លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ

ការបណ្តុះបណ្តាលផ្នែកបរិស្ថាន(ETP)

# មេរៀនៈ A

# ការអភិវឌ្ឍន៍ដោយនិរន្តរភាព និង ការយល់ដឹងពីបរិស្ថាន

## Sustanable Development and Environment Awarenss

ឯកសារសំរាប់សិក្ខាកាម

# មាតិការ

~~~


លក្ខណអេកូឡូស៊ី ប្រជាសាស្ត្រ និងរូបសាស្ត្រនៃអាងទន្លេមេគង្គ................. មេរៀនទី ១

ដំណើរការ និងបញ្ហាក្នុងពិភពធម្មជាតិ..................................... មេរៀនទី ២

គោលការណ៍អភិវឌ្ឍន៍ដោយនិរន្តរភាព................. មេរៀនទី ៣

យាន្តសំរាប់ការ អភិវឌ្ឍន៍ដោយនិរន្តរភាព................. មេរៀនទី ៤

ទំនប់ និង អភិវឌ្ឍន៍ដោយនិរន្តរភាព................. មេរៀនទី ៥

ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព.................. មេរៀនទី ៦

កម្មវិធីរបស់គណៈកម្មការទន្លេមេគង្គដើម្បីការ អភិវឌ្ឍន៍ដោយនិរន្តរភាព................ មេរៀនទី ៧

អក្សរកាត់

សន្ទានុក្រម

ឯកសារយោង
~~~

# លក្ខណៈអេកូឡូស៊ី ប្រជាសាស្ត្រ និងរូបសាស្ត្រនៃអាងទន្លេមេគង្គ

~~~~~~~

ជាទន្លេដ៏ធំមួយនៃពិភពលោក ទន្លេមេគង្គ កើតមានឡើងដោយសារការរលាយព្រិលទឹកកក នៅរយៈកំពស់ ៥៥០០ ម នៃតំបន់អាកាសធាតុដ៏ល្អបរិសុទ្ធនៃភ្នំ តង់ហ្គូឡាសាន់ (Tanggulashan) នៅភាគខាងជើងឈៀងខាង កើតនៃខ្ពង់រាបទីបេ ។ ចាប់ពីកន្លែងនោះដល់ទំនាបទន្លេនៅឆ្នេរខាងត្បូងនៃប្រទេសវៀតណាម និងកម្ពុជា គឺកន្លែងដែលវាហូរចូលទៅក្នុងសមុទ្រចិនខាងត្បូង ការធ្វើដំណើរបត់បែនរបស់វាបាននាំយកទឹកទាំងនោះឆ្លងកាត់ប្រទេសចំនួន ០៦ ចំងាយជិត ៥០០០ គម គឺប្រទេសចិន-ខេត្តយូណាន់ តាមបណ្តោយព្រំដែនខាងជើងឈៀងខាងកើតនៃប្រទេសភូមាជាមួយប្រទេសឡាវ តាមភាគខាងជើងប្រទេសឡាវ និងតាមព្រំដែនខាងលិចនៃប្រទេសឡាវ តាមភាគខាងជើងប្រទេសឡាវ និងតាមព្រំដែនខាងលិចនៃប្រទេសឡាវ និងថៃ ហើយកាត់តាមកណ្តាលប្រទេសកម្ពុជាទៅចុងភាគខាងត្បូងនៃប្រទេសវៀតណាម និងកម្ពុជា ដែលនាំមកនូវទឹក ល្បប់ និងសារធាតុចិញ្ចឹមយ៉ាងច្រើនតាមបណ្តោយផ្លូវរបស់វានោះ ។

## ទន្លេមេគង្គ

អាងទន្លេមេគង្គមានប្រភេទជីវសាស្ត្រ និងទិដ្ឋភាពវប្បធម៌ចំរុះច្រើនបំផុតក្នុងពិភពលោកសព្វថ្ងៃនេះ ( ធនាគារអភិវឌ្ឍន៍អាស៊ី ) ។

ទន្លេនេះត្រូវបានគេដាក់ឈ្មោះឱ្យជាច្រើន ដែលឆ្លុះបញ្ចាំងពីអត្ថន័យរបស់វាចំពោះប្រជាជនដែលវាបានចិញ្ចឹម និងផ្តល់ប្រយោជន៍ឱ្យ គឺមានឈ្មោះ ជាមាតានៃទឹកទាំងអស់ ទន្លេនាគប្រាំបួន ទន្លេថ្ម ទន្លេដ៏ធំ ។ នៅក្នុងខេត្ត យូណាន់ គេហៅថាទន្លេ ឡាន់កាន់យ៉ាង ។

## ទិន្នន័យខ្លះៗស្តីពីប្រជាសាស្ត្រ និងរូបសាស្ត្រ

តាមតំលៃលេខ ទន្លេមេគង្គ ជាទន្លេវែងជាងគេបំផុតនៅអាស៊ីអាគ្នេយ៍ និងវែងជាងគេទី ៨ ក្នុងពិភពលោក ។ ធាទឹកប្រចាំឆ្នាំជាមធ្យម គឺ $475x10^{9}$ $m^{3}$ ដែលឋិតក្នុងជួរទី ១២ បើគិតពីបរិមាណទឹកនេះ ហើយផ្ទៃរងទឹកភ្លៀងរបស់វាសរុប 79 500 $Km^{2}$ ឋិតក្នុងជួរទី ២១ នៃពិភពលោក ។ តារាងទី ១ មានរៀបរាប់ពីទិន្នន័យបន្ថែមទៀតនៃអាងទន្លេមេគង្គ (MRB) ស្តីពីប្រជាជន ផ្ទៃរងទឹកភ្លៀង និងករិតរំហូរទឹកទាំងមូល ។

អ្វីដែលសំខាន់ជាងស្ថិតិទាំងនោះទៀតគឺថា ៨០ ភាគរយ នៃប្រជាជន ៦០ លាននាក់ ដែលរស់នៅក្នុងអាងទន្លេមេគង្គបានពឹងផ្អែកដោយផ្ទាល់លើទន្លេ និងធនធានធម្មជាតិផ្សេងៗទៀតដែលទាក់ទងសំរាប់ការស់នៅ និងតំរូវការផ្សេងៗរបស់គេ ។ ប្រទេសដែលទន្លេនេះហូរកាត់មានលក្ខណជាសេដ្ឋកិច្ចកសិកម្មជាចំបង ហើយកសិករ និងអ្នកនេសាទបានពឹងផ្អែកទៅលើរបបរំហូរទឹកប្រចាំឆ្នាំរបស់ទន្លេមេគង្គ ។ តាមរបាយការណ៍របស់ធនាគារ
~~~~~~~

អភិវឌ្ឍន៍អាស៊ី (ADB) ប្រជាជនប្រហែល ៣០០ លាននាក់ នៅអាស៊ីអាគ្នេយ៍ ពឹងផ្អែកលើផលិតផលមកពីអាង ទន្លេមេគង្គសំរាប់សេចក្តីត្រូវការក្នុងជីវិតប្រចាំថ្ងៃរបស់គេ ។

## ការធ្វើដំណើរត្រួសៗចុះតាមបណ្តោយទន្លេមេគង្គ

ស្ថានភាពភូមិសាស្ត្រ ដែលទន្លេមេគង្គបានហូរកាត់គឺមានលក្ខណៈខុសៗគ្នាជាច្រើន ។ នៅខាងដើមទន្លេនេះ វាបានហូរនាំទឹកពីខ្ពង់រាបភាគខាងជើងក្នុងខេត្តយូណាន់ ប្រទេសឡាវ ភូមា និងប្រទេសថៃ ដែលនៅទីនោះ ទន្លេ និងដៃរបស់វាបានហូរតាមជ្រលងភ្នំជ្រៅៗ ហើយហូរដាច់ដីដោយតាមលក្ខណៈធម្មជាតិ និងសកម្មភាពរបស់មនុស្ស ។ នៅកន្លែងដែលវាជាទន្លេ ឡាន់កានយ៉ាង ក្នុងខេត្តយូណាន់ មានទំនប់ ម៉ាន់វ៉ាន់ ដែលជាទំនប់តែមួយគត់ ដែលបានសាងសង់នៅលើដងទន្លេនេះរហូតមកដល់សព្វថ្ងៃនេះ ហើយដែលបានរារាំងដល់រំហូរទឹកធម្មជាតិ ។ ទំនប់ជាច្រើនទៀតត្រូវបានគេគ្រោងសាងសង់នៅកន្លែងមានជ្រលងជ្រៅនៅតាមបណ្តោយទន្លេនេះ ។ នៅភាគខាងជើងប្រទេសឡាវ និងភាគខាងជើងឈៀងខាងកើតប្រទេសថៃ ទន្លេបានឆ្លងកាត់ដីទំនាប សាខន និង កូរ៉ាត់ ដោយមានដីជាតិអំបិល មុននឹងវាហូរនាំកាត់តំបន់ភ្នំភាគខាងកើតប្រទេសឡាវ ។ ខ្ពង់រាបខាងកើតនេះក៏មានជ្រលងជ្រៅដែលអាចឱ្យគេមានបំណងចង់សាងសង់ទំនប់ផងដែរ ។ នៅភាគខាងលើនៃព្រំដែនឡាវ និងកម្ពុជា ទន្លេនេះបានរីកធំដែលមានទទឹងដល់ ១០ គម ហើយបានចុះមកត្រឹម ៣០ ម នៅត្រង់ល្បាក់ខោនដែលគេហៅថា ÷ "លីពី" ឬ "អន្ទាក់អារក្ស" (Leepee or Spirit Trap) ។ នៅផ្នែកខាងក្រោម និងខាងលើ លីពី នេះទន្លេបានចែកចេញជាច្រើនខ្សែពទ្ធ័ជុំវិញប្រជុំកោះ ស៊ីផាន់ដុន (បួនពាន់កោះ)ដែលជាកន្លែងសំបូរត្រីបំផុតក្នុងប្រទេសឡាវ ។ មានគំរោងជាច្រើនត្រូវបានលើកឡើងក្នុងរយៈពេលច្រើនឆ្នាំកន្លងមកក្នុងការធ្វើឱ្យនាវាចរអាចធ្វើដំណើរបាននៅផ្នែកខាងលើ លីពី នេះ ។

នៅពេលទន្លេឆ្លងកាត់ភាគខាងជើងប្រទេសឡាវចូលមកកម្ពុជា និងវៀតណាម វាបានហូរចូលដីទំនាប ហើយដែលជាបាតុភូតដ៏គួរឱ្យចាប់អារម្មណ៏មួយនៃអាងទន្លេមេគង្គដែលកើតមាននៅទន្លេសាប (ឬបឹងធំ)ដែលជាបឹងធំបំផុតនៅអាស៊ីអាគ្នេយ៏ ។ ដោយមានទឹកជំនន់ពីទន្លេមេគង្គនៅរដូវវស្សា ទន្លេសាបបានកើនផ្ទៃរបស់វាយ៉ាងហោចណាស់ដល់ ៧ ដង បើប្រៀបធៀបទៅនឹងផ្ទៃដែលតូចបំផុតនៅរដូវប្រាំងដែលមានប្រហែល ២៥០០ គម$^{២}$ ដល់ ១៦០០០ គម$^{២}$ ។ ជំរៅរបស់វាបានកើនឡើងពី ១ ម ដល់ ១០ ម ។ ទម្លេមេគង្គ ក៏រួមចំណែកក្នុងការនាំមកនូវដីល្បប់ថ្មីៗ សារជាតិផ្សេងៗ និងផ្តល់នូវជំរកត្រី និងសត្វផ្សេងៗឯទៀតនៅក្នុងទឹកនៅតំបន់ព្រៃលិចទឹកបឹងទន្លេសាប ។ ហើយទន្លេសាបបានផ្តល់មកវិញនូវការកែសំរួលដល់ទឹកជំនន់ក្នុងអាងទន្លេមេគង្គ ដោយវាស្តុកទឹកក្នុងរដូវវស្សា និងបញ្ចេញទឹកមកវិញនៅពេលគ្មានភ្លៀង ។

នៅភ្នំពេញ ទន្លេបាសាក់បានបែកចេញពីទន្លេមេគង្គនៅត្រង់ចំណុច ចតុមុខ នៅក្រោមចំណុចដែលទន្លេសាបបានហូរទៅភាគខាងជើងឈៀងខាងលិចដើម្បីចូលទៅ និងមកពីបឹងទន្លេសាប ។ ទន្លេបាសាក់បានភ្ជាប់

ជាមួយទន្លេមេគង្គធំនេះវិញនៅដីសណ្តមេគង្គនៅភាគខាងជើងបង្អស់ ។ នៅខ្ពង់រាបខាងត្បូងដែលមានជួរភ្នំដីរ៍ និងក្រវ៉ាញ ទឹកបានហូរចូលទៅក្នុងបឹងទន្លេសាប និងទន្លេសាប និងទន្លេបាសាក់ ។

នៅចុងមាត់ផុតបង្អស់របស់វា ទន្លេមេគង្គបានបែកជាដៃទន្លេមួយទៀតទៅក្នុងដីសណ្តមួយដែលហៅថា គូឡុង នៅក្នុងប្រទេសវៀតណាមដែលមានផ្ទៃប្រហែល ៥០០០០ គ.ម២ (ឬហៅថានាគកន្ទុយប្រាំបួន សំរាប់ដៃធំៗទាំងប្រាំបួននៃទន្លេនេះ) ដែលដីល្បប់ដែលនៅសល់ក្នុងទឹកទន្លេនេះត្រូវបានចាក់នៅទីនោះ ហើយបានជួយដល់វិសយ័កសិកម្ម និងជលផល ។ នៅភាគខាងជើងនៃដីសណ្តនេះ ទន្លេបានឆ្លងកាត់ទំនាបត្រែងដែលមានផ្ទៃប្រហែល ១០ ០០០ គ.ម២ ។ នៅទីនោះគេបានធ្វើការកែសំរួលដល់ដីដែលមានជាតិអាស៊ីត ស៊ុលផាត ដើម្បីដាំដំណាំ ។ នៅជិតមាត់នៃដីសណ្តនោះមានការជ្រាបចូលនៃទឹកជាតិអំបិល ភាគច្រើនដោយសារប្រព័ន្ធស្រោចស្រពដែលកំពុងធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ដី និងកសិកម្ម ។

ដីសណ្តមេគង្គគ្របដណ្តប់លើផ្ទៃដីប្រហែល ១២% នៃប្រទេសវៀតណាមដែលមានប្រហែល ៤០%នៃផ្ទៃដីដាំដំណាំនៃប្រទេសនេះ និងលំនៅស្ថានប្រហែល ២០%នៃប្រជាជនទាំអស់ ។ ផ្ទៃដីពីភាគបីនៃដីសណ្តនេះគឺត្រូវប្រើសំរាប់ដាំដំណាំដែលផ្តល់នូវស្បៀងអាហារដល់ច្រើនជាងពាក់កណ្តាលនៃការប្រើប្រាស់ក្នុងប្រទេសវៀតណាម រួមមានស្រូវ ត្រី ជាង៥០% ផ្លែឈើ ជាង៦០% និងផលិតផលពីក្នុងទឹកប្រហែល ៣០០ ០០០ តោន ដែលភាគច្រើនគឺ បង្គារ ដែលភាគច្រើនត្រូវបានគេនាំចេញ ។ ធាទឹកជាមធ្យមនៅដីសណ្តទន្លេមេគង្គគឺ ១៥ ០០០ $m^3$/s ។

តាមបណ្តោយពីខ្ពង់រាបទីបេមកដល់សមុទ្រចិនខាងត្បូង ទន្លេមេគង្គត្រូវបានភ្ជាប់ដោយដៃទន្លេជាង ១៣០ ដែលរួមចំណែកដល់រំហូរទឹក និងដីល្បប់នៅក្នុង "មាតានៃទន្លេទាំងអស់នោះ" ។

តារាង ១: ប្រជាពលរដ្ឋ និងផ្ទៃរងទឹកភ្លៀងនៃបណ្តាប្រទេសក្នុងអាង MRB

| ប្រទេស | ចំនួនប្រជាជន (លាន) | ប្រជាជនក្នុងអាង MRB (លាន) | ភាគរយនៃអាង MRB | |
|---|---|---|---|---|
| | | | ផ្ទៃដី | ធាទឹក |
| ខេត្តយូណាន់ចិន | N/a | 10 | 22 | 16 |
| ភូមា | 44 | 2 | 3 | 2 |
| ឡាវ | 5 | 5 | 25 | 35 |
| កម្ពុជា | 11 | 10 | 19 | 18 |
| វៀតណាម | 79 | 20 | 8 | 11 |
| ថៃ | 62 | 25 | 23 | 8 |

## ការត្រួតពិនិត្យត្រួសៗលើជីវចម្រុះក្នុងអាង MRB

ដូចបានឆ្លុះបញ្ចាំងនៅក្នុងសេចក្ដីដកស្រង់នៃមេរៀននេះដំបូង អាង MRB គឺជាទីជំរកនៃប្រភេទជីវសាស្ត្រដ៏សំបូរ និងមានច្រើនប្រភេទក្នុងពិភពលោក ។ ប្រភេទរុក្ខជាតិ សត្វ និង ត្រីប្រភេទថ្មីៗនៅតែបន្តឃើញមាន ទោះបីជាប្រភេទខ្លះត្រូវបានទទួលរងគ្រោះ ឬបាត់បង់ដោយសារការបាត់បង់ជំរក និងការបរបាញ់ ឬចាប់ហួសប្រមាណក៏ដោយ ។

## ប្រទេសកម្ពុជា

យោងទៅតាមទំហំដី ប្រទេសកម្ពុជាមានអត្រាជំរកដីសើម និងព្រៃលិចទឹកខ្ពស់ជាងគេបង្អស់នៅក្នុងពិភពលោក ហើយមានឆ្នេរដែលរងផលប៉ះពាល់តិចជាងគេក្នុងទ្វីបអាស៊ី ។ គេឃើញមានប្រភេទជំរកជាង ៤៥ ប្រភេទក្នុងប្រទេស ។ កត្តាធម្មជាតិនៃទន្លេមេគង្គ និងអាកាសធាតុបានផ្ដល់នូវផលិតផលធម្មជាតិជាច្រើនប្រភេទ ។ ក្នុងចំណោមប្រភេទរុក្ខជាតិ ២ ៣០០ ប្រភេទដែលមានរៀបរាប់ក្នុងប្រទេសកម្ពុជា មាន ៤០% ត្រូវបានប្រើប្រាស់ជាប្រពៃណីសំរាប់ជាអាហារ និងថ្នាំ ។ គេជឿថាមានថនិកសត្វជាង ១៣០ ប្រភេទ និងសត្វស្លាបជាង ៥០០ ប្រភេទនៅក្នុងប្រទេស ហើយដែលភាគច្រើនគឺជាប្រភេទសំខាន់ដែលត្រូវថែរក្សាជាលក្ខណៈអន្តរជាតិ ។ យ៉ាងហោចណាស់ត្រីទឹកសាបចំនួន ៣០០ ប្រភេទ ត្រូវបានគេកំណត់ ដែលមាន ២១៥ ប្រភេទជាប្រភេទដែលរស់នៅក្នុងទន្លេសាបញឹកញាប់ ។

## ប្រទេសឡាវ

ដោយសារលក្ខណៈភូមិសាស្ត្រជាតំបន់ភ្នំប្រទេសឡាវមានលក្ខណៈអាកាសធាតុ ដី ព្រៃឈើ និងទីវាលប្លែកៗគ្នាជាច្រើនដែលធ្វើឱ្យប្រទេសនេះមានលក្ខណៈពិសេសដែលសំបូរទៅដោយជីវចំរុះនៅក្នុងប្រពន្ធ័អេកូឡូស៊ី ។ គេជឿថាមានថនិកសត្វ ល្មូន សត្វដែលរស់នៅក្នុងទឹកផង និងលើគោកផង សត្វស្លាប ត្រី មេអំបៅ និងរុក្ខជាតិប្រហែល ១០ ០០០ ប្រភេទបានរស់នៅក្នុងតំបន់ព្រៃ ។ គេជឿដោយគ្មានសង្ស័យថា នៅមានប្រភេទផ្សេងៗទៀតដែលមិនទាន់រកឃើញ ។ តាមអង្គការអន្តរជាតិដើម្បីថែរក្សាធម្មជាតិ និង ធនធានធម្មជាតិ (IUCN) បានឱ្យដឹងថា ប្រទេសឡាវមានដង់ស៊ីតេនៃប្រភេទសត្វថ្នាក់លេខ ២ បន្ទាប់ពីប្រទេសកម្ពុជា និង ថ្នាក់លេខ ៤ បន្ទាប់ពីថៃ ភូមា និង វៀតណាមបើគិតពីប្រភេទដែលមានតែនៅកន្លែងណាមួយនោះ ។ ប្រភេទថនិកសត្វ និងសត្វស្លាបប្រហែល ២៥ ប្រភេទ រួមទាំង គោព្រៃ ជ្រូកព្រៃ និង ក្រៀលគឺត្រូវបានចាត់ជាប្រភេទដែលទទួលរងការគំរាមគំហែង ។

## ប្រទេសថៃ

ពុំមានតួរលេខច្បាស់លាស់ទាក់ទងទៅនឹងអត្រាក្នុងអាង MRB នៃប្រទេសថៃទេ ប៉ុន្តែជាទូទៅប្រទេសនេះកំពុងទទួលការបាត់បង់យ៉ាងលឿននូវជីវិតសត្វ និងរុក្ខជាតិ ។ ជារួមប្រទេសថៃមានប្រភេទរុក្ខជាតិពី ១០ ០០០ ទៅ ១៣ ០០០ និង សត្វ ៨៦ ០០០ ដែលមាន ៥០០០ ប្រភេទជាសត្វមានឆ្អឹងខ្នង ។ ទោះជាយ៉ាងណាក៏ដោយប្រភេទសត្វ ថនិកសត្វ ត្រី សត្វស្លាប និងល្មូន ដែលមានតែនៅក្នុងប្រទេសថៃ ត្រូវបាត់បង់ក្នុងពេលថ្មីៗនេះ ។ ត្រីទឹកសាប ២០ ប្រភេទ សត្វរស់នៅក្នុងទឹកផង និងលើគោកផង ២ ប្រភេទ ល្មូន ១០ ប្រភេទ និង ប្រហែល ៤០ ប្រភេទសត្វស្លាប និង ថនិកសត្វ ៤០ ប្រភេទ ទៀតត្រូវទទួលរងការគំរាមគំហែង ។ រុក្ខជាតិប្រហែល ១០០ ប្រភេទត្រូវបានគិតថាទទួលរងគ្រោះថ្នាក់ ៦០០ ប្រភេទជាប្រភេទកំរ និង ៣០០ ជាប្រភេទ ងាយរងគ្រោះថ្នាក់ ។

## ប្រទេសវៀតណាម

ទោះបីជាប្រទេសវៀតណាមគ្របដណ្តប់តែ ១% នៃផ្ទៃដីពិភពលោកទាំងមូលក៏ដោយវាជាជំរកនៃសំរាប់ ១០% នៃប្រភេទថនិកសត្វ សត្វស្លាប និងត្រី ។ ដីព្រៃត្រូវបានថយចុះយ៉ាងខ្លាំងក្នុងរយៈពេលជាង ៣០ ឆ្នាំកន្លងមកនេះ តែទោះបីជាយ៉ាងនោះក៏ដោយក្នុងព្រៃដែលនៅសល់នោះមានសត្វស្លាប និងជីវចំរុះច្រើនជាងគេនៅក្នុងតំបន់ដីគោកនៅអាស៊ីអាគ្នេយ៍ ។ គេឃើញមានប្រភេទសត្វលើគោក និងក្នុងទឹកដែលបានកំណត់ចំនួន ២៣ ០០០ ប្រភេទ និងប្រភេទថនិកសត្វថ្មីៗផ្សេងទៀត ត្រូវបានជួបប្រទះក្នុងពេលថ្មីៗនេះ ។ ប៉ុន្តែប្រភេទដែលមានតែនៅក្នុងប្រទេសសវៀតណាម មាន ២៨% នៃថនិកសត្វ ១០% នៃសត្វស្លាប និង ២១% នៃសត្វរស់នៅក្នុងទឹកផង និងលើគោកផង ហើយល្មូនត្រូវបានគិតថាជាប្រភេទងាយរងគ្រោះថ្នាក់ ។ ក្នុងចំណោមរុក្ខជាតិដែលគេស្គាល់ចំនួន ១២ ០០០ ប្រភេទ គឺមានប្រហែល ៤០ % ជាប្រភេទដែលមានតែនៅប្រទេសវៀតណាម ប្រហែល ៥០០០ប្រភេទ ជាប្រភេទមានតំលៃសេដ្ឋកិច្ច ។

ការបាត់បង់នូវប្រភេទទាំងនេះគឺមិនអាចស្តារឡើងវិញបាន បាត់បង់នូវព្រព្ធ័អេកូឡូស៊ី និង ជីវចំរុះ ហើយនឹងអាចប៉ះពាល់ដល់ការរីកចំរើនសេដ្ឋកិច្ចនាពេលអនាគតផង ។

## ជលផលនៅក្នុងអាង MRB

មានប្រហែល ១ ៣០០ ប្រភេទត្រីដែលបានកំណត់នៅក្នុងអាង MRB ដែល ៥០% ជាប្រភេទដែលមានតែនៅក្នុងតំបន់នេះ និង ១២០ ប្រភេទជាប្រភេទដែលមានតំលៃពាណិជ្ជកម្មសំខាន់ៗក្នុងទីផ្សារក្នុងស្រុក ។ មានប្រភេទត្រីអណ្តែង (Catfish) ប្រហែល ១២៥ ប្រភេទ ប៉ុន្តែប្រភេទត្រីនេះធំៗគឺកំរជួបណាស់នៅពេលបច្ចុប្បន្ន ។ ត្រីនេះត្រូវការរយៈពេលជាច្រើនឆ្នាំមុននឹងវាអាចចាប់ផ្តើមពង ហើយដោយសារតែការនេសាទហួសប្រមាណត្រី នេះគឺឋិតក្នុងស្ថានភាពគ្មាននិរន្តរភាព ។ ហើយស្ថានភាពនេះគឺមានដូចគ្នាដែរចំពោះត្រីដូហ្វាំងធំៗឯទៀត ។

បន្ថែមពីលើទឹកជំនន់នៅទន្លេសាបដែលបានលើកឡើងខាងលើ ទន្លេមេគង្គមានទឹកជំនន់លើផ្ទៃដីប្រហែល ៣០ ០០០ គ.ម² ខាងក្រោមភ្នំពេញក្នុងប្រទេសកម្ពុជា និងផ្ទៃដីសណ្តមួយចំនួនក្នុងប្រទេសវៀតណាម និងកម្ពុជា ។ តំបន់ដែលមានទឹកជំនន់តាមពេលមានទិន្នផលត្រីច្រើនជាងតំបន់ដែលមានទឹកជាប្រចាំជាច្រើនដង ដែលនោះហើយនាំឱ្យទឹក និង ទំនាបលិចទឹកនៅក្នុងទន្លេមេគង្គគឺជាកន្លែងដែលមានផលិតផលត្រីច្រើនជាងគេមួយក្នុងពិភពលោកនេះ ។ ឧទាហរណ៍តំបន់ព្រៃលិចទឹកទន្លេសាបមានទិន្នផលត្រីពី 138 ទៅ 175 Kg/ha ។ ហើយផ្ទុយទៅវិញទិន្នផលជាមធ្យមនៅទន្លេ អាម៉ាស៊ូន មាន **២៤** Kg/ha ។

ការប៉ាន់ស្មានការចាប់ត្រីសរុបក្នុងអាង MRB មានរហូតដល់ ១ លានតោន ក្នុងមួយឆ្នាំបន្ថែមពីលើត្រីចិញ្ចឹម ២០០ ០០០ តោន ទៀត (Jeusen 2000) និង ៣០០០០០ តោន បង្ការទៀតពីកិច្ចដំណើការក្នុងដីសណ្តមេគង្គ ។ ប្រហែល ២០% នៃផលិតផលនេះបានយកមកពីទន្លេសាប ។ ចំនួននៃការចាប់នោះភាគច្រើនសំរាប់សេចក្តីត្រូវការក្នុងស្រុកសំរាប់ជាអាហារ ប៉ុន្តែប្រសិនបើគេលក់ទាំងអស់ទៅក្នុងផ្សារអន្តរជាតិ វានឹងទទួលបានទឹកប្រាក់ប្រហែល ១ កោដិ ដុល្លាអាមេរិក ក្នុងមួយឆ្នាំ ។ ការប្រើប្រាស់ត្រីជាមធ្យមក្នុងអាងទន្លេមេគង្គក្រោមគឺ ២០ គក្រ/ម្នាក់/ឆ្នាំ ទោះបីជានៅកម្ពុជា និងនៅក្នុងតំបន់ដីសណ្តមានចំនួន ៦០-៧០ គក្រ/ម្នាក់/ឆ្នាំ គឺប្រហែលនឹងចំនួនខ្ពស់បំផុតនៃបណ្តាប្រទេសជាប់សមុទ្រមួយចំនួនក្នុងពិភពលោកដូចជា **ណរវ៉េ ជប៉ុន** និង កោះមួយចំនួនក្នុងសមុទ្រប៉ាស៊ីហ្វិក ។

ដំណើជីវិតរបស់ត្រីភាគច្រើន ជាពិសេសប្រភេទដែលមានតំលៃសេដ្ឋកិច្ច គឺពឹងផ្អែកទៅលើទឹកជំនន់លើព្រៃជុំវិញទន្លេសាប និងការធ្វើដំណើរដោយសេរីពីទីនោះទៅក្នុងទន្លេមេគង្គ និងដៃរបស់វា ។ ដូចជាត្រីរៀលដែលជាត្រីតូចៗ និងសំខាន់សំរាប់ជាអាហារដែលបានត្រូវចាប់ក្នុងបរិមាណដ៏ច្រើននៅតាមដៃក្នុងទន្លេសាបបានធ្វើដំណើយ៉ាងឆ្ងាយរហូតដល់ ១០០០ គ.ម ទៅផ្នែកខ្សែទឹកខាងលើទន្លេមេគង្គ និងក្នុងដៃជាច្រើនដើម្បីពងមុនចាប់ផ្តើមចុះមកវិញនៅដើមរដូវវស្សាទៅក្នុងទន្លេសាប ។ មានត្រីខ្លះបានធ្វើដំណើរដល់ទៅ ៣០០ គម ទៅភាគខាងត្បូងនៃដីសណ្តក្នុងប្រទេសវៀតណាម ។ ការមិនរារាំងដល់ការធ្វើដំណើររបស់ត្រីនេះ និងប្រភេទត្រីជាច្រើនទៀតគឺជាកត្តាសំខាន់សំរាប់ការរស់នៅ របស់វា និងការផ្តល់នូវតំរូវការរបស់ប្រជាជននៅក្នុងអាង MRB ។

លំនាចធម្មជាតិ និង រំហូរទឹកនៃទន្លេមេគង្គ គឺជាប្រភពជីវិត និងសុខភាពសំរាប់ត្រី ។

## ព្រៃឈើក្នុងអាង MRB

ព្រៃឈើក្នុងអាង MRB មានការថយចុះក្នុងកំរិតប្រកាសអាសន្នក្នុងរយៈពេលជាង ៣០ ឆ្នាំកន្លងមក នេះ ។ ព្រៃដីស្ងួត និងដីសើម (ដូចជាព្រៃលិចទឹកនៅទន្លេសាប និងព្រៃកោងកាងនៅតាមឆ្នេរ) ត្រូវបានគេធ្វើអាជីវកម្មសំរាប់ឈើពាណិជ្ជកម្ម និងបំណងផ្សេងៗទៀត ។ ស្ថានភាពគឺស្ថិតក្នុងសភាពព្រួយបារម្ភខ្លាំងក្នុងគ្រប់ប្រទេសក្នុងអាងទន្លេមេគង្គក្រោម ។ តួលេខក្នុងអត្ថបទខាងក្រោមគឺជាតួលេខប៉ាន់ស្មានតែប៉ុណ្ណោះដោយសារពុំមានទិន្នន័យណាច្បាស់លាស់ជាងនេះ ។

## ប្រទេសកម្ពុជា

កម្ពុជាមានដីព្រៃនៅសល់ប្រហែល ៤៩-៦៣% (ប្រហែល ១០ លាន ហិចតា) អាស្រ័យទៅតាមប្រភពព័ត៌មានដែលទទួលបាន ។ ADB បានសន្និដ្ឋានថាប្រទេសកម្ពុជានៅសល់ព្រៃច្រើនបើប្រៀបធៀបទៅនឹងប្រទេសជិតខាង ទោះបីជាតាមការសន្និដ្ឋានថាបានឱ្យដឹងថា ការបំផ្លិចបំផ្លាញព្រៃកំពុងបន្តក្នុងអត្រាមួយប្រហែល ៣00 000 ហិចតា/ឆ្នាំ ឬ ៣% នៃចំនួនសរុបរៀងរាល់ឆ្នាំក៏ដោយ ។

## ប្រទេសឡាវ

ដីព្រៃមាននៅក្នុងប្រទេសឡាវគឺពី ៤0-៥0% (១១ លានហិចតា ក្នុងឆ្នាំ១៩៩២) គឺថយចុះពី ៧0 % ដែលធ្លាប់មានកាលពី ៥0 ឆ្នាំ កន្លងមក ។ ដីព្រៃមានភាគច្រើននៅភាគខាងត្បូង (៥៨%) ជាងនៅភាគខាងជើង (៣៦%) ។ តាមរបាយការណ៍ MRC (1997) មានតែ ៤.៧% នៃផ្ទៃដីសរុបមានឈើប្រភេទមានតំលៃពាណិជ្ជកម្ម ។ គេបានប៉ាន់ស្មានថា អត្រាបំផ្លិចបំផ្លាញព្រៃឈើមានដូចប្រទេសកម្ពុជាដែរ ។

## ប្រទេសថៃ

ការបំផ្លិចបំផ្លាញព្រៃឈើក្នុងប្រទេសថៃកើតមានក្នុងកំរិតមួយលឿនជាងប្រទេសដទៃទៀតក្នុងតំបន់ ។ តាមការប៉ាន់ស្មានក្នុងឆ្នាំ ១៩៩៧ របស់ក្រសួងវិទ្យាសាស្ត្រ បច្ចេកទេស និងបរិស្ថាន (MOSTE) ផ្ទៃដីព្រៃនៃប្រទេសទាំងមូលបានថយចុះជាមធ្យម ៤00000 ហិចតា/ឆ្នាំ គឺពី ៥៣% ទៅ ២៥% ក្នុងចន្លោះឆ្នាំ ១៩៦១ និង ១៩៩៨ ។ នៅភាគខាងជើងឈៀងខាងកើតប្រទេសថៃ (នៅកន្លែងដែលស្ថិតក្នុងអាង MRB) ព្រៃឈើនៅសល់គឺមានតែ ១៣% ដោយថយចុះ ៦៩% ក្នុងរយៈពេល ៣0 ឆ្នាំកន្លងមកនេះ ។ ព្រៃត្រូវបានគេកាប់ក្នុងអត្រា 0.៣% នៃចំនួនសរុបរៀងរាល់ឆ្នាំ ។

## ប្រទេសវៀតណាម

ក្នុងដីសណ្តមេគង្គដីព្រៃបានថយចុះពី ២៣% ក្នុងឆ្នាំ ១៩៤៣ មក ៩% ក្នុងឆ្នាំ ១៩៩១ ។ ប្រហែល ៣៤000 ហិចតានៃព្រៃកោងកាង និង ១៣ ហិចតា នៃព្រៃ មាឡាឡិកា មាននៅសល់ក្នុងប្រទេសវៀតណាមក្នុងពាក់កណ្តាលទសវត្សរឆ្នាំ ១៩៩0 ។ ជាទូទៅក្នុងប្រទេសវៀតណាមមានប្រហែល ៣0% នៃដីព្រៃសរុបត្រូវបាត់បង់ក្នុងរយៈពេល ៣0 ឆ្នាំកន្លងមករហូតដល់ចំណុចដែលវាមានតែ ១១% នៃព្រៃនៅសល់ប៉ុណ្ណោះដែលជាប្រភេទឈើមានគុណភាពល្អ ។ អាត្រាបំផ្លិចបំផ្លាញព្រៃឈើប្រចាំឆ្នាំមាន 0.៨% ។

## សង្ខេបចំណុចសំខាន់ៗ

- ទិដ្ឋភាពជាច្រើននៃទន្លេមេគង្គ- ទឹក ធារាសាស្ត្រ ដីល្បប់ ត្រី គឺជាកត្តាសំខាន់សំរាប់ការរស់នៅ និង សុខមាលភាពរបស់ប្រជាជនក្នុងអាង MRB ។
- អាង MRB គឺមានលក្ខណៈពិសេសពីគេបើនិយាយពីភាពប្លែកៗផ្សេងៗគ្នានៃជីវសាស្ត្រ និងវប្បធម៌ ។
- ប្រជាជនប្រហែល ៥0 លាននាក់ ក្នុងអាង MRB ពឹងផ្អែកដោយផ្ទាល់លើទន្លេសំរាប់ការរស់នៅ និង សេចក្តីត្រូវការប្រចាំថ្ងៃរបស់គេ ។
- ភាពប្រែប្រួលនៃរំហូរទឹកក្នុងទន្លេដែលនាំឱ្យមានទឹកជំនន់លើផ្ទៃដីដ៏ធំក្នុងរដូវវស្សានាំឱ្យអាង MRB ជាអាងមួយសំបូរត្រីជាងគេក្នុងចំណោមអាងនៅក្នុងពិភពលោក ។
- ជាលទ្ធផលនៃសម្ពាធក្នុងឆ្នាំថ្មីៗនេះទៅលើព្រៃឈើ ជលផល និង រុក្ខជាតិផ្សេងៗ និង សត្វព្រៃ ធនធាន ធម្មជាតិទូទាំងអាង MRB បានថយចុះដែលក្នុងករណីខ្លះត្រូវវិនាសយ៉ាងខ្លាំង ។

# របៀបអនុវត្តន៍ដោយគ្មាននិរន្តរភាពក្នុងអាងទន្លេមេគង្គ

~~~~~~~

## មូលដ្ឋានគ្រឹះនៃបរិស្ថាន និងប្រពន្ធ័អេកូឡូស៊ី

**និយមន័យ:**

បរិស្ថានរួមមានបន្សំនៃធម្មជាតិ និងអ្វីៗដែលបង្កើតឡើងនៅជុំវិញយើងមានៈ ខ្យល់ ទឹក ដី សារជាតិគីមី រុក្ខជាតិ សត្វ( តាំងពីសត្វល្អិតដល់ដំរី) សារជាតិសរីរាង្គ ថាមពលព្រះអាទិត្យ មនុស្ស និងរចនាសម្ព័ន្ធរបស់មនុស្ស ។

ប្រពន្ធ័អេកូឡូស៊ីគឺកើតឡើងដោយសារចលនាប្រតិកម្មទៅវិញទៅមក និងភាពទាក់ទងគ្នារវាងផ្នែកផ្សេងៗនៃបរិស្ថានគឺៈ ខ្យល់ ទឹក ដី និងជីវសាស្ត្រ និង រំហូរទឹក និងការបំលែងថាមពលរវាងផ្នែកទាំងនោះ ។

## លក្ខណៈរបស់ប្រពន្ធ័អេកូឡូស៊ី

ប្រពន្ធ័អេកូឡូស៊ីវិវត្តន៍ឡើងពីស្ថានភាពមិនទាន់ចាស់រឹងមាំដែលត្រូវលូតលាស់ ។ វាធ្វើឱ្យដីមានភាពរឹងមាំ ពិនិត្យសំណើកដី នាំយកនូវសារជាតិពីដីស្រទាប់ក្រោម និងការពារដល់ការខូចខាតដែលអាចកើតឡើងនៅពេលគ្មានវា ។ ស្ថានភាពដំបូងនេះត្រូវបានជំនួសបន្ទាប់មកដោយការកើនឡើងនូវសារជាតិសរីរាង្គសាំញ៉ាំ និងការទំនាក់ទំនងតាមរយៈដំណាក់កាលជាច្រើន ។ ជាយថាហេតុ ប្រពន្ធ័ដែលមានចំណាស់នោះត្រូវបានបង្កើតឡើងដែលមានលក្ខណៈគ្រប់គ្រាន់ ការថែរក្សាធនធាន និងមានលក្ខណៈល្អបំផុតសមស្របទៅតាមស្ថានភាពបរិស្ថានក្នុងកន្លែងនោះ ។

ប្រពន្ធ័ដែលមានចំណាស់បំផុតរួមមាន សម្ព័ន្ធនៃសារជាតិសរីរាង្គដែលស្ថិតក្នុងស្ថានភាពលំនឹងមួយ ហើយដែលអាចឱ្យទីជំរកនោះនៅរក្សាមិនផ្លាស់ប្តូរពីមួយឆ្នាំទៅមួយឆ្នាំ ។ ទោះបីជាប្រពន្ធ័ដែលចាស់រឹងមាំនោះវាមិនអាចនៅស្ថិតស្ថេរជារៀងរហូតក៏ដោយប៉ុន្តែវាមានលក្ខណៈផ្សេងៗគ្នាជាច្រើន មានស្ថេរភាព និងមានលក្ខណៈសាំញ៉ាំ និងមានលក្ខណៈធន់និងការរំខានផ្សេងៗជាងដំណាក់កាលផ្សេងៗទៀតនៃប្រពន្ធ័អេកូឡូស៊ី ។ តាមរយៈការផ្លាស់ប្តូរដ៏សាំញ៉ាំនៃសារជាតិ ឧស្ម័ន និងថាមពល ប្រពន្ធ័ចំណាស់នោះបានបង្កើតនូវចំនួនជីវម៉ាសដ៏ច្រើនចេញពីធនធានដ៏តិចនោះ ។ ប្រពន្ធ័អេកូឡូស៊ីមួយគឺជាដំណើរការដ៏ស្ថិតស្ថេរមួយនៃថាមពល និងសារជាតិដែលបានខិតខំបង្កើតឡើងដើម្បីទទួលបាននូវថាមពល និងស្ថេរភាពក្នុងប្រពន្ធ័តុល្យភាពមួយ ។ ការមានស្ថានភាពផ្សេងៗគ្នាច្រើនគឺបង្ហាញពីភាពចំណាស់នៃប្រពន្ធ័អេកូឡូស៊ី ។ ដើម្បីឱ្យមានការរស់នៅល្អសមរម្យ រុក្ខជាតិ និងសត្វនិមួយៗ វាមានលក្ខណៈរស់នៅផ្ទាល់របស់វារួមមាន ជំរកធម្មជាតិ តំរូវការរូបសាស្ត្រ និងអាកាសធាតុ ។ ដោយសារពុំមានប្រពន្ធ័អេកូឡូស៊ីណាមានលក្ខណៈដូចគ្នាទៅនឹងឥទ្ធិពលមកពីខាងក្រៅ ការផ្លាស់ប្តូរតែងតែកើតមានដោយសារ
~~~~~~~

តុល្យភាពនៃប្រពន្ធ័ត្រូវបានរំខាន ហើយប្រពន្ធ័អេកូឡូស៊ីបានបន្តកែតំរូវទៅតាមកត្តាថ្មីនោះ ឬ ក៏ការបញ្ចេញថាមពលនោះ ។ ក្នុងស្ថានភាពនេះ ប្រពន្ធ័អេកូឡូស៊ីគឺស្ថិតនៅក្នុងសភាពធនផង និងងាយខូចខាតផង ។

## ផលប៉ះពាល់នៃសកម្មភាពដែលគ្មាននិរន្តរភាពរបស់មនុស្ស លើផ្នែកផ្សេងៗនៃប្រពន្ធ័អេកូឡូស៊ីក្នុងអាងទន្លេមេគង្គ

### ព្រៃធម្មជាតិ

ដីព្រៃក្នុងគ្រប់ប្រទេសនៃអាងទន្លេមេគង្គ (MRB) បានត្រូវបាត់បង់យ៉ាងលឿនក្នុងរយៈពេល ៣០ ឆ្នាំកន្លងមកនេះ ។ ក្នុងរយៈពេលជាង ១០ ឆ្នាំកន្លងមកការបាត់បង់ព្រៃឈើត្រូវបានកើតឡើងក្នុងប្រទេសឡាវ និងកម្ពុជា ចំណែកឯនៅប្រទេសថៃ និងវៀតណាម ការថយចុះនៃដីព្រៃហាក់ដូចជាមានលក្ខណៈយឺតក្នុងឆ្នាំថ្មីៗនេះដោយសារមានការថយចុះនូវកាកសំណល់ជាមូលដ្ឋាននៃដីព្រៃ ។ ដីព្រៃនៅក្នុងអាង MRB សព្វថ្ងៃនេះត្រូវបានគេប៉ាន់ស្មានថានៅត្រឹមតែតិចជាងពាក់កណ្តាលនៃដីព្រៃដែលធ្លាប់មាននៅក្នុងឆ្នាំ ១៩៧០ ទោះបីជាពុំមានទិន្នន័យច្បាស់លាស់ក៏ដោយ ដោយសារខ្វះធនធានមនុស្សក្នុងការត្រួតពិនិត្យ និងធ្វើសារពើភណ្ឌ័ព្រៃឈើ ។

សម្ពាធលើព្រៃឈើភាគច្រើនបណ្តាលមកពីការកាប់ឈើធ្វើពាណិជ្ជកម្ម ដែលភាគច្រើនបណ្តាលមកពីការផ្តល់នូវព្រៃសម្បទានដោយរដ្ឋាភិបាល ។ ជាមួយគ្នានោះដែរការកាប់ឈើដោយខុសច្បាប់ដែលទទួលបាននូវសម្បទាន និងអ្នកផ្សេងៗទៀតបានធ្វើឱ្យមានការកាប់យកឈើប្រភេទមានតំលៃថ្លៃ រួមជាមួយការខូតខាតទៅលើប្រពន្ធ័អេកូឡូស៊ីព្រៃឈើដែលនៅសល់ទៀតផង ។ តាមរបាយការណ៍របស់ MRC (1997) បានឱ្យដឹងថា មានឈើហ៊ុបចំនួន ២ ៥០០ ឡាន ក្នុងមួយថ្ងៃ បានដឹកចេញពីប្រទេសកម្ពុជាដែលភាគច្រើនត្រូវបាននាំចេញដោយខុសច្បាប់ និងដោយគ្មានចំណូលទៅរតនាគាជាតិកម្ពុជាទេ ។

ការរកឧសជាលក្ខណៈប្រពៃណីដោយសហគមន៏ មូលដ្ឋាន ការរានព្រៃដើម្បីគោលបំណងកសិកម្មដោយប្រើវិធីកាប់ព្រៃដុត កសិកម្មពនាចរ ការសាងសង់ផ្លូវថ្នល់ និង អាងទឹកដែលជាមូលហេតុបណ្តាលឱ្យព្រៃដែលនៅសល់ត្រូវបាត់បង់ ។ ការរកឧសជួនកាលត្រូវបានគេគិតថា ជា មូលហេតុចំបងនៃការបាត់បង់ព្រៃ ប៉ុន្តែត្រូវពិនិត្យមើលក្នុងបរិបទនៃប្រពន្ធ័ទូលំទូលាយមួយរវាងអ្នកដែលឈ្នះ និងអ្នកដែលចាញ់ក្នុងការអភិវឌ្ឍន៏សេដ្ឋកិច្ច ។ នៅពេលដែលរបៀបរស់នៅជាលក្ខណៈប្រពៃណីត្រូវបានទទួល រងសម្ពាធដោយការអភិវឌ្ឍន៏ ដូចជាការកាប់ឈើហ៊ុបជាដើមនោះ ការរស់នៅរបស់អ្នកដែលមិនបានទទួល ផលប្រយោជន៏នោះត្រូវពឹងផ្អែកលើធនធានដែលមានតិចជាងមុន ពេលមានការអភិវឌ្ឍន៏នោះ ។ ការបាត់បង់ ព្រៃឈើដ៏ច្រើននៃការរកឧសប្រៀបធៀបទៅនឹងការកាប់ព្រៃឈើជាទ្រង់ទ្រាយធំនោះ ពុំទាន់បានបង្ហាញឱ្យបាន ច្បាស់លាស់ទេ ។

ជាការពិតណាស់ ការបាត់បង់ ព្រៃឈើធំៗ និងរុក្ខជាតិ សត្វ សារជាតិសរីរាង្គ និង សណ្ឋានដី បានបំផ្លាញដល់ប្រពន្ធ័អេកូឡូស៊ីដែលមានចំណាស់ និងមានស្ថេរភាព និងជីវចំរុះ ។ ករណីទាំងអស់នេះអាចគិតថាជាតំលៃនៃការីកចំរើន ប្រសិនបើផលចំណូលពីកាប់ឈើនោះត្រូវបានប្រមូល និងចែកចាយស្មើគ្នា ហើយការ

ផ្លាស់ប្តូរនៃបរិស្ថាននោះអាចកាត់បន្ថយ ឬ បំបាត់បាន ។ ក្នុងការអនុវត្តន៍ជាក់ស្តែង ដូចបានកត់សំគាល់ខាងលើសំរាប់កម្ពុជាករណីនេះពុំមាមកើតឡើងទេ ។

ដីដែលបានរានព្រៃហើយ ដែលត្រូវទុកចោល ឬប្រែក្លាយទៅជាដីកសិកម្មនោះ ពុំមានជីជាតិដូចដើមទេ ។ ក្នុងព្រៃតំបន់ត្រូពិច សារជាតិជាច្រើនត្រូវបានរក្សាទុកនៅក្នុងរុក្ខជាតិរស់មិនមែននៅក្នុងដីទេ ។ សារជាតិដែលនៅសល់ក្នុងដីត្រូវបានបាត់បង់អស់នៅពេលធ្វើកសិកម្មដំបូងម្ល៉េះ ក្រោយមកមានតែការប្រើជីរគីមីសិប្បនិមិត្តទេដែលអាចឱ្យយើងទទួលបានទិន្នផលល្អ ។

បន្ថែមពីលើរបួសដែលដីព្រៃត្រូវបានគេកាប់ដើមឈើដែលការពារ វានោះ ត្រូវរងការប៉ះផ្ទាល់ពីខ្យល់និងភ្លៀងដែលធ្វើឱ្យដាច់ដីហើយហូរច្រោះសារជាតិទៅក្នុងទឹកហើយផ្ទុកនៅ កន្លែងដែលវាអាចធ្លាក់ចុះ និងគ្របដណ្តប់កន្លែងនៅបាតទឹកនោះ ឬ ក៏នាំឱ្យមានដីល្បប់ដុះនៅមាត់អាងទឹកដែលនាំ ឱ្យថយចុះនូវសម្ថភាពស្តុកទឹកនិងអាយុប្រើប្រាស់របស់វា ។

គេមានកាព្រួយបារម្ភថាដីល្បាប់ដែលដុះនៅក្នុង ទន្លេសាប ឬ (បឹងទន្លេសាប) ដែលបណ្តាលមកពីទឹកហូរតាមដីព្រៃដែលត្រូវគេរានជិត១នោះបានធ្វើឱ្យជំរៅបឹងចុះរាក់ ថយចុះនៅបរិមាណស្តុកទឹក និងបង្កើននូវសីតុណ្ហភាពទឹក ហើយដែលកត្តាទាំងនោះមានផលប៉ះពាល់ អាក្រក់ដល់ប្រពន្ឋ័អេកូឡូស៊ីនៃតំបន់ដ៏សំខាន់ក្នុងអាង MRB នេះ ។

ផលវិបាកមួយទៀតនៃការបំផ្លិចបំផ្លាញព្រៃដ៏ធំនេះគឺការប៉ះពាល់លើការឡើងកំដៅអាកាសធាតុក្នុងពិភពលោក ។ ព្រៃបានប្រើប្រាស់ឧស្ម័កាបូនឌីអុកស៊ីតក្នុងការធ្វើសំយោគកាំរស្មីព្រះអាទិត្យហើយក៏បានកាត់បន្ថយចំនួនកំដៅដែលចាំងលើវា និងផ្លាតមកពីដីវិញដែរ ។ នៅពេលដែលព្រៃគ្របដណ្តប់ដីនោះត្រូវគេកាប់ចេញ ទីកន្លែងនោះក្លាយទៅជាកន្លែងមួយដែលផ្តល់កំដៅដល់ការកើនឡើងនៃកំដៅក្នុងពិភពលោកជាជាងការទប់បន្ថយកំដៅដែលវាធ្លាប់មាន ។

## ព្រៃដាំ

អ្នកគាំទ្រដល់ការកាប់ព្រៃឈើបានបង្ហាញថាព្រៃឈើជាធនធានក៏កើតឡើងវិញ ។ ករណីនេះវាជាការពិតប្រសិនបើការកាប់ឈើនោះធ្វើឡើងដោយមានការទទួលខុសត្រូវ គឺនៅពេលដែលដើមឈើត្រូវបានទុកឱ្យនៅសល់គ្រប់គ្រាន់សំរាប់ទ្រទ្រង់ដល់មូលដ្ឋានអេកូឡូស៊ី ហើយដោយទុកពេលវេលាគ្រប់គ្រាន់សំរាប់ព្រៃដុះឡើងវិញតាមលក្ខណៈធម្មជាតិរបស់វា ។ ទោះជាយ៉ាងណាក៏ដោយការដាំជំនួសព្រៃធម្មជាតិដែលបានត្រូវកាប់ហើយនោះគឺដូចជាជំនួសវត្ថុលំអរណាមួយដោយរបស់ជាតិប្លាស្ទិកដែលធ្វើសិប្បនិមិត្តដូចច្នោះដែរ ។ ជាទូទៅព្រៃដាំតែងតែត្រូវធ្វើឡើងក្នុងក្របខណ្ឌ័អភិវឌ្ឍន៍កសិកម្ម ដោយដាំតែឈើមួយប្រភេទសំរាប់ការប្រើប្រាស់ឈើជាលក្ខណៈពាណិជ្ជកម្ម ហើយដាំជាជួរ១ដោយគ្មានរុក្ខជាតិបន្ទាប់បន្សំ ដោយតាមពិតទៅរុក្ខជាតិបន្ទាប់បន្សំនោះត្រូវបានគេជំរះចេញ ឬ ក៏ប្រើថ្នាំកំចាត់ស្មៅដើម្បីបង្កើនការលូតលាស់នៃដើមឈើដែលគេដាំ ។ គេត្រូវការប្រើជីបន្ថែមដោយសារ

វាមានសារជាតិនៅសល់ក្នុងដីមានតិច តំរូវការសារជាតិដ៏ច្រើនរបស់ដើមឈើដែលដាំថ្មី និងការបង្ខំឱ្យវាអាចឆាប់ដល់អាយុដែលអាចទាញយកផលបានក្នុងរយៈពេលខ្លីបំផុតនោះ ។ ហើយក្រោយពីការខិតខំប្រឹងប្រែង និងការចំណាយទាំងនេះ ព្រៃឈើដាំតែឈើមួយប្រភេទនោះវារិតតែងាយរងគ្រោះដោយសារជម្ងឺផ្សេងៗជាងព្រៃធម្មជាតិដែលច្រើនប្រភេទទៅទៀត ។

ព្រៃដាំផ្តល់នូវផលិតផលបន្ទាប់បន្សំតិចតួចប៉ុណ្ណោះក្រៅពីផលិតផលចំបងរបស់វា ។ វាពុំមានធនធានសំរាប់អាហារ និងថ្នាំទេ វាបានផ្តល់នូវព្រៃរបោះ ឬ ជំរកសំរាប់សត្វតែពុំមានផ្តល់ឧសដុត ហើយដើមឈើប្រភេទខ្លះស្លឹកដែលជ្រុះមកនោះមិនបានផ្តល់ប្រយោជន៍ដល់ដីទេតែធ្វើឱ្យខូចដីទៅវិញ ។ ជីវចំរុះក្នុងព្រៃដាំគឺជាប្រភេទសិប្បនិមិត្តដែលអន់ជាងជីវចំរុះពិតប្រាកដ ។

ប្រហែលជាអ្វីដែលអាក្រក់ជាងនោះទៀតនោះគឺថា ព្រៃដាំមិនត្រូវការពលកម្មច្រើនដើម្បីថែរក្សា និងប្រមូលផលដូចព្រៃធម្មជាតិទេ ។ សហគន៍មូលដ្ឋានអាចធ្វើការនៅព្រៃដាំប៉ុន្តែការងារនោះពុំមានជាប់រហូត និងពុំគ្រប់គ្រាន់សំរាប់ទ្រទ្រង់គ្រួសារទេ ។ ដោយសារដីព្រៃដាំត្រូវធ្វើលើដីដែលធ្លាប់ជាប្រភពអាហារនោះ សហគមន៍មូលដ្ឋានតែងតែមានសភាពយ៉ាប់យឺនជាងមុនទៅទៀត ហើយដែលត្រូវខិតខំប្រឹងប្រែងរកចិញ្ចឹមជីវិតតាមរបៀបដែលអាចធ្វើឱ្យខូចខាតដល់បរិស្ថានដូចជាការរកឧស និងធ្វើកសិកម្មដោយដុតព្រៃក្នុងដំបន់ព្រៃធម្មជាតិ ។ ជាងនោះទៅទៀតការកែប្រែដីទៅជាដំណើរការធ្វើពាណិជ្ជកម្ម គឺវាអាចនាំឱ្យថយចុះនូវឥទ្ធិពលរបស់ប្រជាជនមូលដ្ឋានភាគច្រើន ។

## ព្រៃកោងកាង

ក្នុងឆ្នាំថ្មីៗកន្លងទៅនេះមានការថយចុះនូវព្រៃកោងកាងនៅតំបន់ឆ្នេរនៃដីសណ្តមេគង្គយ៉ាងខ្លាំង គឺភាគច្រើនមកពីការរានព្រៃធ្វើវារីវប្បកម្មជាលក្ខណៈពាណិជ្ជកម្ម ។ ការថយចុះនូវព្រៃកោងកាងនេះបាននាំឱ្យរលកទឹកពីសមុទ្របោកផ្ទាល់ទៅលើឆ្នេរដែលនាំឱ្យមានការដាច់ដី និងការជ្រាបចូលនៃទឹកជាតិអំបិលទៅក្នុងតំបន់ដីសណ្ត ។ ពពួកសត្វ និងត្រីដែលរស់ពឹងផ្អែកលើប្រពន្ធ័ឬសព្រៃកោងកាងសំរាប់ជាជំរក និងប្រភពចំណីអាហារត្រូវបានថយចុះ និងត្រូវបានជំនួសដោយរបរកសិកម្មទំនើប ។ ជាការល្អដែរ ដោយរបរកសិកម្មអាចជួយដល់ការអភិវឌ្ឍន៏សេដ្ឋកិច្ចដោយមានការប៉ះពាល់តិច និងអាចទទួលយកបានទៅលើប្រពន្ធ័អេកូឡូស៊ី ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយការប្រកបរបរកសិកម្មហួសប្រមាណបាននាំឱ្យមានការខូចខាតដល់បរិស្ថាន ដល់សត្វត្រី និងពពួកសត្វផ្សេងៗ ដោយសារសារជាតិគីមីថ្នាំពុល និងកាកសំណល់ត្រីងាប់ជាដើម ។

## ដីសើម

ដីសើមនៅក្នុងតំបន់អាងទន្លេមេគង្គបានផ្តល់នូវសេវាកម្មសំខាន់ៗជាច្រើនដូចជាអាងសំរួលដល់រំហូរទឹក ជាកន្លែងកំណើតសំរាប់ត្រី និងសត្វផ្សេងៗទៀត ជាជំរកសត្វស្លាប ល្ហូន ថនិកសត្វ និងជាគ្រឿងកាពារកុំឱ្យដីមានជាតិ

អាស៊ីត និងជាតិអំបិលច្រើន ។ ការបំបាត់នូវដីសើមបានកំពុងកើតមានឡើងនៅក្នុងពិភពលោកក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ទោះបីជាគេបានទទួលស្គាល់នូវការចូលរួមចំណែករបស់វាក្នុងប្រពន្ធ័អេកូឡូស៊ី និងបានចាត់វិធានការថែរក្សាវាយ៉ាងណាក៏ដោយ ។ ជីវចំរុះក្នុងប្រពន្ធ័ដីសើមគឺជាកត្តាមួយក្នុងចំណោមកត្តាសំខាន់ៗនៃប្រពន្ធ័អេឡូស៊ីទាំងអស់ ការបំបាត់នៅកត្តានេះដូចជានៅបឹងធំក្នុងប្រទេសកម្ពុជា ក្នុងតំបន់ដីសើមក្នុងក្រុងវៀងចន្ទ័នៃប្រទេសឡាវ (ដូចមានក្នុងការសិក្សាករណីនៃមេរៀននេះ) និងនៅវាលត្រែងនៅភាគខាងជើងនៃដីសណ្តទន្លេមេគង្គ នឹងនាំឱ្យមានការព្រួយបារម្ភយ៉ាងធំ ។

### ជលផល

ដូចជានៅក្នុងតំបន់ជាច្រើនទៀតក្នុងពិភពលោកដែរ គឺថាវាមានបញ្ហាត្រង់ថានៅក្នុងតំបន់អាងទន្លេមេគង្គនេះមានមនុស្សច្រើនដែលកំពុងនាំគ្នារកចាប់ត្រីដែលមានតិចនោះ ។ ការនេសាទហួសប្រមាណគឺជាសក្តិភាពមួយក្នុងបុព្វហេតុនៃកាថយចុះនៃចំនួនចាប់ត្រី ត្រូវបានគេកត់សំគាល់នៅក្នុងប្រពន្ធ័ទន្លេមេគង្គ ។ បឹងធំនៅប្រទេសកម្ពុជា និងអាងជលផល ណាំងឹម ក្នុងប្រទេសឡាវ គឺជាកាសិក្សាករណីដែលបានបង្ហាញ ។ ដំណោះស្រាយចំពោះបញ្ហានេះត្រូវបានគេគិតថាមានតែការកែលំអរនូវប្រពន្ធ័ច្បាប់ និងអនុវត្តន៏ច្បាប់ឱ្យបានជិតដល់ទេ ដែលករណីនេះវាងាយស្រួលនិយាយ ប៉ុន្តែការអនុវត្តន៏ពិតជាពិបាក ។ មូលហេតុមិនផ្ទាល់ផ្សេងទៀតដែលនាំឱ្យមានការថយចុះនូវទិន្នផល ត្រីគឺការបាត់បង់ជំរក ជាពិសេសព្រៃលិចទឹកនៅបឹងទន្លេសាប ព្រៃកោងកាងក្នុងដីសណ្តទន្លេមេគង្គ និងដីសើមក្នុងអាងទន្លេមេគង្គទាំមូល ។

ការប្រែប្រួលនូវគុណភាពទឹក និងរបបទឹកក្នុងប្រពន្ធ័ទន្លេមេគង្គបាននាំឱ្យមានលក្ខណៈមិនល្អថែមទៀតដល់ត្រី ។ ទំនប់នៅលើទន្លេ ធឿន និង ទន្លេ ងឹម នៃប្រទេសឡាវ និង ទន្លេ មូន នៃប្រទេសថៃ និង ទន្លេ សេសាននៅក្នុងប្រទេសកម្ពុជា និងប្រទេសវៀតណាម បានរារាំងដល់ការបំលាស់ទីរបស់ត្រី ហើយដែលរារាំងដល់ការបង្ករកំណើតនៃត្រីប្រភេទនោះដែលត្រូវពងនៅផ្នែកខាងលើនៃទំនប់នោះហើយត្រូវផ្លាស់ទីមកផ្នែកខាងក្រោមនៃទំនប់នោះវិញ ។ ទំហំធារទឹកនៅរដូវទឹកច្រើននៅក្នុងទន្លេទាំងនេះត្រូវបានកែប្រែហើយរបបទឹកតាមធម្មជាតិដែលសត្វនៅក្នុងទឹកតែងតែពឹងផ្អែកលើក្នុងដំណើរជីវិតរបស់វាត្រូវបានផ្លាស់ប្តូរ ។

ទឹកដែលហូរធ្លាក់ពីលើខ្នងទំនប់មានលក្ខគីមី និងកករវិលវល់ក្នុងទឹកខុសពីទឹកក្នុងទន្លេផ្ទាល់ ។ នៅក្រោមទំនប់នោះបន្តិច ទឹកអាចមានធាតុនីត្រូសែរ្សន និងអុកស៊ីសែរ្សនច្រើនហួសដោយសារតែវាមានការបោកក្ងចខ្យល់ និងទឹកនៅខាងក្រោមផ្លូវបង្ហៀរទឹកនោះ ។ សារជាតិរលាយ និងសារជាតិគីមីខ្លះបានធ្លាក់ចេញពីទឹក ឬ បានត្រូវប្រើប្រាស់ដោយដំណើការរូបសាស្ត្រនៅពេលដែលវានៅក្នុងអាងទឹក ធ្វើឱ្យទឹកដែលហូរចេញនោះមានគុណភាពអន់ ។ ហើយអង្គធាតុរឹងដែលនៅក្នុងទឹកអាងស្ងៀមនោះ តាមលក្ខណៈសមត្ថភាពរបស់វាបានធ្វើឱ្យមានលក្ខណៈឱណាមីកដែលតែងតែកើតមាននៅផ្នែកខាងក្រោមទំនប់នោះ ។ ការផ្លាស់ប្តូរនេះបានធ្វើឱ្យប្រែប្រួលនូវស្ថានភាពដែលត្រីធ្លាប់រស់នៅ គឺថាស្ថានភាពដែលវាធ្លាប់សាំនឹងការរស់នៅរបស់វា ។ ប្រភេទខ្លះអាចទ្រាំទ្របាន និង

ផ្លាស់ប្តូរតាមស្ថានភាពហើយខ្លះទៀតមិនអាចទ្រាំបានក៏ត្រូវបាត់បង់ ។ នៅកន្លែងផ្សេងទៀតនៃប្រពន្ធ័ទន្លេ ការកើតឡើងនូវការហូរកួច និងអង្គធាតុរឹងដោយសារការហូរច្រោះពីដីនៃព្រៃរិចរឹលបានរាំងដល់ការរកចំណីរបស់ត្រី និងមានការកកស្ទះដោយសារដីកករ ។

ការនេសាទខុសច្បាប់ និងការនាំមក ឬ ចិញ្ចឹមប្រភេទត្រីថ្មីផ្សេងៗទៀតគឺជាកាគំរាមគំហែងបន្ថែមដល់បរិមាណត្រីនៅក្នុងអាងទន្លេមេគង្គ ។ ការនេសាទខុសច្បាប់រួមមានការនេសាទដោយគ្មានការអនុញ្ញាតិនៅក្នុងតំបន់ហាមឃាត់ ឧទាហរណ៍ដូចជាការនេសាទក្នុងតំបន់ត្រួតពិនិត្យក្នុងបឹងទន្លេសាប និងការប្រើប្រាស់ឧបករណ៍ចាប់ត្រីខុសច្បាប់ ដូចជាការប្រើអគ្គិសនីឆក់ជាដើម (ឧ. ក្នុងបឹងធំនៃប្រទេសកម្ពុជា) និង ការប្រើថ្នាំបំពុលដែលសំលាប់យ៉ាងរង្គាលដល់សត្វក្នុងទឹកដែលមិនគ្រាន់តែចំពោះត្រីដែលគេចង់បាននោះទេ ។ ប្រភេទដែលនាំមកពីខាងក្រៅដែលដាក់ចូលទៅក្នុងអាងទឹក ឬ ប្រភេទដែលរត់ចេញពីការធ្វើវបរកសិកម្មអាចជាប្រភេទដែលគ្របដណ្តប់ក្នុងប្រព័ន្ធអេកូឡូស៊ីទឹក ហើយដែលធ្វើឱ្យបាត់ត្រីប្រភេទដើម ។ ប្រភេទត្រី ទីលាប់ផ្សា (O. nilotica) គឺជាឧទាហរណ៍មួយនៃត្រីមិនមែនពពួកដើមដែលមាននៅក្នុងអាងទន្លេ ជាពិសេសនៅក្នុងតំបន់ដីសណ្ត ។ វាជាប្រភេទដែលងាយបន្សាំ និងរស់នៅ ហើយដែលអាចជាគ្រោះថ្នាក់ដល់ប្រភេទក្នុងស្រុកមួយចំនួន ។

## ទំនប់

ផលប៉ះពាល់ខ្លះៗនៃទំនប់លើត្រីក្នុងអាងទន្លេមេគង្គមានរៀបរាប់ក្នុងផ្នែកខាងដើមរួចមកហើយ ។ ទំនប់ជួនកាលវាផ្តល់ផលល្អ ជួនកាលផលអាក្រក់ ដែលអាចប៉ះពាល់ដល់ធារទឹក និងពេលវេលានៅផ្នែកខាងក្រោមដោយសារការបញ្ចេញទឹកដើម្បីសមទៅតាមគោលបំណងរបស់គេ ដូចជាស្រោចស្រព វារីអគ្គិសនី ឬការការពារទឹកជំនន់ ។ ទំនប់នៅក្នុងអាងទន្លេមេគង្គជាទូទៅច្រើនតែសំរាប់វារីអគ្គិសនី ដូចនេះការស្តុក និងការបញ្ចេញទឹកច្រើនតែធ្វើទៅដើម្បីរក្សាឱ្យមានទឹកជាប់បន្តរសំរាប់ផលិតថាមពល ។ ក្នុងករណីនេះ ការប៉ះពាល់ទៅលើផ្នែកខាងក្រោមក្នុងទន្លេមេគង្គពុំមានទេ ប៉ុន្តែកសិកម្ម និងជលផលជាលក្ខណៈប្រពៃណី និងការប្រើប្រាស់ទន្លេនៅក្នុងតំបន់ផ្ទៃរងទឹកភ្លៀងនៃទំនប់ និងដៃទន្លេត្រូវទទួលរងផលប៉ះពាល់ ។

ផលប៉ះពាល់នៃការទប់ទំនប់ ដែលឃើញមានគឺ ការបំភាយនូវឧស្ម័នដូចជា មេតាន និងកាបូនឌីអុកស៊ីតចេញពីរុក្ខជាតិដែលលិចក្នុងទឹក ។ វារីអគ្គិសនីត្រូវបានគេយល់ថាជាជំរើសមួយដែលគ្មានបំពុលដល់បរិស្ថាន ក្នុងការផលិតថាមពល បើប្រៀបធៀប ទៅនឹងការប្រើប្រេងឥន្ធនៈ ប៉ុន្តែកាយល់ឃើញនេះពុំមានន័យទៀតទេ ។ ផលប៉ះពាល់ផ្សេងទៀតផ្នែកអាណារូបិក នៃអង្គធាតុសេរីរាង្គក្នុងអាងទឹកនឹងត្រូវពិភាក្សាក្នុងមេរៀនក្រោយ ។ ដើមឈើ និងព្រៃដែលដាំ ដែលមិនបានកាប់ ចេញនៅក្នុងអាងទឹកជាឧបស័គ្គដល់ការនេសាទ និងនាវាចរ ។

ទោះបីជានៅពេលឥឡូវនេះវាពុំមែនជាលទ្ធផលនៃទំនប់នៅក្នុងប្រព័ន្ធទន្លេមេគង្គក៏ដោយ វាអាចជាលទ្ធភាពនៃការជ្រាបចូលនៃទឹកជាតិអំបិលទៅក្នុងតំបន់ដីសណ្ត ប្រសិនបើរំហូរទឹកនៅទន្លេមេត្រូវថយចុះដែលជា

លទ្ធផលនៃការគ្រប់គ្រងរំហូរទឹកនៅផ្នែកខាងលើ ។ ការហូរចូលនៃជាតិអំបិលបន្ថែមទៀតនឹងនាំឱ្យប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ីនៅដីសណ្តទន្លេមេគង្គ និងធ្វើឱ្យខូចខាតដល់គុណភាពដីតំបន់ដាំដំណាំ ។

ផលប៉ះពាល់សំខាន់ៗនៃការធ្វើទំនប់គឺផលប៉ះពាល់វាទៅលើសហគមន៍ដែលរស់នៅក្នុងតំបន់គោលដៅគឺផ្នែកខាងលើទំនប់កន្លែងដែលត្រូវលិចទឹកក្នុងអាង នៅតំបន់ជិតទំនប់ និងសំណង់សំរាប់ផលិតអគ្គិសនី ឬក៏នៅតំបន់ជិតៗនៃខ្សែទឹកខាងក្រោមនៃអាង ។ តាមលក្ខណៈអេកូឡូស៊ី ផលប៉ះពាល់ទៅលើមនុស្សដោយការអភិវឌ្ឍន៍ទាំងនេះយ៉ាងហោចណាស់គឺមានទៅលើ សត្វព្រៃ ត្រី និងសត្វផ្សេងទៀត ។ ជាលទ្ធផលនៃការផ្លាស់ទីលំនៅរបស់ប្រជាជនដើម្បីធ្វើផ្លូវចូលទៅទំនប់ ជាទូទៅច្រើនធ្វើឱ្យសហគមន៍ចុះខ្សោយ និងក្រីក្រ ។ ការពិភាក្សាបន្ថែមលើបញ្ហានេះនឹងត្រូវរៀបរាប់ក្នុងមេរៀនផ្នែក ទី៦ នៃមេរៀននេះ ។

## ការស្រោចស្រព

ចំពោះកសិកម្ម ការស្រោចស្រពគឺជា សារៈសំខាន់មួយ តែបើធ្វើមិនបានត្រឹមត្រូវទេវាអាចជាមហន្តរាយមួយទៅវិញ ។ ការស្រោចស្រពនៅតំបន់ផ្នែកខាងលើអាចធ្វើឱ្យថយចុះនូវរំហូរទឹកនៅផ្នែកខាងក្រោម ហើយបង្អត់ដល់សហគមន៍ដែលនៅផ្នែកខាងក្រោមនៃអាងទន្លេ ក្នុងន័យនៃការផ្គត់ផ្គង់ស្មើគ្នា ។ នៅពេលដែលមានទឹកលិចជាប្រចាំដោយសារការស្រោចស្រព សារជាតិអំបិលនៅក្នុងដីអាចជ្រាបចេញមកផ្ទៃដីខាងលើ ដែលនាំឱ្យខូចដល់គុណភាពដី ។ ផលប៉ះពាល់ដូចគ្នានេះដែរអាចកើតមានប្រសិនបើកំពស់ទឹកក្រោមដីឡើងជិតដល់ផ្ទៃដីខាងលើដោយសារការស្រោចស្រពច្រើនពេក ។ ការសង្កេតពិនិត្យក៏បានបង្ហាញភាពពិតដែរគឺថា ការប្រើប្រាស់ទឹកក្រោមដីហួសប្រមាណសំរាប់ការស្រោចស្រពអាចនាំឱ្យមានការខូចខាតដល់ធនធាន កំពស់ទឹកក្រោមដីកាន់តែជ្រៅ និងបង្កើននូវជាតិអំបិលក្នុងទឹកក្រោមដី ។

ការស្រោចស្រពសំរាប់កសិកម្មជាទូទៅតែងតែមានការប្រើប្រាស់ជី និងថ្នាំសំលាប់សត្វល្អិត ។ ចំនួនដ៏ច្រើននៃសារជាតិទាំងនេះអាចូលទៅក្នុងទឹកហូរដែលស្រោចស្រពនោះហើយហូរចាក់ទៅទន្លេក្បែរនោះ ដែលធ្វើឱ្យគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់នៅខ្សែទឹកខាងក្រោម និងអាចប៉ះពាល់ដល់ជីវិតសត្វក្នុងទឹក ។ ការសិក្សាករណីនៅដីសណ្តទន្លេមេគង្គ និងនៅបឹងធំក្នុងប្រទេសកម្ពុជាបានពិនិត្យលើបញ្ហានេះ ។

រួមជាមួយនឹងសារជាតិគីមីនៅក្នុងរំហូរទឹក គឺមានដីដែលហូរដាច់ពីតំបន់ដាំដំណាំដែលនាំឱ្យមានកករកាន់តែច្រើននៅក្នុងរំហូរទឹកហើយដែនាំឱ្យប៉ះពាល់ដល់ជំរកសត្វក្នុងទឹក ។ ការសាងសង់សំណង់ធារាសាស្ត្រមិនត្រឹមត្រូវនៅតំបន់ភ្នំអាចនាំឱ្យមានការដាច់ជើងភ្នំ និងបាក់ដី ដែលនាំឱ្យកើតឡើងនូវកករដី និងអាចប៉ះពាល់ដល់ជីវិតមនុស្ស ។

ការស្តុកទឹកក្នុងអាងសំរាប់ស្រោចស្រព គ្រប់គ្រងទឹកជំនន់ ឬសំរាប់ផលិតថាមពលនាំឱ្យមានការហួតបាត់ទៅក្នុងបរិយាកាស ។ នៅក្នុងតំបន់អាកាសធាតុក្តៅធារទឹកអាចហួតរហូតដល់ ៧% នៃធារទឹកក្នុងអាង ដែលនាំឱ្យ

កើត ឡើងនូវសារជាតិរឹងនៅសល់ក្នុងអាង ហើយក៏អាចនាំឱ្យកើនឡើងនូវជាតិអំបិលក្នុងដីប្រសិនបើទឹកនោះត្រូវប្រើសំរាប់ស្រោចស្រព ។

## ការធ្វើនគរូបនីយកម្ម

ផ្ទុយពីបំណងក្នុងការបង្កើននូវស្ថានភាពរស់នៅរបស់មនុស្សនៅតំបន់ជនបទ ផែនការអភិវឌ្ឍន៍ ជួនកាលអាចនាំឱ្យមានការផ្លាស់ទីតាំងពីទីជនបទទៅទីក្រុងធំៗដែលមានមនុស្សច្រើនលើលប់ និង អាចមានការឈឺចាប់ច្រើនទៀត ។ ហេដ្ឋារចនាសម្ព័ន្ធនៃទីក្រុងធំៗបំផុតនៅអាស៊ីអាគ្នេយ៍ត្រូវបានប្រើប្រាស់ដោយមនុស្សជាច្រើន ដែលបានសំរុកចូលទៅពីទីជនបទ ។ ប្រពន្ធ័អេកូឡូស៊ីនៃទីក្រុងវាជារឿងមួយរបស់វា ប៉ុន្តែយើងអាចនិយាយបានថាវាមានមនុស្សច្រើនហួសប្រមាណ ខ្វះការផ្គត់ផ្គង់ទឹក មានការបោះកាកសំណល់ចោលច្រើន ការបំពុលបរិយាកាសពីរោងចក្រផ្សេងៗ និងពីយានយន្ត សុខភាពសារធារណៈមិនល្អ មានអ្នកអត់ការងារធ្វើ និង ផលិតកម្មទាបបើប្រៀបធៀបទៅនឹងជីវិតនៅទីជនបទ ការបាត់បង់វប្បធម៌ប្រពៃណី មានឧក្រិដ្ឋកម្ម និងបាត់បង់ភាពថ្លៃថ្នូរទាំងនោះគឺជាសក្ខីភាពនៃការបាត់បង់នូវស្ថេរភាពនៃប្រពន្ធ័អេកូឡូស៊ី ។ ប្រជាជនដែលរស់នៅទីក្រុងធំៗគឺត្រូវបានកាត់ផ្តាច់ពីដំណើរការនៃប្រពន្ធ័អេកូឡូស៊ីធម្មជាតិ ទោះបីជាចលនានៃប្រពន្ធ័អេកូឡូស៊ីនៅតែមានអនុវត្តន៍នៅទីនោះក៏ដោយ វាអនុវត្តន៍ទៅតាមរបៀបដែលមិនមានមុខងារល្អ ។

## ប្រពន្ធ័ច្បាប់ និងការិយាធិបតេយ្យ

ប្រពន្ធ័អេកូឡូស៊ីមួយមិនមែនជាបណ្តុំនៃផ្នែកផ្សេងៗដែលអនុវត្តន៍ដោយដាច់ឡែកពីគ្នាទេ ដូចដែលប្រទេសជាច្រើនបានកំពុងគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិរបស់ខ្លួននោះទេ ព្រោះថាគ្រប់ផ្នែកទាំងអស់នៃប្រពន្ធ័អេកូឡូស៊ីគឺត្រូវពឹងផ្អែកគ្នាទៅវិញទៅមក ហើយការប៉ះពាល់ដល់ផ្នែកណាមួយវាអាចនាំឱ្យប៉ះពាល់ដល់ប្រពន្ធ័ទាំងមូល ។ ការចាត់ទុកក្របខណ្ឌ័នៃផ្នែកនីមួយៗដូចជាប្រអប់ដាច់ដោយឡែកពីគ្នានោះ អាចនាំឱ្យមានការត្រួតស៊ីគ្នានូវការទទួលខុសត្រូវរវាងស្ថាបន័ផ្សេងៗរបស់រដ្ឋាភិបាល មានការលុបចោលនូវផ្នែកសំខាន់ៗ មានជំលោះ និងមានការប្រកួតប្រជែង ពុំមានប្រសិទ្ធភាពក្នុងការគ្របគ្រងច្បាប់ និងបញ្ញត្តិផ្សេងៗដែលបានរៀបចំឡើងក្នុងវង្វង់ក្របខណ្ឌ័ជាមូលដ្ឋាននេះ ។ ដូចនេះភ្នាក់ងាររដ្ឋាភិបាលដែលទទួលខុសត្រូវលើ ត្រី កសិកម្ម ព្រៃឈើ ថាមពល ធនធានទឹក ទេសចរណ៍ ឧស្សាហកម្ម បរិស្ថាន និងវិស័យផ្សេងៗទៀត ត្រូវទំនាក់ទំនងគ្នាហើយធ្វើការឱ្យសមស្របទៅតាមផ្លូវដែលពិភពលោកទាំងមូលកំពុងអនុវត្តន៍ និង បង្កើននូវធនធានដែលមានកេរិតរបស់ខ្លួន ។ ការបង្ហាញថាតើបញ្ហានេះគួរត្រូវដោះស្រាយយ៉ាងណានឹងមានរៀបរាប់ក្នុងការសិក្សាករណីលើតំបន់បរិយ៍ជីវមណ្ឌលព្រែកទាល់នៃប្រទេសកម្ពុជា ។

ប្រធានបទដែលទាក់ទងលំអិតក្នុងមេរៀនទី ៣ (គោលការណ៍ អភិវឌ្ឍន៍ដោយនិរន្តរភាព) គឺជាមូលដ្ឋាននៃភាពមិនស្មើគ្នាក្នុងកម្មសិទ្ធដី និងទ្រព្យសម្បត្តិ ។ នៅក្នុង ប្រទេសកំពុងអភិវឌ្ឍន៍ កម្មសិទ្ធដី គឺជារបស់បុគ្គល

មួយចំនួនតូច ប៉ុន្តែត្រូវធ្វើការដោយមនុស្សជាច្រើន ។ ស្ថានភាពនេះគឺពុំមានលក្ខណៈស្ថេរភាពផ្នែកអេកូឡូស៊ីទេ ។ ហើយតាមពិតទៅការបែងចែកទ្រព្យសម្បត្តិនៅទូទាំង ពិភពលោកនេះពុំមានលក្ខណៈស្មើភាព និងនិរន្តរភាពទេ ។

## អត្តចរិត និងជំនឿ

អត្តចរិតរបស់យើងចំពោះបរិស្ថាន និងធម្មជាតិ ជាទូទៅបានវិវត្តន៍ទៅតាមពេលវេលាដែលជាលទ្ធផលនៃជំនឿ វប្បធម៌ និងការឱ្យតំលៃផ្សេងគ្នារបស់យើង ។ នៅក្នុងតំបន់ជាច្រើននៃពិភពលោកនេះ គេជឿថាធម្មជាតិកើតមានឡើងគឺសំរាប់មនុស្សគ្រប់គ្រង និងប្រើប្រាស់ដោយពុំគិតពីសុខមាលភាពរបស់ធម្មជាតិទេ ។ អត្តចរិតនេះទោះបីជាវាមិនមានទូទៅក៏ដោយ វាបាននាំឱ្យមានកាធ្វើអាជីវកម្មហួសប្រមាណនាពេលបច្ចុប្បន្ន នាំឱ្យមានការរេចរិល និងក្រខ្វក់ដល់ប្រភពធនធានជាច្រើន និងនាំឱ្យមានការបាត់បង់ខ្លះ ។

ជាង ១៥ ឆ្នាំកន្លងមកនេះគឺមានការចាប់ផ្តើមយល់ឃើញថាធនធានលើផែនដីយើងនេះមានកំរិត ហើយដែលអាចឱ្យគេផ្លាស់ប្តូរចិត្តពីការប្រមូលយក និងប្រើប្រាស់ ទៅជាកាចែកចាយ និងថែរក្សាធនធាន និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពវិញ ។ គេបានពិនិត្យឃើញថាគ្មានផ្លូវណាផ្សេងក្នុងការទ្រទ្រង់ជីវិតទេ ។ ផ្លូវដែលបានដើរកន្លងមកអាចនាំឱ្យឈានដល់ការបាត់បង់ធនធានធម្មជាតិ និងមនុស្ស ។

គោលគំនិតនៃការរៀបចំឡើងវិញគឺថា ការប្រើប្រាស់ដោយមនុស្សមួយចំនួនតូចតាមរយៈការចំណាយរបស់មនុស្សច្រើននោះត្រូវបញ្ឈប់ ហើយត្រូវជំនួសដោយសីលធម៌ត្រឹមត្រូវមួយផ្អែកលើគោលគំនិតដែលធ្វើឱ្យមានស្ថេរភាពនៃប្រភពធនធាន និងបង្កើតនូវការអភិវឌ្ឍន៍សំរាប់មនុស្សទូទៅ ។

## សង្ខេបចំណុចសំខាន់ៗ

- បរិស្ថារួមមាន ខ្យល់ ទឹក ដី រ៉ែ ថាមពលព្រះអាទិត្យ រុក្ខជាតិ សត្វ មីក្រូសរីរាង្គ មនុស្ស និងរចនាសម្ព័ន្ធរបស់មនុស្ស ។
- ប្រពន្ធ័អេកូឡូស៊ី គឺជាចលនាលើគ្នាទៅវិញទៅមក និងទាក់ទងគ្នារវាងផ្នែកនីមួយៗក្នុងបរិស្ថាន និងការហូរ និងបំលែងថាមពលរវាងផ្នែកទាំងនោះ ។
- ព្រន្ធ័អេកូឡូស៊ីដែលមានសុខភាពល្អអាចមានស្ថេរភាពដោយខ្លួនឯង ហើយបានបង្កើតនូវទ្រនាប់ការពារ ប៉ុន្តែអាចងាយបំពុល និងបំផ្លាញដោយសារអន្តរាគមន៏របស់មនុស្ស ។
- ផ្នែកផ្សេងៗនៃបរិស្ថាននៅក្នុងអាងទន្លេមេគង្គត្រូវបានរិចរិល ខ្វះខាត និងក្នុងករណីខ្លះត្រូវបានបំផ្លាញដោយសារសកម្មភាពរបស់មនុស្ស ។ ឧទាហរណ៏ដូចជា ព្រៃឈើ ជលផល កសិកម្ម និង ផ្ទៃទន្លេ ។
- ចាំបាច់ត្រូវមានទិសដៅ និងផែនការថ្មីដើម្បីផ្លាស់ប្តូរនូវវិធីសាស្ត្រអភិវឌ្ឍន៏ក្នុងការធ្វើឱ្យមានស្ថេរភាព និងការចែកចាយផលប្រយោជន៏ស្មើៗគ្នាពីការប្រើប្រាស់ធនធានធម្មជាតិ ។

# គោលការណ៍នៃការអភិវឌ្ឍន៍ដោយនិរន្តរភាព

~~~~~~~

## មូលដ្ឋានគ្រឹះនៃការអភិវឌ្ឍន៍ដោយនិរន្តរភាព

ពាក្យអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពបានប្រើយ៉ាងទូលំទូលាយក្នុងរបាយការណ៍ឆ្នាំ ១៩៨០ ស្តីពីយុទ្ធសាស្ត្រសំរាប់អភិរក្សពិភពលោកដែលរួមគ្នាធ្វើឡើងដោយអង្គការ IUCN (សហភាពអន្តរជាតិដើម្បីថែរក្សាធម្មជាតិ និងធនធានធម្មជាតិ) UNEP (កម្មវិធីបរិស្ថានសហប្រជាជាតិ) និងអង្គការ WWF (មូលនិធិពិភពលោកដើម្បីធម្មជាតិ) ។ ពាក្យនេះក្រោយមកត្រូវបានសំរេចថាជាពាក្យសំខាន់មួយក្នុងរបាយការណ៍ឆ្នាំ ១៩៨៧ ដែលមានចំណងជើងថា "អនាគតរបស់យើងទាំងអស់គ្នា" ដែលធ្វើឡើងដោយអង្គការគណៈកម្មការពិភពលោក ស្តីពីបរិស្ថាន និងការអភិវឌ្ឍន៍ ដែលគេស្គាល់ជាទូទៅឈ្មោះ "របាយការណ៍ ប្រាន់ឡែន" ក្រោយពីប្រធានរបស់គណៈកម្មាធិការគឺលោកស្រី **ហ្គ្រោហារលែម ប្រាន់ឡែន** ដែលជានាយករដ្ឋមន្ត្រីនៃប្រទេស ន័រវ៉េ នៅពេលនោះ ។ គណៈកម្មការត្រូវបានបង្កើតឡើងដើម្បីរៀបចំកម្មវិធីពិភពលោកមួយ ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរ ដោយធ្វើការពិនិត្យមើលលើបញ្ហាបរិស្ថាន សេដ្ឋកិច្ច និងសង្គម ក្នុងវេទិកាសាធារណៈមួយដែលត្រូវប្រារព្ធឡើងជាបន្តបន្ទាប់នៅជុំវិញពិភពលោក ។

## និយមន័យនៃការអភិវឌ្ឍន៍ដោយនិរន្តរភាព

ទោះបីជាពាក្យអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពត្រូវបានប្រើយ៉ាងទូលំទូលាយក៏ដោយ គោលគំនិតនៃពាក្យនេះគឺពិបាកបញ្ជាក់ និងពន្យល់ឱ្យច្បាស់លាស់ណាស់ ។ សំរាប់ការលូតលាស់សេដ្ឋកិច្ច និងភាពរុងរឿង ការអភិវឌ្ឍន៍ដោយនិរន្តរភាពគឺពោលដល់សុទ្ធិដ្ឋិនិយមដែលភាពប៉ិនប្រសព្វរបស់មនុស្ស និងគោលបំណងត្រូវតែជំនះលើឧសគ្គទាំងឡាយនៅពេលដែលវាកើតមាន ។ ពាក្យនេះជាទូទៅគឺមិនសូវល្អសំរាប់ផ្នែកជំនួញទេនៅពេលដែលមនុស្សកំពុងតែនាំគ្នាសំរុកបំផ្លិចបំផ្លាញធនធាននៅលើដីយើងនេះ ។

និយមន័យដែលតែងតែប្រើចំពោះពាក្យអភិវឌ្ឍន៍ដោយនិរន្តភាពតាមរបាយការណ៍ ប្រ៉ាន់ឡែន គឺជាលក្ខណៈបំផុសគំនិតមួយ ប៉ុន្តែមិនមែនជាជំនួយដល់ការធ្វើផែនការយុទ្ធសាស្ត្រ និងគោលបំណងដែលបានកំនត់នោះទេ ។

## ការបរិយាយខ្លីៗស្តីអំពីការអភិវឌ្ឍន៍ដោយនិរន្តរភាព

តាមការអនុវត្តន៍ ទោះជាវាភាគច្រើនឋិតក្នុងផ្នែកនយោបាយ និងទស្សនៈវិស័យក៏ដោយ នោះគឺគោលការណ៍ទាំង ២៧ សំរាប់ការអភិវឌ្ឍន៍ដោយនិរន្តរភាព ដែលមាននៅក្នុងផែនការសកម្មភាពដែលគេស្គាល់ថា
~~~~~~~

ជាកម្មវិធីAgenda 21 (ដែលជាចំណងជើង គឺកម្មវិធីសំរាប់សតវត្សទី ២១) ដែលបានដកស្រង់ដើម្បីធ្វើការអនុម័ត នៅពេលប្រជុំកំពូលស្តីពីបញ្ហាផែនដីនៅសន្និសិទ្ធអង្គការសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍន៍ (UNCED) នៅទីក្រុង Rio de Janerio ។ គ្រប់គោលការណ៍ទាំងអស់គឺអាចអនុវត្តន៍ក្នុងករិតណាមួយចំពោះបញ្ហាក្នុងអាងទន្លេមេគង្គ (MRB) ប៉ុន្តែប្រធានបទខាងក្រោមនេះជាចំណុចដែលទាក់ទងពិសេស :

- ការកាត់បន្ថយភាពក្រីក្រ
- របៀបប្រើប្រាស់របស់មនុស្ស
- ស្ថានភាពប្រជាជន និងទីលំនៅ
- សុខភាពមនុស្ស
- ជីវចំរុះ
- ធនធានទឹកសាប និងទឹកសមុទ្រ
- តំបន់ភ្នំ
- កសិកម្ម និងការអភិវឌ្ឍន៍ជនបទ
- សំណល់ និងសារធាតុគីមីគ្រោះថ្នាក់
- ការការពារបរិយាកាស
- ស្ត្រី កុមារ និងយុវវ័យ
- ប្រជាជនអន្តោប្រាម
- ក្របខ័ណ្ឌច្បាប់ និងស្ថាប័ន

## និយមន័យនៃការអភិវឌ្ឍន៍ដោយនិរន្តរភាព

ការអភិវឌ្ឍន៍ដែលស្របតាមតម្រូវការបច្ចុប្បន្ន ដោយពុំមានប៉ះពាល់ដល់លទ្ធភាពដែលផ្តល់នូវតម្រូវការរបស់មនុស្សជំនាន់ក្រោយ ។

គណៈកម្មាការប្រ៊ុនឡែន : អនាគតរបស់យើង

## គោលបំណងរបស់ការអភិវឌ្ឍន៍ដោយនិរន្តរភាព

ដើម្បីឱ្យបុគ្គលម្នាក់ៗអាចរស់នៅដោយពេញលេញតាមការអភិវឌ្ឍន៍ផ្នែកស្មារតី គំនិត និងរូបសាស្ត្ររបស់គេ ។

កម្មវិធី Agenda 21; កិច្ចប្រជុំកំពូលស្តីពីផែនដី

## គោលការណ៍របស់ការអភិវឌ្ឍន៍ដោយនិរន្តរភាព

សង្គមដែលប្រកបដោយនិរន្តរភាពដែលអាចឱ្យសមាជិករបស់ខ្លួនសំរេចបាននូវជីវិតរស់នៅប្រកបដោយគុណភាពខ្ពស់តាមរបៀបដែលមានលក្ខណៈស្ថេរភាពដល់ព្រន្ធ័អេកូឡូស៊ី ។

អង្គការសហប្រជាជាតិ

ចំណងទាក់ទងដែលមិនអាចកាត់ផ្តាច់ពីគ្នាបាននៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ ការកើនឡើងនូវចំនួនប្រជាជន សុខភាពមនុស្ស សិទ្ធមនុស្ស និងការអភិរក្សបរិស្ថានត្រូវបានបង្កើតឡើងតាមរយៈគោលកាណ៍កម្មវិធី Agenda 21 ។ ពុំមានបញ្ហាណាមួយអាចត្រូវដោះស្រាយបានដោយពេញលេញទេ ប្រសិនបើមិនបានដោះស្រាយបញ្ហាផ្សេងៗទៀតនោះ ដោយសារបញ្ហានីមួយៗគឺជាផ្នែករួមរបស់ប្រព័ន្ធសេដ្ឋកិច្ច-សង្គមរបស់មនុស្ស ។ ឧទាហរណ៍ដូចជាការសាងសង់ទំនប់នៅភាគខាងជើងប្រទេសឡាវ ដើម្បីទទួលផលចំណូលពីការលក់ថាមពលទៅប្រទេសជិតខាងអាចនាំឱ្យមានការចំណាយលើការជំលៀសប្រជាជនក្នុងសហគមន៍ ការកាប់ឆ្ការព្រៃ និងបាត់ដីដាំដំណាំដែលយើងមិនបានគិតទុក និងមិនចង់ឱ្យកើតមាននៅកន្លែងដែលត្រូវសង់ទំនប់ និងអាងទឹកនោះ ហើយនិងមានការប៉ះពាល់ដល់រំហូរទន្លេក្នុងផ្នែកខាងក្រោម ជលផល ដីសើម និងមានការ

ជ្រាបចូលនូវទឹកជាតិអំបិលទៅក្នុងដីសណ្ដមេគង្គ ហើយដែលអាចបណ្ដាលឱ្យខូចខាតដល់សុខភាពប្រជាជនដែលរស់នៅ និងពឹងផ្អែកលើប្រភពធនធានទាំងនេះ ។

វិធីសាស្ត្របច្ចេកទេសបានមានបំណងចង់ដោះស្រាយបញ្ហាទាំងនោះដាច់ដោយឡែកពីគ្នា ។ ការទាក់ទងគ្នាទៅវិញទៅមកនៃបញ្ហានិមួយៗអាចត្រូវបំភ្លេចក្នុងការប្រើវិធីសាស្ត្រនេះ ហើយដំណោះស្រាយទៅលើតែផ្នែកណាមួយនៃបញ្ហានោះវាអាចបង្កើតឱ្យមានបញ្ហានៅត្រង់កន្លែងមួយផ្សេងទៀត ។

ដោយគិតតំលៃខាងក្រៅនៃការខូចខាតរួមគ្នានៃការអភិវឌ្ឍន៍ទំនប់ បានបង្ហាញនូវផលវិបាកនៃការគិតគូរតែទៅលើបញ្ហាបន្ទាន់តែប៉ុណ្ណោះ ។ ការគិតគូរដល់ប្រពន្ធ័រួម ហើយនិងការអនុវត្តន៍ឱ្យស្របគ្នាគឺជាកត្តាចាំបាច់ក្នុងការជៀសវាងការប្រើរបៀបឧស្សាហកម្មដែលផ្តោតលើតែលក្ខណៈវិស្វកម្មនោះ ។ ត្រូវយកបញ្ហាប្រជាជនមកគិតគូរជាធំនោះជាតំរូវការដែលត្រូវធ្វើដូចដែលគណៈកម្មាការទន្លេមេគង្គ (MRC) បានធ្វើក្នុងផែនការយុទ្ធសាស្ត្ររបស់ខ្លួន ។ ការគ្រប់គ្រងធនធានលើផែនដី និងបញ្ហាធំៗផ្សេងទៀតដូចជាភាពក្រីក្រ និង សុខភាពដោយដាក់វាដាច់ៗពីគ្នាគឺបានន័យថាយើងមិនបានយល់ដល់ភាពទាក់ទងគ្នាទៅវិញទៅមករបស់វាទេ ។

## ភាពក្រីក្រ ការស្រេកឃ្លាន បរិស្ថាន និងការអភិវឌ្ឍន៍

យោងតាមអង្គការ UNEP លក្ខណ្ឌ័ចំបងរបស់ការអភិវឌ្ឍន៍ដោយនិរន្តភាពនោះគឺថាតើវាបានបំពេញនូវសេចក្តីត្រូវការរបស់អ្នកដែលបានទទួលផលប្រយោជន៍តិច និងងាយរងគ្រោះក្នុងសង្គមដែរឬទេ ។ ពួកគេទាំងនោះច្រើនតែជាអ្នកមានចំណូលតិច កុមារ ស្ត្រី និងប្រជាជនមូលដ្ឋាន ។ ប្រជាជនក្រីក្រព្រួយបារម្ភជាពិសេសទៅលើការរស់នៅប្រចាំថ្ងៃរបស់ខ្លួន គឺមិនមែនសំរាប់ការថែរក្សាធនធានរយៈពេលវែងនោះទេ ។ ប្រសិនបើការអភិវឌ្ឍន៍បានបំបាត់នូវប្រភពចំណីអាហារ និងជំរកដែលចាំបាច់ផ្ទាល់របស់ពួកគេ ដោយពុំបានធ្វើសំណងទូទាត់ឱ្យបានគ្រាប់គ្រាន់ទេនោះ ប្រជាជនក្រីក្រនឹងត្រូវទៅរកប្រភពចំណីអាហារនៅកន្លែងដែលអាចរកបានថ្មីទៀត ដោយពុំគិតអំពីផលប៉ះពាល់បរិស្ថានពីសកម្មភាពរបស់គេឡើយ ។

គឺជាការមិនសមសោះដែលប្រជាជនក្រីក្រគឺជាអ្នកទទួលរងគ្រោះជាងគេ ពីការខូចខាតបរិស្ថានតាមរយៈទឹកផ្គត់ផ្គង់ដែលក្រខ្វក់ និងខ្វះអនាម័យ ការដែលត្រូវរស់នៅកន្លែងដែលទទួលរងផលប៉ះពាល់ច្រើន កន្លែងងាយរងគ្រោះដោយការបាក់ដី ឬទឹកជំនន់ កន្លែងដែលមានមនុស្សច្រើនហួស និងកន្លែងដែលមានឧស្ម័នពុកស៊ីចមកពីឧស្សាហកម្ម ។ ដោយសារតែគេត្រូវពឹងផ្អែលលើអាហារ និងថាមពលក្នុងមូលដ្ឋាន ប្រជាជនក្រីក្រនឹងត្រូវរងគ្រោះខ្លាំងជាងគេ ប្រសិនបើប្រភពផ្គត់ផ្គង់ទាំងនោះត្រូវបាត់បង់ដោយសារសកម្មភាពអភិវឌ្ឍន៍ ។ សមាជិកដែលមានទ្រព្យសម្បត្តិច្រើនក្នុង សង្គមអាចទិញផលិតផលនាំចូលមកពីតំបន់ផ្សេងទៀត ដូចនេះពួកគេមិនទទួលរងគ្រោះខ្លាំងទេ ។ ក្នុងករណីនេះ គំលាតរវាងអ្នកមាននឹងអ្នកក្រត្រូវបានកើនឡើង ដែលវាជាការ

ភិវឌ្ឍន៍សេដ្ឋកិច្ចសំរាប់អ្នកមួយចំនួនហើយជា បច្ច័យអាក្រក់សំរាប់អ្នកផ្សេងទៀត ហើយការខូចខាតបរិស្ថាន នឹងកើតមានជាបន្តបន្ទាប់ ។

ម្យ៉ាងទៀត ការការពារទប់ទល់នឹងការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រាន់តែដើម្បីការពារ បរិស្ថានដោយពុំគិតដល់ការតស៊ូចំពោះភាពក្រីក្រនោះ គឺពិតជាការដែលពុំមានមនសិកាទេ ។

កត្តាសំខាន់គឺការប្រើធនធានធម្មជាតិដោយមានប្រសិទ្ធភាព ឧទាហរណ៍ ដូចជា ដោយឱ្យមានកាកសំណល់តិចបំផុតដើម្បីធានាថាអ្នកដែលបានទទួលផលប្រយោជន៍ពីការអភវឌ្ឍន៍នោះត្រូវតែចំណាយប្រាក់ ហើយអ្នកដែលត្រូវលះបង់ ឬចំណាយដើមទុន (ឧទាហរណ៍ បាត់បង់ដីធ្លី និងប្រពៃណី) អាចចូលរួមក្នុងការសំរេចចិត្ត និងបានទទួលចំណែកស្មើគ្នាដូចសមាជិកពាក់ព័ន្ធទាំងអស់ដែរ ។ ការធ្វើអាជីវកម្មលើបរិស្ថាន ឬប្រជាជនក្រីក្រតាមរយៈការអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលធ្វើឡើងដោយអ្នកមានអំណាចនោះគឺជាកាគិតខ្លី និងមានលក្ខណៈជាការបណ្តុះពូជដើម្បីបំផ្លាញខ្លួនឯង ។

## ផ្នែកផ្សេងៗនៃបរិស្ថានក្នុងការអភិវឌ្ឍន៍ដោយនិរន្តរភាព

ធនធានទឹកនៅក្នុងអាងទន្លេមេគង្គ គឺជាសក្ខីភាពមួយបញ្ជាក់ពីការជាប់ទាក់ទងគ្នា ។ ការអភិវឌ្ឍន៍ដោយនិរន្តរភាព ការកាត់បន្ថយភាពក្រីក្រ និងការបង្កើនសុខភាពសាធារណៈមិនអាចធ្វើទៅបានទេបើគ្មានការផ្គត់ផ្គង់ទឹកសាបដែលមានគុណភាពល្អគ្រប់គ្រាន់នោះ ។ ដើម្បីធានាដល់ការផ្គត់ផ្គង់នោះ ធារាសាស្ត្រក្នុងអាងទន្លេមេគង្គត្រូវតែគ្រប់គ្រងជាប្រព័ន្ធពេញលេញមួយគឺមិនមែនតែក្នុងព្រំដែនប្រទេសនីមួយៗ ឬផ្ទៃរងទឹកភ្លៀងណាមួយទេ ។ សុខភាពរបស់ប្រព័ន្ធអេកូឡូស៊ីទឹកពឹងផ្អែកទៅលើក្របខណ្ឌនៃគោលបំណង ផែនការ និងការអនុវត្តន៍ក្នុងអាងទន្លេទាំងមូល ។ តួនាទីរបស់ MRC គឺមានសារៈសំខាន់ណាស់ក្នុងគោលបំណងនេះ ។

## ការយល់ដឹងពីបរិស្ថាន

ជំហានចាំបាច់ដំបូងក្នុងការណែនាំនូវអត្តចរិតដែលត្រូវផ្លាស់ប្តូរសំរាប់ទៅរកការអភិវឌ្ឍន៍ដោយនិរន្តរភាពនោះគឺការបង្កើតឱ្យមានការយល់ដឹងក្នុងគ្រប់ផ្នែកអភិវឌ្ឍន៍ដែលជាតំណាងរបស់រដ្ឋាភិបាល សាធារណៈទូទៅ និងសហគមន៍គោលដៅសំរាប់សកម្មភាពអភិវឌ្ឍន៍ណាមួយនោះ ។ ពត៌មាន ការបណ្តុះបណ្តាល និង ការចូលរួមរបស់សាធារណៈក្នុងការសំរេចចិត្តទាក់ទង និងការអភិវឌ្ឍន៍ និងហេតុប៉ះពាល់របស់វាលើបរិស្ថាន និងសហគមន៍មូលដ្ឋានគឺជាកត្តាចំបងក្នុងការឈានទៅដល់ជំរើសសកម្មភាពដែលមានស្ថេរភាព និងជាទីពេញចិត្ត ។ ចាំបាច់ត្រូវមានការ

ចូលរួមពីអ្នកជំនាញលើផ្នែកនីមួយៗ ប៉ុន្តែវាមានសារៈសំខាន់ណាស់ពីការចូលរួមរបស់សហគមន៍ និងបុគ្គលដែលអាចទទួលរងផលប៉ះពាល់ពីគំរោងអភិវឌ្ឍន៍នោះ ។ ប្រជាជនទាំងនោះគឺជាអ្នកជំនាញលើស្ថានភាពមូលដ្ឋាន និងជីវិតរស់នៅផ្ទាល់ និងសេចក្តីត្រូវការរបស់គេ ។ ការបង្ហាញពីសារៈសំខាន់នៃការយល់ដឹងអំពីបញ្ហានៃការគ្រប់គ្រងធនធាន អាចសិក្សាបន្ថែមទៀតនៅក្នុងការសិក្សាករណីលើអាងជលផល ណាំងឹម ក្នុងប្រទេសឡាវ ។

## គោលការណ៍ការពារ

ក្នុងការព្យាករណ៍ ឬប៉ាន់ស្មាននូវហេតុប៉ះពាល់បរិស្ថាន ឬសេដ្ឋកិច្ចនាពេលអនាគតនៃគំរោងអភិវឌ្ឍន៍ ឬការផ្លាស់ប្តូណាមួយ កំរិតនៃការប្រយ័ត្នប្រយែងគឺជាកត្តាចាំបាច់ក្នុងការឆ្លើយតបឱ្យសមទៅនឹងកំរិតគ្រោះថ្នាក់ ។ គោលការណ៍ការពារដែលមានរៀវរាប់ក្នុងកម្មវិធី Agenda 21 បានចែងថា ÷

"នៅពេលដែលមានការគំរាមកំហែងអំពីការខូចខាតធ្ងន់ធ្ងរ ឬមិនអាចកែប្រែបានណាមួយនោះ ការខ្វះខាតខាងផ្នែកវិទ្យាសាស្ត្រពិតប្រាកដ និងពេញលេញ មិនត្រូវលើកយកជាមូលហេតុនៃការផ្អាកដល់ការចាត់វិធានការវាយតំលៃលើប្រសិទ្ធភាព-ថ្លៃ ដើម្បីការពារដល់ការខូចខាតបរិស្ថាននោះទេ" ។

ការជជែកពិភាក្សាថ្មីៗនេះស្តីពីការគំរាមកំហែងលើកំដៅពិភពលោកដ៏ធ្ងន់ធ្ងរនោះ គឺជាឧទាហរណ៍មួយដែលបានអនុវត្តន៍នូវគោលការណ៍ការពារនេះ ។ ប្រសិនបើការព្រមាននោះមានប្រសិទ្ធិភាពនោះ លទ្ធផលនៃសកម្មភាព និងអាចមានតំលៃថ្លៃច្រើនជាងតំលៃនៃសកម្មភាពដែលធ្វើឡើងដើម្បីកាត់បន្ថយគ្រោះថ្នាក់នោះទៅទៀត ។ សភាវធម៌របស់មនុស្ស និងច្បាប់នៃការយកចិត្តទុកដាក់ គឺចាំបាច់ត្រូវឱ្យបុគ្គល សហគមន៍ និងរដ្ឋាភិបាលធ្វើការយកចិត្តទុកដាក់ដ៏សមស្របក្នុងការការពារដល់គ្រោះថ្នាក់ចំពោះខ្លួនឯង និងអ្នកដ៏ទៃទៀត ។

## អនាគតសំរាប់ការអភិវឌ្ឍន៍ដោយនិរន្តរភាព

នៅពេលដែលយើងគិតដល់បញ្ហាច្រើនមុខ និងសាំញ៉ាំនៅក្នុងការអភិវឌ្ឍន៍ដោយនិរន្តរភាពនោះ យើងពិតជាយល់ច្បាស់ថាដើម្បីសំរេចឈានដល់ការអភិវឌ្ឍន៍នោះ វាប្រហែលពិតជាកិច្ចខិតខំប្រឹងប្រែងដ៏ធំមួយដែលមនុស្សលោកកំពុងប្រឈមមុខ ឬក៏ក្នុងពេលណាមួយនៃប្រវត្តិសាស្ត្រនោះ ។ គោលគំនិតនៃការអភិវឌ្ឍន៍ដោយនិរន្តរភាព គឺមិនមែនជាបំណង ឬជាទិសដៅមួយទេ ប៉ុន្តែគឺជាចលនា ឬជាទស្សនៈផ្លាស់ប្តូរមួយ ដែលយើងត្រូវតែធ្វើដំណើរឆ្ពោះទៅរកវា ។ ការធ្វើដំណើរនេះទាមទារឱ្យមានការគិតគូរ ការជុំរុញ ឆន្ទៈល្អ មេត្តាធម៌ អត់ធ្មត់

កិច្ចសហការ ចំណេះដឹង ការផ្លាស់ប្តូរ និងការបង្កើតថ្មី ។ សុខមាលភាពនាពេលអនាគតរបស់ប្រជាជនទាំងអស់អាស្រ័យលើបំណងរបស់មនុស្សសម័យបច្ចុប្បន្ននៅលើផែនដីនេះក្នុងការប្តេជ្ញាខ្លួនដើរតាមផ្លូវណានោះ ។

## សង្ខេបចំណុចសំខាន់ៗ

- ដើម្បីឱ្យការអភិវឌ្ឍន៍មានលក្ខណៈនិរន្តភាព គឺត្រូវគោរពដល់សិទ្ធ និងកិត្តិយសរបស់មនុស្សគ្រប់រូប និងបរិស្ថាន ។
- ពាក្យអភិវឌ្ឍន៍ដោយនិរន្តរភាព មួយចំនួនមានន័យថា ការការពារភាពក្រខ្វក់ ការថែរក្សា ការរួមចំណែកស្មើគ្នាចំពោះផលប្រយោជន៍ និងតំលៃ និងការចូលរួមរបស់អ្នកពាក់ពន្ធ័ក្នុងការសំរេចចិត្តលើបញ្ហាដែលអាចប៉ះពាល់ដល់ពួកគេ ។
- ការអភិវឌ្ឍន៍ដោយនិរន្តរភាព អាចមានជោគជ័យទៅបាន លុះត្រាតែវាបានកាត់បន្ថយភាពក្រីក្រ ការស្រេកឃ្លាន និងជម្ងឺ គឺថា អ្នកដែលរងផលប៉ះពាល់ច្រើនជាងគេក្នុងសង្គម ត្រូវតែជាអ្នកទទួលផលប្រយោជន៍ ។
- ការអភិវឌ្ឍន៍ដោយនិរន្តរភាពគឺជាប្រព័ន្ធ ចង្វាក់សេដ្ឋកិច្ច-សង្គម និងបរិស្ថាន ដែលកត្តាទាំងអស់នោះត្រូវតែបានដោះស្រាយ ។
- កត្តាបរិស្ថានក្នុងការអភិវឌ្ឍន៍ដោយនិរន្តភាពរួមមាន ការថែរក្សាប្រពន្ធ័អេកូឡូស៊ី ជីវចំរុះ ទឹក និងធនធានដី
- យើងមិនមែនទទួលមរតកផែនដីនេះពីដូនតាយើងទេ ប៉ុន្តែយើងខ្ចីផែនដីនេះពីកូនចៅរបស់យើង ។

# ដំណើរឆ្ពោះទៅការអភិវឌ្ឍន៍ដោយនិរន្តរភាព

~~~~~~~

## ការអភិវឌ្ឍន៍ដោយនិរន្តរភាព : ដំណើរផ្លូវ

ការអភិវឌ្ឍន៍ដោយនិរន្តរភាពមិនមែនជាទិសដៅដែលយើងត្រូវឈានទៅដល់ទេ ប៉ុន្តែគឺជាផ្លូវដើរដែលគ្មានទីបញ្ចប់ដែលយើងត្រូវដើរ ។ ដូចជាដំណើរផ្លូវឯទៀតដែរ វាមានដំណាក់កាលជាច្រើនគឺៈ រៀបចំផ្លូវ សំរេចចិត្តថាតើត្រូវមើលផ្លាកសញ្ញាអ្វីខ្លះ ចាប់ផ្តើមធ្វើដំណើរលើផ្លូវ និងវាស់វែងនូវដំណើរតាមផ្លូវដែលបានធ្វើដំណើរ ។

## ការផ្លាស់ប្តូរផ្នែកស្ថាប័ន ច្បាប់ និងគោលនយោបាយ

របៀបអភិវឌ្ឍន៍សេដ្ឋកិច្ចតាមលក្ខណៈប្រពៃណីបានធ្វើឱ្យប៉ះពាល់ដល់ធនធានធម្មជាតិ និងបណ្តាលឱ្យមានវិសមភាពក្នុងសង្គម ។ មានតែការកែប្រែនូវមូលដ្ឋានគ្រឹះខ្លះៗនៃការគ្រប់គ្រង និងតាមរយៈការកែទំរង់ស្ថាប័នទេ ដែលអាចឱ្យមនុស្សជាតិរៀបចំខ្លួនឈានឆ្ពោះទៅរកការអភិវឌ្ឍន៍មួយប្រកបដោយនិរន្តរភាព តុល្យភាព និងតាមមធ្យោបាយដ៏យុត្តិធម៌នោះ ។

នៅដំណាក់កាលដំបូងរួមមាន ការផ្លាស់ប្តូរគោលនយោបាយជាតិ និងអន្តរជាតិដើម្បីទទួលស្គាល់នូវតំលៃពេញលេញលើធនធានធម្មជាតិក្នុងការចាត់ទុកវាជាប្រភពទុនមួយដែលត្រូវរក្សាឱ្យស្ថិតស្ថេរ កុំឱ្យដូចបច្ចុប្បន្ន និងជាចំណូលមួយដែលយើងអាចចាយវាយបាន ។ ករណីនេះតំរូវឱ្យយើងឱ្យតំលៃពិតប្រាកដជាងមុនដល់ ថាមពល ការដឹកជញ្ជូន ទឹក ព្រៃឈើ ជលផល ដីធ្លី ធនធានកកើតឡើងវិញ និងការបោះចោលនូវកាកសំណល់ដើម្បីផ្តល់នូវការលើកទឹកចិត្តដល់ការប្រើប្រាស់ដោយនិរន្តរភាពនូវប្រភពធនធាន ។

ការអភិវឌ្ឍន៍ធំៗជាច្រើនបានប្រើប្រាស់ធនធានអស់ច្រើន ហើយដែលអាចធ្វើឱ្យរេចរិល ឬមានផលអាក្រក់អស់រយៈពេលជាច្រើនឆ្នាំក្នុងពេលអនាគត ។ តំលៃពិតប្រាកដនៃការស្តារឡើងវិញនៃធនធានទាំងនេះ និងការទូទាត់ទៅនឹងការអាក់ខានក្នុងការរស់នៅរបស់អ្នកដែលរងគ្រោះដោយសារការអភិវឌ្ឍន៍នេះ ត្រូវតែបានគិតគូរឱ្យសព្វគ្រប់ជាងមុន ជាជាងមិនបានគិតគូរ ឬទុកឱ្យអ្នកដែលមិនបានទទួលផលប្រយោជន៍ ឬអ្នកជំនាន់ក្រោយជាអ្នកទទួលរងគ្រោះដូចដែលយើងអាចឃើញអនុវត្តន៍ក្នុងពេលសព្វថ្ងៃនេះ ។
~~~~~~~

## គោលនយោបាយកាត់បន្ថយភាពក្រីក្រ

ដូចបានកត់សំគាល់នៅក្នុងមេរៀនមុន គោលការណ៍នៃការអភិវឌ្ឍន៍ដោយនិរន្តរភាពគឺថាលុះត្រាណាតែប្រជាជនក្រីក្របានទទួលចំណែកផលប្រយោជន៍ពីការអភិវឌ្ឍន៍នោះ បើពុំនោះទេនឹងត្រូវតែមានការទន្ទ្រានទៅលើធនធានធម្មជាតិដែលនៅសល់ដោយសារអ្នកក្រីក្រក្នុងការស្វែងរកធនធានឯទៀតដើម្បីរស់នៅ ។ រដ្ឋាភិបាលត្រូវបង្កើតនូវគោលនយោបាយដោយធ្វើការពិភាក្សាជាមួយអ្នកពាក់ពន្ធ័ទាំងអស់ ជាពិសេសអ្នកក្រីក្រ ប្រជាជនមូលដ្ឋាន និងអ្នកដែលអាចទទួលរងគ្រោះ ឬក៏ក្រុមអ្នករងគ្រោះផ្សេងៗទៀត ដើម្បីធានាដល់ការជូនដំណឹង និងការបែងចែកស្មើគ្នានូវតំលៃ និងផលប្រយោជន៍នៃការអភិវឌ្ឍន៍ ។ ដោយសារប្រជាជនក្រីក្រពឹងផ្អែកស្ទើរតែទាំងស្រុងលើធនធានក្នុងមូលដ្ឋានសំរាប់ការរស់នៅរបស់គេនោះ មធ្យោបាយរកចិញ្ចឹមជីវិតនេះត្រូវតែបានការពារ និងធានាដល់ការប្រើប្រាស់វាដោយប្រជាជន ។ ប្រជាជនដែលក្រីក្រជាងគេបង្អស់ក្នុងសង្គម គឺក៏តែងតែរស់នៅក្នុងតំបន់ដែលទទួលរងផលប៉ះពាល់ដោយសារសំណល់ឧស្សាហកម្ម ដែលបញ្ចេញទៅក្នុង ខ្យល់ ទឹក ឬដី ។ គេគួរត្រូវមានគោលនយោបាយ និងច្បាប់ដែលការពារដល់សិទ្ធិរស់នៅដ៏មានសុខភាពល្អរបស់គេក្នុងបរិស្ថាន និងការការពារចំពោះភាពក្រខ្វក់ ។

ប្រជាជនក្រីក្ររស់នៅលើដីដែលពុំមែនជាបំណងប្រាថ្នារបស់អ្នកដែលមានថវិការច្រើននោះ ។ តំបន់ដូចជាទំនាបលិចទឹក តំបន់ភ្នំដែលអាចងាយបាក់ដី និងលិចទឹក និងតំបន់ឧស្សាហកម្មដែលជាកន្លែងដែលមានបញ្ចេញកាកសំណល់ ឬបំភាយឧស្ម័ន គឺត្រូវបានប្រជាជនក្រីក្ររស់នៅ ។ ជាលទ្ធផលនៅពេលមានគ្រោះធម្មជាតិកើតឡើងនោះគឺប្រជាជនក្រីក្រដែលតែងតែទទួលរងគ្រោះជាងគេ ។ ចាំបាច់ត្រូវមានគោលនយោបាយដើម្បីធានាថា ក្នុងរយៈពេលនោះកម្មវិធីអាចចាត់ចែងរៀបចំឡើងវិញនូវផ្ទះសម្បែង និងដីធ្លីរបស់ប្រជាជនដែលត្រូវផ្លាស់ទីកន្លែង ។

តាមនិយមន័យ អ្នកក្រីក្រពុំអាចមានកម្មសិទ្ធិទ្រព្យសម្បត្តិទេ ។ ជាលទ្ធផលគេបានទទួលការលើទឹកចិត្តតិចជាង អ្នកដែលមានកម្មសិទ្ធដី ក្នុងការថែរក្សាការពារនូវដីដែលគេរស់នៅលើនោះ ។ តំបន់ដែលរស់នៅដោយមនុស្សច្រើន ហើយដែលមិនមែនជាកម្មសិទ្ធរបស់អ្នកណាម្នាក់នោះ ច្រើនត្រូវធ្វើអាជីវកម្មសំរាប់តែរយៈពេលខ្លី ជាជាង ដើម្បីនិរន្តរភាពរយៈពេលវែង ។ មូលហេតុដែលនាំឱ្យកើតមានករណីនេះគឺថា អ្នកដែលមានបំណងថែរក្សាធនធាន ក៏នឹងត្រូវមានអ្នកដែលចង់ប្រមូលយកធនធាននោះឱ្យបានច្រើនតាមដែលគេអាចធ្វើទៅបានដើម្បីទុកប្រការក្នុងករណីណាដែលគេអាចត្រូវចាកចេញពីទីនោះ ។ គោលការណ៍នេះគឺជា "សោកនាដកម្មដល់ទ្រព្យសម្បត្តិរួម" គឺថាដីដែលជាកម្មសិទ្ធរួមវាពុំមែនជាការទទួលខុសត្រូវរបស់អ្នកណាម្នាក់ លុះត្រាណាតែអភិបាលកិច្ចសហគមន៍ត្រូវបានបង្កើតឡើង ។ ការសិក្សាករណីនៅបឹងធំ និងការគ្រប់គ្រងព្រៃលិចទឹក ដោយសហគមន៍ក្នុង ខេត្តសៀមរាប ប្រទេសកម្ពុជា និងនៅអាងជលផល ណាំងឹម នៅប្រទេសឡាវ បានបង្ហាញនូវគោលការណ៍នេះ ។

អ្នកក្រីក្រត្រូវតែបានផ្តល់នូវកម្មសិទ្ធស្របច្បាប់ដើម្បីឱ្យគេមានទឹកចិត្តការពារ និងបង្កើនតំលៃដីដែលគេរស់នៅ ។ ចាំបាច់ត្រូវមានការផ្លាស់ប្តូរដើម្បីប្រគល់ដីឱ្យទៅជាកម្មសិទ្ធរបស់ប្រជាជនមូលដ្ឋាន ហើយអនុវត្តន៏កម្មវិធីគ្រប់គ្រង និងអភិវឌ្ឍន៏រួមដោយរដ្ឋាភិបាល ភ្នាក់ងារផ្តល់ជំនួយ និងអ្នកអភិវឌ្ឍន៏ផ្សេងៗ ។

ការណែនាំប្រើប្រាស់នូវបច្ចេកវិទ្យាក្នុងកំរិតសមស្របក្នុងគំរោងធំៗ អាចផ្តល់នូវផលប្រយោជន៏ផ្ទាល់ច្រើនដល់សហគមន៏មូដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ ។ ឥណទានសំរាប់គ្រួសារ និងសហគមន៏បានបង្ហាញនូវជោគជ័យនៃផលចំណូលហិរញ្ញវត្ថុដល់ប្រជជនមូលដ្ឋានជាងការអភិវឌ្ឍន៏ឧស្សាហកម្ម ឬ កសិកម្មធំៗ ដែលជាទូទៅផលប្រយោជន៏ត្រូវធ្លាក់ទៅកន្លែងដែលនៅឆ្ងាយពីកន្លែងដែលទទួលរងការប៉ះពាល់ ។ ការប្រើប្រាស់បច្ចេកវិទ្យាសមស្របគឺជាកត្តាសំខាន់ដែលបានអនុវត្តន៏នៅមជ្ឍមណ្ឌលភូមិន្ទសិក្សា និងអភិវឌ្ឍន៏នៅក្នុងប្រទេសថៃ និងការការពារច្រាំងទន្លេទីក្រុងវៀងចន្ទ័ ក្នុងប្រទេសឡាវ ។

ទោះបីជាចំពោះការតំឡើងសំណង់ធំៗក៏ដោយ វា ប្រហែលជាមានប្រសិទ្ធភាពខាងតំលៃ និងមានលក្ខណៈបរិស្ថានល្អជាង បើសិនជាការសាងសង់ក្នុងកំរិតសមស្រប តាមគំរូវការក្នុងមូលដ្ឋាន ជាជាងក្នុងកំរិតធំមួយដើម្បីចែកចាយដែលត្រូវពឹងផ្អែកលើការលក់ចេញទៅប្រទេសក្រៅ ដើម្បីសមស្របតាមស្ថានភាពណាមួយនោះ។

ដោយសារថាប្រជាជនគឺជាមូលដ្ឋាននៃការអភិវឌ្ឍន៏ដោយនិរន្តរភាព ចាំបាច់ត្រូវឱ្យមានការចូលរួមស្មើៗគ្នា ពីបណ្តាអ្នកពាក់ពន្ធ័ទាំងអស់ក្នុងការសំរេចចិត្ត ។ អំណាចក្នុងការសំរេចិត្ត ត្រូវមានស្មើៗគ្នា ចំពោះអ្នកដែលនឹងត្រូវទទួលរងផលប៉ះពាល់ពីការសំរេចចិត្តនោះ ។ តម្លាភាព ភាពទទួលខុសត្រូវ និងគោលនយោបាយនិងការធ្វើផែនការដែលចូលរួមដោយភាគីពាក់ពន្ធ័ទាំងអស់ នាំឱ្យអាចឈានទៅដល់ដំណោះ ស្រាយរយៈពេលវែងក្នុងការអភិវឌ្ឍន៏ ជាងការដែលធ្វើដោយស្ទាត់កំបាំង ដោយអ្នកមានអំណាចដោយគ្មានការ ពិភាក្សា ។ ឧទាហរណ៏នៃការចូលរួមរបស់អ្នកពាក់ពន្ធ័មានបង្ហាញក្នុងការសិក្សាករណីស្តីពីការគ្រប់គ្រងព្រៃលិចទឹកនៅក្នុងខេត្តសៀមរាបដោយសហគមន៏ និងអំពីគំរោងគ្រប់គ្រងដីសើមចំរុះនៅបឹងធំក្នុងប្រទេស កម្ពុជា ។

គំនិតផ្តួចផ្តើមនៃកម្មវិធី Agenda 21 និងគំនិតផ្តួចផ្តើមរបស់ធនាគារអភិវឌ្ឍន៏អាស៊ី ធនាគាពិភពលោក និងអង្គការសហប្រជាជាតិ បានបង្ហាញពីសារៈសំខាន់នៃការទទួលស្គាល់នូវស្ថានភាព និងមុខងាររបស់ស្ត្រីជាដៃគូរក្នុងការអភិវឌ្ឍន៏ដោយនិរន្តរភាព ។ ស្ត្រីជាតំណាងឱ្យមនុស្សក្រីក្រភាគច្រើនក្នុងសង្គម ហើយដែលសិទ្ធិរបស់គេតែងតែមានកំណត់ ។ ការផ្តល់ភាពស្មើភាពដល់ស្ត្រីគឺជាមូលដ្ឋានគ្រឹះមួយទៀតក្នុងការអភិវឌ្ឍន៏ដោយនិរន្តភាព ។

## តំរូវការផ្នែកច្បាប់ និងស្ថាប័ន

ច្បាប់ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៏ដោយនិរន្តភាពត្រូវបង្កើតឡើងក្នុងក្របខ័ណ្ឌគោលការណ៏ និងនយោបាយដូចមានសង្ខេបក្នុងផ្នែកដំបូងក្នុងមេរៀននេះ ។ តាមប្រពៃណី ច្បាប់ និងបទបញ្ញត្តិទាក់ទងនឹងធនធានត្រូវបានបង្កើតឡើងទៅតាមវិស័យផ្សេងៗគ្នាដូចជាព្រៃឈើ ជលផល កសិកម្ម សត្វព្រៃ ឧស្សាហកម្ម ការប្រើប្រាស់ដីរ៉ែ ថាមពល បរិស្ថាន និងក៏ដូចជាវិស័យសេដ្ឋកិច្ចហិរញ្ញវត្ថុផងដែរ ។ ធម្មតា ការគ្រប់គ្រង និងរដ្ឋបាលនៃធនធាន

នីមួយៗត្រូវបានខ័ណ្ឌដាច់ពីគ្នាដែលនាំឱ្យមានការត្រួតស៊ីគ្នានូវប្រព័ន្ធសមត្ថកិច្ច មានគំលាតក្នុងការគ្រប់គ្រង ការប្រតួតប្រជែង និងមានការជាន់គ្នារវាងភ្នាក់ងាររដ្ឋាភិបាលផ្សេងៗ ។

សំរាប់ទស្សនៈទូលំទូលាយក្នុងការជំរុញ ដល់ការអភិវឌ្ឍន៍ដោយនិរន្តរភាព វាចាំបាច់ត្រូវធ្វើឱ្យមានភាពស្របគ្នាក្នុងការទទួលខុសត្រូវ និងអនុវត្តន៍ក្នុងវិស័យ ផ្សេងៗដើម្បីអនុវត្តន៍ និងត្រួតពិនិត្យភាពស្របច្បាប់នោះ ។ អ្នកបង្កើតច្បាប់ត្រូវគិតគូរដល់ប្រពន្ធ័អេកូឡូស៊ី ផ្ទៃរងទឹកភ្លៀង អាងទន្លេទាំងមូល និងប្រតិកម្ម និងការទាក់ទងគ្នាទៅវិញទៅមករវាងធនធានក្នុងវិស័យផ្សេងៗ ។ ឧទាហរណ៍ ដូចជា ដើម្បីឈានឆ្ពោះទៅរកការប្រើប្រាស់ប្រកបដោយស្រិទ្ធភាព និងការការពារធនធាននោះ ច្បាប់ព្រៃឈើ ត្រូវគិតគូរដល់ផលប៉ះពាល់នៃការកាប់ឈើទៅលើការប្រើប្រាស់ធនធានដ៏ទៃទៀតក្នុងតំបន់ផ្ទៃរងទឹក ភ្លៀងដូចជា ជលផល គុណភាពទឹក និងការប្រើប្រាស់ផលិតផលព្រៃឈើដែលមិនមែនជាឈើផ្សេងៗទៀត ។

ការបង្កើននូវការរួមបញ្ចូលគ្នានៃច្បាប់ក្នុងក៏រិតមូលដ្ឋាន និងថ្នាក់ជាតិ គឺជាតួនាទីរបស់ភ្នាក់ងារផ្សេងៗ ដូចជា គណៈកម្មាការទន្លេមេគង្គ (MRC) ជាដើមក្នុងផែនការតំបន់ដែលឆ្លងកាត់ព្រំដែនប្រទេស ដើម្បីធានាដល់ផលប្រយោជន៏នៃបណ្តប្រទេសជាសមាជិកទាំងអស់ ( សូមមើលលំអិតក្នុងមេរៀនទី ៨) ។

ក្នុងការបង្កើតច្បាប់ និងបទបញ្ញត្តិផ្សេងៗដើម្បីការពារធនធានធម្មជាតិ កត្តាសំខាន់គឺត្រូវធានានាថា ច្បាប់នោះនឹងត្រូវបានអនុវត្តន៍ដោយសមស្រប មានតម្លាភាព និងដោយយុត្តិធម៌ ។ វាងាយស្រួលទេក្នុងការសរសេរច្បាប់ ប៉ុន្តែវាពិបាកក្នុងការអនុវត្តន៍ បើយើងខ្វះខាតធនធានមនុស្ស និងថវិកា ។ គោលការណ៍ជាមូលដ្ឋានមួយចំនួននោះមាន ÷

- នៅពេលធនធានកកើតឡើងវិញដូចជា ដើមឈើ រុក្ខជាតិផ្សេងៗទៀត ត្រី សត្វព្រៃ ត្រូវបានគេរកនៅក្នុងតំបន់មួយ អត្រានៃការរកនោះមិនត្រូវឱ្យប៉ះពាល់ប្រពន្ធ័អេកូឡូស៊ី ដែលវាបានពឹងផ្អែកលើនោះទេ
- អ្នកធ្វើឱ្យខូចខាត ក្រខ្វក់ និងប្រើប្រាស់ធនធានធម្មជាតិត្រូវតែបង់ថ្លៃពេញលេញចំពោះផលប៉ះពាល់ទៅលើបរិស្ថាន រួមទាំងសុខភាព និងការបាត់បង់ទាំងអស់ដោយសារការប្រើប្រាស់ធនធានដោយអ្នកដ៏ទៃទៀតផងដែរ ។

ការអនុវត្តន៍ និងត្រួតពិនិត្យដ៏មានប្រសិទ្ធភាពទៅលើគោលការណ៍ទាំងនេះ នឹងត្រូវធ្វើក្នុងរយៈពេលយូរដើម្បីឈានទៅរកការទទួលខុសត្រូវ និងការអភិរក្សរយៈពេលវែងចំពោះធនធានសំរាប់មនុស្សជំនាន់ក្រោយ ។ ការធ្វើការត្រួតពិនិត្យដ៏មានប្រសិទ្ធភាពគឺជាទិន្នន័យដ៏ច្បាស់លាស់មួយស្តីពីស្ថានភាពទូទៅ ប្រជាជន និងប្រភេទសត្វផ្សេងៗ គឺជាការងារដ៏ចំបងមួយដែរ ដោយសារនៅខ្វះអ្នកមានសមត្ថភាព និងថវិកា ។ បញ្ហាអនុវត្តន៍ច្បាប់ត្រូវបានពិនិត្យមើលនៅក្នុងការសិក្សាករណីអាងជលលផល ណាំងឹម ក្នុងប្រទេសឡាវ ។

## ការវាយតំលៃលើបរិស្ថានជាយុទ្ធសាស្រ្ត

ការវាយតំលៃលើបរិស្ថានជាយុទ្ធសាស្រ្ត (SEA) គឺជាដំណើរការមួយដែលត្រូវបានអនុវត្តន៏ជាបន្តបន្ទាប់នៅក្នុងប្រទេសមួយចំនួនដើម្បីវាយតំលៃលើហេតុប៉ះពាល់បរិស្ថានដែលអាចកើតមានពីគោលនយោបាយ និងច្បាប់ដែលបានលើកឡើង ។ ប្រធានបទនេះនឹងត្រូពិភាក្សាលំអិតនៅក្នុងមេរៀន H ។ សំរាប់ពេលនេះគឺវាជាការគ្រប់គ្រាន់នឹងនិយាយថា SEA គឺជាការដាក់ការគិតគូរផ្នែកបរិស្ថានទៅក្នុងការគិតគូរសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបច្ចេកវិទ្យា នៅពេលពិនិត្យមើលដល់លទ្ធផលនៃការអនុវត្តន៏ច្បាប់ ឬនយោបាយជាតិ ឬក៏តំបន់ ។ យោងទៅដល់ពាក្យនេះ SEA គឺជាការពិនិត្យមើលក៏រិតខ្ពស់មួយទៅលើផលប៉ះពាល់ដែលអាចកើតមានពីកម្មវិធី ច្បាប់ នយោបាយអភិវឌ្ឍន៏ និងផែនការថ្នាក់តំបន់ ដែលត្រូវវាយតំលៃថាតើយុទ្ធសាស្រ្តដែលបានលើកឡើងនោះវាសមស្របសំរាប់ធានាដល់ការអភិវឌ្ឍន៏ដោយនិរន្តរភាពដែរឬទេ ។

SEA អាចផ្តល់នូវប្រពន្ធ័នៃការប្រុងប្រយត្ន័ចំពោះបញ្ហាដែលយើងមិនបានគិតទុកជាមុន ដែលអាចកើតឡើងដោយសារគោលនយោបាយ ឬច្បាប់ដែលបានលើកឡើងនោះ ។ SEA ដែលបានអនុវត្តន៏ទៅដោយល្អនោះអាចបង្ហាញពីទិដ្ឋភាពនៃការអភិវឌ្ឍន៏ដែលត្រូវយកចិត្តទុកដាក់ជាពិសេស ដូចជាការបង្កើននូវការជ្រាបចូលនៃទឹកជាតិអំបិលទៅក្នុងទំនាបមេគង្គ និងការខ្វះទឹកដើម្បីទ្រទ្រង់ដល់ជលផលនៅក្នុងបឹងទន្លេសាប ប្រសិនបើរំហូរទឹកត្រូវបានរារាំងដោយទំនប់នៅផ្នែកខាងលើនៃអាងទន្លេមេគង្គ (MRB) ។ លទ្ធផលសេដ្ឋកិច្ច និងសង្គមនៃផលប៉ះពាល់ដូចខាងលើនេះអាចកើតមានច្រើនពីគោលនយោបាយ ដែលចង់ជុំរុញដល់ការអភិវឌ្ឍន៏វារីអគ្គិសនី ។ SEA អាចជួយកំណត់នូវវិធីសាស្រ្តដើម្បីបង្កើតនូវស្ថានភាពល្អទាំងបីសំរាប់ តំរូវការសេដ្ឋកិច្ច-សង្គម ប្រព័ន្ធអេកូឡូស៊ី និងបរិស្ថាន ។

ការយកចិត្តទុកដាក់របស់ SEA ក៏ដូចជាក្នុងការវាយតំលៃហេតុប៉ះពាល់បរិស្ថានផ្សេងៗទៀតដែរគឺការការពារដល់គ្រោះភ័យ ។ ដំណើរការនេះក៏អាចជួយធ្វើឱ្យមានភាពស្របគ្នា និងទំនាក់ទំនងគ្នារវាងគោលនយោបាយអភិវឌ្ឍន៏នៅក្នុងបណ្តាប្រទេសជាសមាជិក ដើម្បីធានាថាគំនិតផ្តួចផ្តើមរបស់ប្រទេសនិមួយៗនឹងត្រូវផ្តល់ប្រយោជន៏ដល់គ្នាទៅវិញទៅមក ។ ក្នុងន័យនេះ SEA អាចកាត់ផ្តាច់នូវព្រំដែនជាតិ ក៏រិតរដ្ឋាភិបាល និងព្រំដែន នៃវិស័យផ្សេងៗដើម្បីផ្តោតការយកចិត្តទុកដាក់ទៅលើផលប្រយោជន៏ល្អថែមទៀតសំរាប់មនុស្សគ្រប់រូបនៅពេលកំណត់អាទិភាព និងក៏រិតព្រំដែនសំរាប់ការអភិវឌ្ឍន៏ដោយនិរន្តរភាពក្នុងអាងទន្លេមេគង្គ (MRB) ។

## ការវាយតំលៃលើហេតុផលប៉ះពាល់រួម

ក្នុងធម្មជាតិគ្មានសកម្មភាព ឬផលប៉ះពាល់ណាកើតឡើងដោយដាច់តែឯងពីសកម្មភាព និងផលប៉ះពាល់ផ្សេងៗទៀតទេ ។ ប្រពន្ធ័អេកូឡូស៊ី មនុស្ស សេដ្ឋកិច្ច និងប្រពន្ធ័នយោបាយត្រូវបានជាប់ទាក់ទងគ្នា និងពឹងផ្អែកលើគ្នាទៅវិញទៅមក ។ នៅពេលដែលការអភិវឌ្ឍន៏ណាមួយបានធ្វើឡើងនៅផ្នែកណាមួយនៃអាងទន្លេមេគង្គ (MRB) ផលវិបាករបស់វាអាចរាលដាលដល់អាងទន្លេទាំងមូល ។ ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

រួម (CEA) គឺជាដំណើការមួយដែលប្រើដើម្បីវាយតំលៃលើផលប៉ះពាល់រួមនៃការអភិវឌ្ឍន៍មួយ ឬច្រើនទៅលើបរិស្ថាននៅកន្លែង និងពេលវាលាជាច្រើន ។ CEA ផ្តោតទៅលើផលប៉ះពាល់រួមនៃសកម្មភាពណាមួយដោយខុសពី SEA ដែលគិតគូពីផលប៉ះពាល់ទូទៅនៃគោលនយោបាយច្បាប់ និងផែនការនៃកម្មវិធីនោះ ។ CEA មានបំណងពិនិត្យមើលថាតើផលប៉ះពាល់រួមនៃផលប៉ះពាល់តូច មធ្យម និងធំៗវាបានកើតឡើងក្នុងរយៈពេលបន្តមកទៀតនោះវាអាចប៉ះពាល់ដល់បរិស្ថានយ៉ាងណា ឬថាតើការផ្លាស់ប្តូរទាំងឡាយនោះនៅក្នុងបរិស្ថានវាប៉ះពាល់ដល់មុខងារនៃប្រពន្ធ័អេកូឡូស៊ី ធនធានកកើតឡើងវិញ និងសុខភាពយ៉ាងណា ។ ហេតុផលប៉ះពាល់បរិស្ថានពីប្រភពធនធានមួយ (ឧទាហរណ៏ រោងចក្រជីមួយ) អាចត្រូវធ្វើការព្យាករណ៏ និងត្រួតពិនិត្យបានដោយក្នុងលក្ខណៈពិតប្រាកដបើទោះជាក្នុងឧទាហរណ៏ដ៏សាមញ្ញនេះ ការផ្លាស់ប្តូរក្នុងក៏រិតទាបអាចមិនត្រូវបានកត់សំគាល់ក្នុងរយៈពេលណាមួយក៏ដោយ ។ ធាតុពិត សេដ្ឋកិច្ច និងការអភិវឌ្ឍន៏ឧស្សាហកម្មដូចជាកាកើតឡើងនូវរោងចក្រ ជីគឺមិនមែនកើតឡើង ដាច់ពីការផ្លាស់ប្តូរផ្សេងទៀតទេ ដូចជាការកើនឡើងនូវចំនួនប្រជាជន ហេដ្ឋារចនាសម្ពន្ធ័ថ្មីមាន ផ្លូវថ្នល់ ការដឹកជញ្ជូន ផ្ទះសម្បែង និងការអភិវឌ្ឍន៏ផ្សេងៗទៀត ដូចជាការផលិតថាមពលផលិតចំណីអាហារ សំណង់ និងឧស្សាហកម្មផ្សេងៗទៀត ។ ការអភិវឌ្ឍន៏អាចកើតឡើងនៅក្នុងតំបន់ភូមិសាស្រ្តតែមួយដូចគ្នា ឬនៅឆ្ងាយពីគ្នា ។ ដោយពុំគិតពីទីតាំងរបស់វា ការអភិវឌ្ឍន៏ទាំងអស់នោះត្រូវការនូវសមត្ថភាពដែលអាចទ្រទ្រង់នៃប្រពន្ធ័អេកូឡូស៊ី ផ្សេងៗនៅក្នុង MRB ។

ការពិភាក្សាលំអិតស្តីពី CEA នឹងត្រូវបង្ហាញនៅក្នុងមេរៀន G ។ គោលបំណងនៃការលើកឡើងនៅពេលនេះគឺដើម្បីបង្ហាញពី CEA ដែលអាចចូលរួមក្នុងការធ្វើការប្រុងប្រយត្ន័ជាមុនដល់កាខូចខាតប្រពន្ធ័អេកូឡូស៊ី ។ CEA អាចប្រើក្នុងការជូនដំណឹងដល់រដ្ឋាភិបាល និងផ្នែកជំនួញផ្សេងៗពីផលប៉ះពាល់រួមដែលអាចកើតមានពីការអភិវឌ្ឍន៏នៅកន្លែងផ្សេងៗក្នុងអាង MRB គឺផលប៉ះពាល់ដែលអាចរាលដាលដល់រាប់រយគីឡូម៉ែត្រពីប្រភពរបស់វា ។ ដោយធ្វើការផ្សព្វផ្សាយពីការយល់ដឹងអំពីផលប៉ះពាល់ទៅវិញទៅមកដែលអាចកើតមាន CEA ក៏ដូចជា SEA ផងដែរអាចជំរុញដល់ការទទួលខុសត្រូវ និងការអភិវឌ្ឍន៏ដែលមានផលប្រយោជន៏ទៅវិញទៅមករវាងបណ្តាប្រទេសនៅក្នុងអាងទន្លេមេគង្គ (MRB) ។

**ការវាយតំលៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្រ្ត** (SEA)

ការវាយតំលៃប្រកបដោយលក្ខណៈត្រឹមត្រូវនៃផលវិបាកលើបរិស្ថាននៃគោលនយោបាយច្បាប់ឬ ផែនការកម្មវិធីដែលបានលើកឡើង ។

**ការវាតំលៃផលប៉ះពាល់រួម** (CEA)

ការកំណត់ និងវាយតំលៃលើផលប៉ះពាល់ទៅវិញទៅមក និងសរុបនៃសកម្មភាពរបស់មនុស្សលើប្រពន្ធ័អេកូឡូស៊ីទាំងមូលក្នុងរយៈពេលបន្តបន្ទាប់ ។

## ការត្រួតពិនិត្យលើកិច្ចដំណើរការឆ្ពោះទៅរកការអភិវឌ្ឍន៍ដោយនិរន្តរភាព

នៅពេលមានការអភិវឌ្ឍន៍ រដ្ឋាភិបាល និងស្ថាប័នអន្តរជាតិ ដូចជា MRC ត្រូវមានប្រពន្ធ័វាស់ស្ទង់ និងគ្រប់គ្រងដើម្បីត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន និងសេដ្ឋកិច្ច-សង្គម និងដើម្បីធ្វើការណែនាំនូវវិធានការ កែតំរូវ និងការពារនៅពេលណាចាំបាច់ ។ ការគ្រប់គ្រងធនធានចំរុះ និងបរិស្ថាន (IREM) គឺជាឧបករណ៍មួយ ដែលជួយដល់ការទទួលខុសត្រូវទាំងនេះ និងក្នុងការធ្វើទំនាក់ទំនងរវាងបណ្តាការងារក្នុងវិស័យផ្សេងៗទាំងនោះ ដែលបានលើកឡើងខាងដើមក្នុងមេរៀននេះ ។

## ការគ្រប់គ្រងធនធានចំរុះ និងបរិស្ថាន (IREM)

ប្រពន្ធ័អេកូឡូស៊ីគឺមិនមែនកំណត់ដោយព្រំដែនជាតិឬ ខេត្តទេ ហើយក៏មិនអាចចែកឱ្យដាច់ពីគ្នាដើម្បីឱ្យសមទៅតាមក្របខ័ណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋបាលបានដែរ ។ IREM មានបំណងអនុវត្តន៏នូវប្រពន្ធ័គ្រប់គ្រងរបស់មនុស្សដើម្បីឆ្លើយតបនឹងការគោរពទៅតាមច្បាប់ធម្មជាតិ ។ មេរៀន C នឹងបង្ហាញលំអិតអំពី IREM ។ គោលការណ៏ដែលបានលើកឡើង និងការអនុវត្តន៏ជាមូលដ្ឋានមួយចំនួននឹងត្រូវពិភាក្សានៅពេលនេះដើម្បីបង្ហាញពីការប្រើប្រាស់របស់វា ។

IREM ផ្តោតការយកចិត្តទុកដាក់លើប្រពន្ធ័អេកូឡូស៊ីជាដែនមួយដែលត្រូវគ្រប់គ្រងដោយយកចិត្តទុកដាក់ដល់ភាពទំនាក់ទំនងគ្នារវាងផ្នែកផ្សេងៗនៃប្រពន្ធ័អេកូឡូស៊ី ។ ដូចក្នុង SEA និង CEA ដែរការយកចិត្តទុកដាក់ជាសំខាន់របស់ IREM គឺការការពារបញ្ហា ។ ដូចនេះហើយបានជាឧបករណ៏គ្រប់គ្រងទាំងបីនេះត្រូវបានបញ្ចូលក្នុងមេរៀននេះក្នុងចំណេងជើងការអភិវឌ្ឍន៏ដោយនិរន្តរភាព និង ការយល់ដឹងពីបរិស្ថាន ។ ការការពារគឺតែងតែមានប្រសិទ្ធភាពតំលៃជាងការព្យាបាលហើយវាអាចឱ្យយើងជួយដល់ការខូចខាតបរិស្ថាន និង ការឈឺចាប់របស់មនុស្សលោកផង ។

IREM ដ៏មានប្រសិទ្ធភាព គឺធ្វើឡើងដោយផ្អែកទៅលើមូលដ្ឋាននៃទិន្នន័យជាមូលដ្ឋាននៃ រុក្ខជាតិ សត្វ ប្រភេទដី ការប្រើប្រាស់ដី គុណភាពទឹក ធារាសាស្រ្ត ការប្រើប្រាស់ធនធានធម្មជាតិ ការបញ្ចេញកាកសំណល់ ស្ថានភាពប្រជាជន និងដំណើការទាក់ទងគ្នាទៅវិញទៅមករវាងកត្តាទាំងនោះ ។ ពិតណាស់ វាត្រូវការនូវធនធានមនុស្សមួយចំនួនធំ ប៉ុន្តែវាជាការល្អដែរដោយសារវាមិនត្រូវការឱ្យមានភាពល្អឥតខ្ចោះប៉ុន្មានទេ ។ IREM មានភាពរស់រវើក និងអាចសំរបទៅតាមពត៏មានដែលអាចមាន និងអាចត្រូវផ្លាស់ប្តូរ ។ ការគ្រប់គ្រងគឺស្ថិតក្នុងកំរិតដ៏ល្អមួយដែល ទិន្នន័យនោះបានផ្តល់ឱ្យ ហើយវានឹងមានលក្ខណៈល្អប្រសើឡើងថែមទៀតនៅពេលដែលគេបានស្វែងយល់ និងដឹងអំពីប្រពន្ធ័អេកូឡូស៊ីបានកាន់តែល្អឡើងនោះ ។ គោលការណ៏ការពារគឺជាមូលដ្ឋានរបស់ IREM ហើយការដែលពុំមានភស្តុតាងបញ្ជាក់ វាពុំមែនជាមូលហេតុដែលយើងដែលយើងត្រូវពន្យាពេលអនុវត្តន៏

នូវវិធានការការពារទេប្រសិន បើប្រព័ន្ធអេកូឡូស៊ីត្រូវបានពិនិត្យឃើញថាកំពុងចុះថយ និងរងការគំរាមគំហែងនោះ ។ ការគ្រប់គ្រងធនធានគួរត្រូវ អនុវត្តន៍តាមការផ្លាស់ប្តូរនូវចំណេះដឹងជាប្រចាំ ដើម្បីថែរក្សានូវតុល្យភាពរវាងការអភិវឌ្ឍន៍ និងស្ថេរភាព ។

IREM គឺត្រូវការឱ្យយើងផ្អាកនូវតំរូវការសិន ដើម្បីពិនិត្យមើលនូវភាពជាក់លាក់ និងភ័ស្តុតាងដែលមិនអាចប្រកែកបានមុននឹងធ្វើសកម្មភាពអ្វីមួយ ។ វាត្រូវពឹងផ្អែកលើគោលការណ៍ "រៀនសូត្រតាមរយៈការអនុវត្តន៍" ហើយកែតំរូវសកម្មភាពតាមរយៈលទ្ធផលនៃការរៀនសូត្រនោះ ។ ឧទាហរណ៍ នៅក្នុងសតវត្សទី ២០ ភាគច្រើនទំនប់ត្រូវបានគេយល់ថាវាជាប្រភពផ្តល់ចរន្តអគ្គិសនីដែលមានលក្ខណៈបរិស្ថាន និង សុខភាពល្អ ។ ប៉ុន្តែនៅពេលដែលពត៌មានត្រូវបានប្រមូលនៅចុងសតវត្សកន្លងមកស្តីពីផលប៉ះពាល់រយៈពេលវែងនៃទំនប់លើបរិស្ថាន និងសេដ្ឋកិច្ច-សង្គម វាបានក្លាយទៅជាសក្ខីភាពបញ្ជាក់ថា ក្នុងកាលៈទេសៈជាច្រើន តំលៃនៃការអភិវឌ្ឍន៍វារី-អគ្គិសនីចំពោះសង្គម និងប្រព័ន្ធអេកូឡូស៊ី គឺវាមិនស៊ីគ្នានឹងផលប្រយោជន៍ទេ ។ ការនេះបាននាំឱ្យធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ទាមទារឱ្យអ្នកគាំទ្រការអភិវឌ្ឍន៍នេះធ្វើការវាយតំលៃឱ្យបានល្អិតល្អន់នូវគំរោងសាងសង់ទំនប់ដោយប្រើគោលការណ៍ IREM ដូចដែលនឹងត្រូវពិភាក្សាក្នុងមេរៀនទី ៦ ។

អ្នកជំនាញនៅក្នុងអង្គភាពនានារបស់រដ្ឋភិបាល និងវិទ្យាស្ថាននានា និងការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល និងភ្នាក់ងារផ្តល់ជំនួយបរទេសត្រូវទំនាក់ទំនងគ្នា ដើម្បីបង្កើតនូវទិន្នន័យជាមូលដ្ឋាន និងធ្វើការអនុវត្តន៍នូវយុទ្ធសាស្ត្រ IREM ដ៏សមស្របមួយ ។ មតិយោបល់ដែលដកស្រង់ចេញពីបទពិសោធន៍របស់សហគមន៍មូដ្ឋានគឺជាផ្នែកមួយផងដែរសំរាប់គាំទ្រដល់ការសំរេចចិត្តក្នុងបរិបទ IREM ។ ដំណោះស្រាយទាំងឡាយត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋានថ្នាក់តំបន់ ។ អាងទន្លេមេគង្គ គឺជាតំបន់ដ៏សមស្របមួយដែលអាចបង្កើតជាក្រខណ្ឌ IREM ហើយ MRC គឺអង្គភាពមួយដែលមានលក្ខណៈសមស្របទាំងសមត្ថភាព និងទីកន្លែង ដើម្បីធ្វើទំនាក់ទំនង និងអនុវត្តន៍នូវ IREM ។ កិច្ចខិតខំប្រឹងប្រែងអនុវត្តន៍នូវ IREM ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍ដោយនិរន្តរភាព និងការចាំបាច់ក្នុងការរំលាយនូវព្រំដែនគ្រប់គ្រងធនធានជាលក្ខណៈប្រពៃណី ត្រូវបានបង្ហាញក្នុងការសិក្សាករណីនៅតំបន់ឋបនីយ៍ជីវមណ្ឌលព្រែកទាល់ ក្នុងប្រទេស កម្ពុជា ។

## សង្ខេបចំណុចសំខាន់ៗ

- ការអភិវឌ្ឍន៍ដោយនិរន្តភាពត្រូវតែបង្កើតឡើងដោយផ្អែកលើគោលការណ៍ និងគោលនយោបាយដែលគិតគូរដល់សេដ្ឋកិច្ច ការប្រើប្រាស់ធនធានធម្មជាតិ ការលើកទឹកចិត្តផ្នែកតំលៃ ការកាត់បន្ថយភាពក្រីក្របរិស្ថាន ការប្រើប្រាស់បច្ចេកវិទ្យា និងសិទ្ធិរបស់សហគមន៍ និងបុគ្គល ។

- ច្បាប់ដែលគាំទ្រដល់ការអភិវឌ្ឍន៍ដោយនិរន្តភាពត្រូវផ្អែកលើគោលនយោបាយ និងគោលការណ៍ល្អ និងផ្ដោតលើការរួមបញ្ចូលគ្នានូវច្បាប់គ្រប់គ្រងបរិស្ថាន និងការគិតគូរផ្នែកសេដ្ឋកិច្ច និងយុត្តិធម៌សង្គម ។
- ការប្រើប្រាស់ SEA និង CEA អាចជួយដល់ការការពារបរិស្ថាន និងបញ្ហាសង្គមដែលកើតឡើងពីការអភិវឌ្ឍន៍ និងក្នុងការចង្អុលបង្ហាញនូវបញ្ហាដែលត្រូវយកចិត្តទុដាក់ជាចំបង ។
- ដើម្បីឆ្លើយតបទៅនឹងសម្ពាធនៃការអភិវឌ្ឍន៍ ការគ្រប់គ្រងប្រពន្ធ័អេកូឡូស៊ី អាចធ្វើឡើងដោយប្រើ IREM ដែលអាចធ្វើទំនាក់ទំនងនូវរាល់ការចូលរួមរបស់អ្នកជំនាញជាច្រើនក្នុងរបៀបគ្រប់គ្រងដ៏សមស្របមួយ ។
- ចាំបាច់ត្រូវការនូវធនធានមនុស្សមួយចំនួនធំ ដើម្បីបង្កើតនូវទិន្នន័យជាមូលដ្ឋាន និងពិតប្រាកដដែលត្រូវការសំរាប់អនុវត្តន៍ IREM ។

# សេដ្ឋកិច្ចបរិស្ថាន

~~~~~~~

## អត្តចរិតគឺជាអ្វីៗទាំងអស់

ដើម្បីអោយការអភិវឌ្ឍន៍មានលក្ខណៈនិរន្តរភាព គឺមិនត្រូវយកចិត្តទុកដាក់តែទៅលើតែបរិស្ថាន និង ប្រព័ន្ធអេកូឡូស៊ីទេ ប៉ុន្តែត្រូវតែដោះស្រាយបញ្ហាតំរូវការផ្នែកសង្គម ជាពិសេសភាពក្រីក្រ ការបណ្តុះបណ្តាល និងសមភាពរវាងបុគ្គល ដោយក្នុងពេលជាមួយគ្នានោះ ក៏ត្រូវផ្តល់នូវចំណូលដ៏សមរម្យលើប្រាក់ដែលបានដាក់ទុន ដោយអ្នកអភិវឌ្ឍន៍ផងដែរ ។ ការការពារបរិស្ថាន យុត្តិធម៌សង្គម និងការរីកចំរើនសេដ្ឋកិច្ច កត្តាទាំងនេះត្រូវតែគាំទ្រដល់គោលបំណងនៃការអភិវឌ្ឍន៍ដោយនិរន្តរភាព ។

អត្តចរិតចំពោះផ្នែកទាំងអស់នៃការអភិវឌ្ឍន៍ដោយនិរន្តរភាពនេះ គឺត្រូវបានបង្កើតជារូបរាងឡើងដោយ កត្តាបុគ្គល តំលៃវប្បធម៌ និងក៏រិតមាត្រដ្ឋានណាមួយ ។ ជាលទ្ធផលត្រលប់មកវិញ អត្តចរិតដែលគ្រប់គ្រងលើ មហិច្ឆិតា បំណង ការព្រួយបារម្ភរបស់យើង និងសកម្មភាពដែលយើងបំណងធ្វើទាក់ទងទៅនឹងផ្នែកសំខាន់ៗទាំង បីនោះ វានឹងកំណត់ថា តើវាមានលទ្ធភាព នឹង អភិវឌ្ឍន៍ដោយនិរន្តរភាពដែរឬទេ ។

## អត្តចរិតចំពោះបរិស្ថាន

អត្តចរិតជាមូលដ្ឋានទាំងបួនចំពោះបរិស្ថានគឺមានលក្ខណៈដូចខាងក្រោម :

- **អត្តចរិតដែលគិតតែប្រយោជន៍ :** បរិស្ថាន និង ប្រព័ន្ធអេកូឡូស៊ីកើតមានឡើងគឺដើម្បីតែបំរើ ដល់ផលប្រយោជន៍សេដ្ឋកិច្ចរបស់មនុស្សជាតិ ។ បើទុកនៅតែកន្លែងដើមវាដដែល ផ្នែកផ្សេងៗដែលបង្កើតបរិស្ថាន (ដី ទឹក រុក្ខជាតិ សត្វ រ៉ែ ) នឹងពុំមានតំលៃដើមរបស់វាទេ លុះត្រាណាតែវាត្រូវបានគេយកមកច្នៃទៅជាផលិតផល សំរាប់ការប្រើប្រាស់របស់មនុស្ស ។

- **អត្តចរិតអេកូឡូស៊ី :** បរិស្ថាន និង ប្រព័ន្ធអេកូឡូស៊ីត្រូវតែបានថែរក្សាការពារ ព្រោះថាវាបានផ្តល់ នូវមធ្យោបាយក្នុងការទ្រទ្រង់ជីវិតនៅលើផែនដីនេះ ។

- **អត្តចរិតសោភ័ណភាព :** បរិស្ថានមានតំលៃជាសោភ័ណភាព ហើយតំលៃអរូបិយ៍របស់វាគឺ ចិត្ត សាស្ត្រ វិញ្ញាណ និងការលើកទឹកចិត្តដល់មនុស្ស ។

- **អត្តចរិតសីលធម៌ :** បរិស្ថាន និង ប្រព័ន្ធអេកូឡូស៊ីគឺជាលំនៅដ្ឋានរស់នៅរបស់សត្វលោក និងអ្វីៗ ដែលមានជីវិតទាំងអស់ ដែលត្រូវមានសិទ្ធិរស់នៅទីនោះ ។ ភារៈកិច្ចរបស់មនុស្សគឺត្រូវគោរព និងការពាររបស់ ដែលមានជីវិតទាំងអស់ និងទីជំរករបស់វា ។ លោកឈូម៉ាឃ័រ (Schumacher 1973) បានហៅអត្តចរិតនេះថាជា លក្ខណៈគោរពដល់ប្រពន្ធ័អេកូឡូស៊ី ។
~~~~~~~

យើងពិតជាឃើញថាអត្តចរិតទាំងអស់នេះនឹងនាំអោយមានចរិតផ្សេងៗរបស់មនុស្សចំពោះបរិស្ថាន មាន ចាប់តាំងពី ចរិតដែលមានលក្ខណៈគិតតែយកប្រយោជន៍ប្រើប្រាស់ដោយអ្នកដែលមានចរិតគិតតែប្រយោជន៍ រហូតដល់ការគោរពហួសហេតុដោយអ្នកមានចរិតសីលធម៌និយម ។

អ្នកអភិវឌ្ឍន៍ដោយនិរន្តរភាពប្រហែលជាត្រូវអនុវត្តន៍តាមអត្តចរិតណាមួយនៃអត្តចរិតទាំងបួនខាងលើនេះ ។

## អត្តចរិតរបស់អ្នកសេដ្ឋកិច្ចជាលក្ខណៈប្រពៃណី :

សេដ្ឋកិច្ច គឺជាវិទ្យាសាស្ត្រស្តីពីផលិតកម្ម និងការចែកចាយនូវទ្រព្យសម្បត្តិ ។ ក្នុងនាមជាវិទ្យាសាស្ត្រមួយ សេដ្ឋកិច្ច គឺបានគិតគូរពីប្រសិទ្ធិភាពខ្ពស់បំផុតនៃការចាត់ចែងធនធាន និងការចែកចាយទ្រព្យសម្បត្តិ (ប្រាក់ ទ្រព្យសម្បត្តិ) ក្នុងចំណោមប្រជាជន ។ សេដ្ឋកិច្ចគិតគូរតែពីថាតើកិច្ចខិតខំប្រឹងប្រែងណាមួយនោះបានផ្តល់ផលប្រយោជន៍ជាទឹកប្រាក់ដល់អ្នកដែលបានធ្វើនោះដែរឬទេ ដោយមិនមែនសំរាប់សង្គមទាំងមូលទេ ។

តំលៃនៃផលិតផលត្រូវបានកំណត់ដោយសម្ពាធនៃតំរូវការចំពោះផលិតផល ភាពសំបូររបស់វា និងលទ្ធភាពដែលអ្នកប្រើប្រាស់អាចចំណាយ ។ តំលៃនៃផលិតគឺមិនមានទំនាក់ទំនងដោយស្វ័យប្រវត្តិទៅនឹងតំលៃពិតរបស់វាចំពោះសង្គមទេ ។ ហើយបើករណីនេះវាអាចទៅជាដូច្នេះ នោះរបស់ដែលចាំបាច់ជាមូលដ្ឋានដូចជាទឹកស្អាត និងខ្យល់វានឹងត្រូវមានតំលៃថ្លៃជាងពេជ្រ ឬមាសយ៉ាងច្រើន ។ សេដ្ឋកិច្ចពុំបានគិតដល់តំលៃរបស់សហគមន៍ បុគ្គល ឬជនជាតិភាគតិចទេ ព្រោះថា វាជាវិទ្យាសាស្ត្រ ហើយមានលក្ខណៈដាច់ដោយឡែកពីកត្តាទាំងនោះ ។

អ្នកសេដ្ឋកិច្ចជាលក្ខណៈប្រពៃណី ច្រើនតែមានអត្តចរិតបែបគិតតែប្រយោជន៍ ចំពោះបរិស្ថាន ដោយយល់ឃើញថាធនធានធម្មជាតិពុំមានតំលៃដើមរបស់វាទេ លុះត្រាតែវាអាចត្រូវបានគេផលិត និងកែច្នៃទៅជាទំនិញដែលអាចលក់ដូរបាន ។ បរិស្ថានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីត្រូវបានគេគិតថាជាទំនិញដែលគេអាចធ្វើអាជីវកម្មដោយមិនបាច់បង់ថ្លៃ ។ មូលធនធម្មជាតិ គឺ ធនធានធម្មជាតិដែលមានសល់នៅក្នុងរយៈពេលណាមួយ គឺពុំត្រូវគេអោយតំលៃសេដ្ឋកិច្ចទេ ។ ហើយជាលទ្ធផល ប្រព័ន្ធអេកូឡូស៊ីជួយឧបត្ថម្ភដល់សេដ្ឋកិច្ចរបស់មនុស្សជាពិសេសអ្នកដែលទទួលផលប្រយោជន៍ពីការអភិវឌ្ឍន៍ណាមួយ ហើយដែលមិនត្រូវបានទូទាត់មកវិញពេញលេញដល់ការចូលរួមចំណែករបស់ធម្មជាតិទេ ។

យើងអាចចងចាំបានថា មនុស្សពុំបានផលិតអ្វីទាំងអស់ គេគ្រាន់តែបានកែច្នៃផលិតផលដំបូងរបស់ធម្មជាតិអោយក្លាយទៅជាទំនិញផ្សេងៗតែប៉ុណ្ណោះ ។ មនុស្សគឺជាអ្នកប្រើប្រាស់ទ្រង់ទ្រាយធំ ដែលប្រើប្រាស់នូវចំនួនដ៏ច្រើននៃថាមពលការីតខ្ពស់ដែលបានកែច្នៃដោយធម្មជាតិក្នុងរូបភាពជា រុក្ខជាតិ សត្វ ធនធានរ៉ែ និងទឹក ។

**ការធ្វើអោយតំលៃមាននៅអ្នកខាងក្រៅ :**

ដោយសារថាសេដ្ឋកិច្ចមូលធននិយម គឺគិតអំពីការរកចំណូលជាប្រាក់ វាគឺជាផលប្រយោជន៍របស់អ្នកសេដ្ឋកិច្ច ក្នុងការកាត់បន្ថយអោយតិចបំផុតនូវតំលៃនៃការទាញយក និងកែច្នៃធនធានធម្មជាតិ និងបង្កើនអោយខ្ពស់បំផុតនូវតំលៃលក់នូវផលិតផល ឬសេវាកម្ម ។ យន្តការដែលបានប្រើជាសកលក្នុងការសំរេចនូវគោលដៅនេះគឺការធ្វើអោយតំលៃមានទៅអ្នកខាងក្រៅយ៉ាងច្រើនតាមតែអាចធ្វើទៅបាននូវតំលៃលើធនធាន និងតំលៃផលិតកម្មនោះ ដូចជា ផ្ទេរតំលៃនេះតាមការដែលអាចធ្វើទៅបានទៅលើអ្នកដទៃ ដូចជារដ្ឋាភិបាល សហគមន៍ បុគ្គល អ្នកជំនាន់ក្រោយ ។ល។

ទស្សនៈដ៏ចង្អៀតចង្អល់នេះ បានឆ្លុះបញ្ចាំងនូវការបញ្ចុះតំលៃចំពោះការអភិវឌ្ឍន៍ដែលអាចកើតមានក្នុងរយៈពេលយូរឆ្នាំទៀតទៅពេលអនាគតដោយគេជ្រើសយកការទទួលខុសត្រូវតែក្នុងរយៈពេលខ្លីមួយតែប៉ុណ្ណោះ ។ ឧទាហរណ៍ នៅពេលដែលតំលៃកើតមានចំពោះគំរោងទំនប់ ដែលបណ្តាលមកពីការផ្លាស់ទីលំនៅរបស់សហគមន៍ អ្នកសេដ្ឋកិច្ចអាចគិតគូរតែពីតំលៃនៃការផ្លាស់ទីលំនៅដំបូងប៉ុណ្ណោះ ដោយគិតថាអ្វីៗវានឹងមានដំណើរការល្អ ។ ក្នុងស្ថានភាពជាក់ស្តែង បញ្ហាដែលទាក់ទងនឹងអ្នកដែលត្រូវជំលៀសចេញពីទីតាំងទំនប់ (ដូចជាប្រជាជនដែលត្រូវជំលៀសចេញដោយសារការសាងសងទំនប់ និងអាងទឹកជំនន់) អាចធ្លាក់ទៅដល់អ្នកជំនាន់ក្រោយទៀត ក្រោយពេលគេផ្លាស់ប្តូរទីលំនៅ ។ តំលៃនៃការចុះក្រីក្រ និងលទ្ធផលនៃជីវភាពរស់នៅដ៏ក្រលំបាករបស់ពួកគេនោះត្រូវធ្លាក់ទៅលើរដ្ឋាភិបាល សហគមន៍មូលដ្ឋាន និងសង្គមទូទៅ មិនមែនទៅលើអ្នកសាងសង់ទំនប់ទេ ។

ឧទាហរណ៍ផ្សេងៗទៀតនៃការធ្វើអោយតំលៃមានទៅអ្នកខាងក្រៅគឺ :

- នៅពេលដែលជី និងថ្នាំសំលាប់សត្វល្អិតត្រូវបានប្រើប្រាស់ក្នុងកសិកម្មទំនើប មិនមែនអ្នកលក់សារជាតិគីមី ហើយក៏មិនមែនអ្នកលក់ផលិតផលចំណីអាហារនោះជាអ្នកទទួលខុសត្រូវលើតំលៃនៃការខូចខាតទៅលើជលផល និងសុខភាពសាធារណៈដែលកើតឡើងដោយសារការធ្វើអោយក្រខ្វក់ទឹក ទឹកក្រោមដី ជម្ងឺរបស់កសិករ អ្នកប្រើប្រាស់ និងអ្នកជិតខាងដែលត្រូវបំពុលដោយសារសារជាតិគីមីទាំងនោះ ជម្ងឺរបស់ប្រជាជនដែលប្រើប្រាស់អាហារដែលមានជាតិថ្នាំសំលាប់សត្វល្អិត ការបាត់បង់គុណភាពដីរយៈពេលវែង ឬការបាត់បង់លំអងផ្កាដោយសារជាតិពុកស៊ុចនៃថ្នាំសំលាប់សត្វល្អិតនោះទេ ។ អ្នកផលិតសារជាតិគីមីបានធ្វើអោយតំលៃនោះមានទៅលើអ្នកខាងក្រៅ គឺថា ដោយទុកអោយអ្នកដទៃជាអ្នកទទួលរ៉ាប់រង ។

- តំលៃទៅអ្នកខាងក្រៅនៃទឹកក្រខ្វក់ដែលមិនបានសំអាត ដែលបញ្ចេញចោលដោយរោងចក្រទៅក្នុងទន្លេ រួមមានភាពក្រខ្វក់ដែលអាចធ្វើអោយងាប់ត្រីក្នុងតំបន់នោះ ធ្វើអោយក្រខ្វក់ដល់ទឹកសំរាប់ផឹករបស់សហគមន៍នៅខ្សែទឹកខាងក្រោម និងរំខានដល់ការប្រើប្រាស់ទន្លេសំរាប់ការលំហែរកំសាន្ត ដែលតំលៃទាំងអស់នោះត្រូវធ្លាក់ទៅលើអ្នកដទៃ ។

- នៅពេលដែលក្រុមហ៊ុនឈើហ៊ុបកាប់តែឈើប្រភេទមានតំលៃខ្ពស់ ប៉ុន្តែបានបំផ្លាញដល់ឈើ និងព្រៃដែលនៅសល់ផ្សេងទៀតនៅពេលដែលគេចូលទៅទីនោះ នោះគឺការធ្វើអោយតំលៃមានទៅអ្នកខាងក្រៅលើ

ធនធានដែលបាត់បង់ទាំងអស់ ដូចជាផលិតផលឈើដ៏ទៃទៀត រុក្ខជាតិហូប និងជាថ្នាំ សត្វ ធនធានទឹក គុណភាពដី ទីជំរក តំលៃសោភ័ណភាព និងលទ្ធភាពក្នុងការធ្វើទេសចរណ៍ ។ ទោះជានៅពេលដែលព្រៃត្រូវបានកាប់ និងឈើដែលអាចលក់បានត្រូវយកចេញហើយក៏ដោយ ធនធានដ៏ទៃទៀតបានខូចខាតទៅជាមួយគ្នា ហើយដែលជាការបាត់បង់រួមរបស់សង្គម ។ តំលៃនៃការបាត់បង់របស់វា គឺជាតំលៃរបស់សហគមន៍មូលដ្ឋាន និងប្រទេសជាតិ ។

ការធ្វើអោយតំលៃមានទៅអ្នកខាងក្រៅនូវតំលៃពិតរបស់ការអភិវឌ្ឍន៍ ធ្វើអោយរូបភាពនៃអត្រាតំលៃ-ផលប្រយោជន៍ខុសពីភាពពិតដើមរបស់វា ហើយដែលធ្វើអោយការអភិវឌ្ឍន៍នោះមើលទៅហាក់ដូចជាគួរឱ្យចាប់អារម្មណ៍ជាងភាពពិតរបស់វា ។ អត្តចរិតនេះគឺបានស្ថិតជាចំណុចខ្មៅមួយក្នុងការអនុវត្តន៍គោលការណ៍សេដ្ឋកិច្ចតាមលក្ខណៈប្រពៃណី ។ នេះគឺជាសញ្ញានៃគំនិតចង្អៀតចង្អល់ និងគ្មានមូលដ្ឋានច្បាស់លាស់ ។

ការអនុវត្តន៍សេដ្ឋកិច្ចហាក់ដូចជាពិនិត្យតែទៅលើបញ្ហារយៈពេលខ្លី ដោយមើលរំលងផលប៉ះពាល់ដែលអាចកើតឡើងក្នុងរយៈពេលវែងនៃការប្រើប្រាស់ធនធាន ដោយយល់ថា សេដ្ឋកិច្ចទីផ្សារសេរីនឹងឆ្លើយតទៅនឹងការខ្វះខាតណាមួយក្នុងពេលអនាគតក្នុងការផ្គត់ផ្គង់វត្ថុធាតុដើម ដោយត្រូវរកធនធានផ្សេងៗទៀត ឬវត្ថុធាតុជំនួសផ្សេងៗទៀត ។ អ្នកសេដ្ឋកិច្ចបែបប្រពៃណីបានប្រកាសថា មនុស្សយើងតែងតែរកឃើញនូវធនធានធម្មជាតិបំរុងថ្មីៗដូចជា ប្រេង រ៉ែ ត្បូងថ្ម និងឈើ នៅពេលណាយើងត្រូវការ ដូចនេះពុំចាំបាច់ព្រួយបារម្ភអំពីការខ្វះខាតដ៏ធ្ងន់ធ្ងរនាពេលអនាគតទេ ។

គោលការណ៍សេដ្ឋកិច្ចមួយទៀត គឺថាគឺមិនមែនអ្នកជំនាន់បច្ចុប្បន្ននេះទេ ដែលត្រូវទទួលខុសត្រូវមើលថែទាំដល់អ្នកជំនាន់ក្រោយៗនោះ ។ អត្តចរិតនេះមានគំនិតថាអ្នកជំនាន់ក្រោយពិតជាអាចមានលទ្ធភាពពេញលេញក្នុងការមើលថែទាំខ្លួនឯង ហើយក្នុងករណីខ្លះយើងមិនបានដឹងផងថាអ្វីនឹងសំខាន់សំរាប់គេ ដូចនេះហេតុអ្វីយើងត្រូវថែរក្សានូវធនធានដ៏កំរក្នុងពេលនេះ ? មតិមួយដែលទាក់ទងនឹងសេដ្ឋកិច្ចគឺថាគោលការណ៍ការពារនោះគឺវាហាក់ដូចជាហួតចត់ខ្លាំងពេក ហើយជាជំរើសមួយដែលមានតំលៃថ្លៃសំរាប់ពេលបច្ចុប្បន្ន ។ ឧទាហរណ៍ ដូចជាហេតុអ្វីត្រូវចំណាយប្រាក់ដ៏ច្រើនទៅលើដំណើរឡើងនៃកំដៅដ៏យឺតក្នុងបរិយាកាស នៅពេលដែលវាពុំទាន់ឃើញអ្វីបញ្ជាក់ថាបាតុភូតនោះវាពិតប្រាកដផង ។ វាជាការល្អណាស់ ក្នុងការរង់ចាំរហូតដល់មានការបង្ហាញតាមលក្ខណៈវិទ្យាសាស្ត្រច្បាស់លាស់ចំពោះព្រឹត្តការណ៍ដ៏ភ័យខ្លាចនោះ ។ ប្រសិនបើថ្ងៃណាមួយមានការបញ្ជាក់ច្បាស់ នៅពេលនោះ វិទ្យាសាស្ត្រ និងបច្ចេកទេសនឹងមានភាពជឿនលឿន ហើយដែលអាចរកដំណោះស្រាយប្រកបដោយប្រសិទ្ធភាពតំលៃមួយ ។

អ្នកសេដ្ឋកិច្ចមូលធនបានពោលអះអាងថា ផ្លូវដែលល្អបំផុតក្នុងការទប់ទល់នឹងភាពក្រីក្រគឺការពង្រីកមូលដ្ឋានសេដ្ឋកិច្ចនៃប្រទេស ហើយទ្រព្យសម្បត្តិនឹងធ្លាក់ទៅដល់អ្នកក្រនៅពេលដែលគ្រប់សមាជិកទាំងអស់របស់សង្គមក្លាយជាអ្នកមាន ។ ក្នុងរបៀបនេះបញ្ហាបរិស្ថានក៏នឹងត្រូវបានដោះស្រាយផងដែរព្រោះថាអ្នកក្រីក្រ នឹងមិនរុករកធនធានទៀតទេ ។ អនាម័យ សុខភាព ការសិក្សា និងកំរិតសង្គមនឹងត្រូវបានបង្កើនក្នុងពេលតែមួយនោះ

នៅពេលដែលមានទ្រព្យសម្បត្តិ ។ សក្ខីភាពនៃគុណវិបត្តិនៃអំណះអំណាងនេះអាចពិនិត្យឃើញនៅក្នុងប្រទេសសមាជិកអាងទន្លេមេគង្គនិមួយៗ ដោយឃើញយ៉ាងច្បាស់ថា ពុំមែនមនុស្សទាំងអស់បានទទួលផលប្រយោជន៍ពីការរីកចំរើនក្រោមរូបភាពសេដ្ឋកិច្ចបែបលក្ខណៈប្រពៃណីនោះទេ ។

## លទ្ធផលនៃសេដ្ឋកិច្ចជាលក្ខណៈប្រពៃណី

គោលការណ៍ និងការអនុវត្តន៍សេដ្ឋកិច្ចបែបប្រពៃណីបាននាំមកនូវការរីករាលដាលនៃការខូចខាតធនធានធម្មជាតិក្នុង MRB ដែលនាំអោយមានការថយចុះនូវមូលធនធម្មជាតិដែលមានសំរាប់មនុស្សបច្ចុប្បន្ន និងជំនាន់ក្រោយ ។ អត្តចរិតគិតខ្លីរបស់គោលគំនិតសេដ្ឋកិច្ចបែបប្រពៃណី នាំអោយមានការគិតគូរដល់ការកាត់បន្ថយនូវតំលៃនៃការដកយកធនធានដោយពុំបានគិតដល់ការថែរក្សាសំរាប់រយៈពេលវែងឡើយ ។

ក្នុងកំរិតមូលដ្ឋាន និងកំរិតពិភពលោក ការអភិវឌ្ឍន៍សេដ្ឋកិច្ចមានបំណងផ្តល់ផលប្រយោជន៍ដល់អ្នកដែលមានទ្រព្យសម្បត្តិរួចទៅហើយ ចំណែកឯអ្នកក្រត្រូវទុកអោយនៅទទួលនូវតំលៃក្នុងកំរិតមិនយុត្តិធម៌មួយ ។ អត្តចរិតសេដ្ឋកិច្ចទាំងនេះបង្ហាញពីគុណវិបត្តិរបស់មនុស្ស នោះគឺសេចក្តី លោភ ការភ័យខ្លាច និងការស្រេចឃ្លានអំណាច ។

## អត្តចរិតរបស់ប្រជាជនក្រីក្រ

ផ្នែកនេះគឺមិនមែនធ្វើការកាត់ក្តីលើអត្តចរិតរបស់ប្រជាជនក្រីក្រទេ ប៉ុន្តែជាការបង្ហាញនូវភាពពិតខ្លះៗ ។ ភាពក្រីក្រគឺជាស្ថានភាពនៃភាពគ្មានអំណាច ។ ប្រជាជនក្រីក្រធ្វើសកម្មភាពដើម្បីឆ្លើយតបនឹងតំរូវការជាមូលដ្ឋានសំរាប់ជីវិតប្រចាំថ្ងៃរបស់ពួកគេ ហើយអ្នកដែលមិនមែនជាអ្នកក្រនោះពុំមានសិទ្ធិវាយតំលៃថា សកម្មភាពរបស់អ្នកក្រនោះល្អ ឬអាក្រក់ឡើយ ។

## ឋានានុក្រមនៃសេចក្តីត្រូវការរបស់លោក ម៉ាស្លូវ (Maslow)

លោក អាប្រាហាម ម៉ាស្លូវ ជាអ្នកចិត្តសាស្ត្រអាមេរិកកាំង បានធ្វើការវិភាគលើកត្តាជំរុញទឹកចិត្ត និងចរិតរបស់មនុស្សដោយផ្អែកលើការវាយតំលៃតំរូវការខ្វះខាត និងតំរូវការរីកចំរើន ។ គាត់បានបង្កើតនូវឋានានុក្រមនៃសេចក្តីត្រូវការដែលជួយដល់ការពន្យល់ថា តើហេតុអ្វីយើងមានចរិតបែបណាមួយនោះ នៅពេលយើងប្រឈមមុខនឹងស្ថានភាពផ្សេងៗគ្នាក្នុងជីវិត ។ កំរិតត្រូវការទាបបំផុតក្នុងឋានានុក្រម គឺត្រូវតែបានទទួលជាមុនសិនមុននឹងបុគ្គលម្នាក់អាចឈានទៅរកកំរិតត្រូវការបន្ទាប់នោះ ។ តំរូវការដែលខ្វះខាតគឺជាកត្តាសំខាន់បំផុត ។ តំរូវការសំរាប់រីកចំរើន គឺជាប្រយោជន៍នៃមនុស្សមួយភាគតូចនៃប្រជាជនក្នុងពិភពលោក ។

សំរាប់ប្រជាជនដែលក្រីក្របំផុត ការរស់នៅជាមូលដ្ឋាន និងសន្តិសុខគឺជាបញ្ហាសំខាន់ ។ ពួកគេត្រូវតែស្វែងរកអាហារ និងទឹកគ្រប់គ្រាន់សំរាប់រស់នៅពីមួយថ្ងៃទៅមួយថ្ងៃ និងរកជំរកបែបណាក៏ដោយដែលអាច

ឱ្យគេជ្រកគេចពីសត្វ និងអាកាសធាតុបាន ។ គេពុំបានយកចិត្តទុកដាក់ទៅលើអ្វីទៀតទេ លុះត្រាតែគេបានទទួលនូវតំរូវការទាំងនេះជាមុនសិន ហើយអ្វីៗដែលគេបានធ្វើគឺត្រូវបានជំរុញដោយគោលបំណងទាំងនេះ គឺថាទីមួយការរស់នៅហើយបន្ទាប់មក សន្តិសុខ ។ ការអភិរក្សបរិស្ថាន ឬការព្រួយបារម្ភពីសុខភាពប្រព័ន្ធអេកូឡូស៊ីគឺមិនមែនជាផ្នែកមួយនៃសតិសម្បជញ្ញៈរបស់ប្រជាជនក្រីក្រទេ ទាំងនោះគឺជាកំរិតតំរូវការរីកចំរើនខ្ពស់ទៀតដែលមិនអាចឈានទៅដល់ដោយអ្នកដែលត្រូវការតែការរស់នៅសិននោះទេ ។

សង្គមជាច្រើន នៅពេលដែលនៅក្រីក្រនៅឡើយ បានបំពេញនូវកំរិតគ្រប់គ្រាន់នៃការចិញ្ចឹមខ្លួន និងសន្តិសុខជាមុនសិនមុននឹងឈានទៅប្រាថ្នារកសេចក្តីត្រូវការពីរបន្ទាប់ទៀត គឺការចង់ក្លាយខ្លួនជាសមាជិក និងបានទទួលស្គាល់ និងគោរពពីសហគមន៍មូលដ្ឋាន ។ នៅក្នុងកំរិតនៃការអភិវឌ្ឍន៍នេះ អាចអោយយើងគិតដល់ការព្រួយបារម្ភពីបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី ហើយដែលអាចមានវិធានការអនុវត្តន៍មួយ ដើម្បីធានាដល់ការបន្តការរស់នៅដោយមានសុខភាព និងសុខមាលភាព ។

ការបំពេញបំណងនៃសេចក្តីត្រូវការរីកចំរើន គឺចាត់ទុកជាភាពរុងរឿងនៃសហគមន៍ដែលមានទ្រព្យសម្បត្តិមួយ ដែលគេយកចិត្តទុកដាក់ដល់ផលប្រយោជន៍ផ្នែក លំហែកាយ និងសោភ័ណភាព ដែលក្នុងកំរិតនោះការការពារថែរក្សាធម្មជាតិអាចធ្វើទៅបាន ទោះជាវាមិនមែនជៀសមិនរួចក៏ដោយ ។ អ្នកដែលជ្រើសរើសដើរតាមមាគ៌ាសាសនាអាចស្វែងរកកំរិតតំរូវការខ្ពស់ថែមទៀត ទោះជាសំរាប់ពួកគេនោះ ពុំទាន់បានទទួលនូវតំរូវការនៃការខ្វះខាតជាមូលដ្ឋានជាមុនសិនក៏ដោយ ។

## ទ្រឹស្តីនៃដែនកំណត់

### គោលការណ៍របស់លោកម៉ាលធូសាន (Malthusian) :

នៅពេលដែលប្រជាជនក្នុងពិភពលោក រួមទាំងប្រជាជនក្នុង MRB កើនឡើង គឺវាមានការកើននូវសម្ពាធនៃការរកចំណីអាហារ និងទីជំរកទៅលើបរិស្ថាននៃធនធានធម្មជាតិ ។ លោក **តូម៉ាស់ ម៉ាលធូស** បានចាត់ទុកកំណើនប្រជាជនថាជាការគំរាមកំហែងដល់ការរស់នៅរបស់មនុស្ស ដោយសារចំនួន ដី ទឹក និងអាហារដែលមាននោះមានកំណត់ ។ ថ្មីៗនេះ ភាពក្រីក្រ គឺមានទាក់ទងនឹងអត្រាកំណើតដ៏ខ្ពស់ ការសិក្សាទាបខ្វះអនាម័យ ចំណីអាហារ និងសុខភាព និងអត្រាស្លាប់ខ្ពស់ ។ កត្តាទាំងអស់នេះមានទាក់ទងគ្នា ។ ដូចនេះការកាត់បន្ថយភាពក្រីក្រ គឺជាការចាំបាច់ ប្រសិនបើក្នុងពេលអនាគតនៅមានការកើនឡើងនូវចំនួនប្រជាជន ។

## សោកនាដកម្មលើធនធានសាធារណៈ

នៅពេលដែលធនធានត្រូវកាន់កាប់ដោយសហគមន៍ ឬដោយសមត្ថកិច្ចពីចំងាយដូចជារដ្ឋាភិបាលជាដើម នោះតាមទ្រឹស្តីសោកនាដកម្មលើធនធានសាធារណៈរបស់លោក **ហាឌីន** គឺថា វាជាធម្មតា បុគ្គលម្នាក់ៗនឹងខំយកប្រយោជន៍រៀងៗខ្លួន ដោយខិតខំបង្កើននូវចំណែករបស់ខ្លួនលើទិន្នផលពីធនធាន ព្រោះថាតំលៃនោះត្រូវបានរួម

ចំណែកដោយសហគមន៍ទាំងមូល ចំណែកឯការចំណេញគឺបានមកបុគ្គលនោះតែម្នាក់ឯង ។ នៅពេលដែលប្រជាជនអ្នកប្រើប្រាស់កើនឡើង គ្រោះថ្នាក់នៃការប្រើប្រាស់ហួសប្រមាណលើធនធានក៏កើនឡើងដែរ ។ និក្ខេបបទរបស់លោក **ហាឌីន** ឆ្លុះបញ្ចាំងថា អ្នកប្រើប្រាស់ធនធានរួមគឺពុំមានសមត្ថភាពនឹងធ្វើការរួមគ្នា ដើម្បីគោលបំណងអភិវឌ្ឍន៍ដោយនិរន្តរភាពទេ ។

តាមនិយមន័យប្រជាជនក្រីក្រពុំមានកម្មសិទ្ធិ ដីធ្លី ឬទ្រព្យសម្បត្តិទេ ហើយត្រូវរស់នៅ និងធ្វើការលើដីដែលជាកម្មសិទ្ធរបស់អ្នកដទៃ ឬក៏ដីដែលមិនមែនជារបស់អ្នកណាម្នាក់នោះ ។ តាមការរួមបញ្ចូលគ្នានៃការចង់រស់នៅនៃឋានន្តរក្រមនៃតំរូវការរបស់លោក **ម៉ាស្លូវ** និង សោកនាដកម្មលើធនធានរួមរបស់លោក **ហាឌីន** វាជាធម្មតា នឹងមានការប្រើប្រាស់ធនធានទាំងនោះដោយអស់ពីលទ្ធភាពដែលអាចធ្វើទៅបាន ។ ដោយសារគេគ្មានការធានាណាថា ដីទាំងនោះនឹងទុកសំរាប់ពួកគេនាពេលអនាគតនោះ គឺវាគ្មានការលើកទឹកចិត្តណាដល់ប្រជាជនក្រីក្រ ដើម្បីចាត់ទុកធនធានទាំងនោះជាទ្រព្យសម្បត្តិ ហើយថែរក្សាការពារទុកសំរាប់ពួកគេទេ ។

## សង្ខេបផលប៉ះពាល់នៃសេដ្ឋកិច្ចខាលក្ខណៈប្រពៃណី

តើយើងត្រូវធ្វើយ៉ាងដូចម្តេចជាមួយរូបភាពដ៏ស្រងេះស្រងោចខាងលើនេះ ? វាហាក់ដូចជាលេចចេញថាធម្មជាតិរបស់មនុស្សជាមូលដ្ឋានដូចដែលមានឆ្លុះបញ្ចាំងក្នុងទ្រឹស្តីសេដ្ឋកិច្ចបែបប្រពៃណី និងអ្វីៗដែលកំពុងកើតមាននោះគឺកំពុងប្រឆាំងនឹងលទ្ធភាពអភិវឌ្ឍន៍ដោយនិរន្តរភាព ។ ករណីនេះប្រហែលជាការពិត ។ លុះត្រាតែយើងបានរកឃើញនូវគំរូផ្សេងណាមួយដែលអាចផ្លាស់ប្តូរប្រព័ន្ធសេដ្ឋកិច្ច និងសង្គមដែលទាក់ទងនិងភាពក្រីក្រ និងបញ្ហាពាក់ព័ន្ធ និងអត្រាកំណើត អក្ខរកម្ម ជម្ងឺ និងរយៈពេលរស់នៅទាប និងការនាំទៅរកសមភាព និងដំណោះស្រាយដោយយុត្តិធម៌ បើពុំនោះទេការអភិវឌ្ឍន៍ នឹងនៅតែបន្តផ្តល់ផលប្រយោជន៍ដល់មនុស្សមួយចំនួនតូច ហើយឋិតលើការចំណាយរបស់មនុស្សភាគច្រើនដដែល ។

## ជំរើសផ្សេងៗក្រៅពីសេដ្ឋកិច្ចបែបប្រពៃណី

ចំណុចខាងក្រោមនេះគឺជាជំរើសមួយចំនួន ដែលអាចបង្កើតជាមូលដ្ឋានសំរាប់ការអនុវត្តន៍ផ្សេងៗទៀតនៃទ្រឹស្តីសេដ្ឋកិច្ច ដែលអាចជួយដល់ការអភិវឌ្ឍន៍ដោយនិរន្តភាព ។

១- ដូចមានក្នុងកម្មវិធី Agenda 21 និងក្នុងគោលការណ៍បរិស្ថានរបស់គណៈកម្មកាទន្លេមេគង្គ ប្រជាជនត្រូវជាកត្តាចំបងដែលត្រូវយកចិត្តទុកដាក់ ជាពិសេសលើសុខភាព សុខមាលភាព ការសិក្សា សេដ្ឋកិច្ច និងសេចក្តីត្រូវការផ្នែកសង្គម ។

២- ជំនួសឱ្យគំរោងធំៗយើងអាចអនុវត្តន៍នូវបច្ចេកវិទ្យា និងជំនាញដែលសមស្របតាមតំរូវការក្នុងមូលដ្ឋាន ដើម្បីធ្វើឱ្យអ្នកដែលបង់ប្រាក់អាចទទួលបាននូវផលប្រយោជន៍ ។ លោក **ឈូមាឃើរ** (Schumacher 1973) បានពណ៌នាករណីនេះថាជា "បច្ចេកវិទ្យាដែលយល់មុខមនុស្ស" ព្រោះថាវាបានផ្តល់នូវស្ថានភាពការងារ

ដែលការពារដល់កិត្តិយសរបស់មនុស្ស និងតំលៃរបស់ខ្លួន ហើយនិងបង្កើននូវផលិតភាព ។ ផ្ទុយទៅវិញ បច្ចេកវិទ្យាខ្ពស់ៗ និងការអភិវឌ្ឍន៍ធំៗមិនបានយកចិត្តទុកដាក់ដល់ប្រជាជនក្រីក្រទេ ព្រោះថាគេពុំមានសិទ្ធិខាងចំណេះដឹងដើម្បីធ្វើការជាមួយ ។ ហើយជាលទ្ធផលច្រើនមានអត្រាគ្មានការងារធ្វើខ្ពស់ មានការហូរចូលទៅទីក្រុងដែលមានមនុស្សច្រើនទៅហើយ មានការចុះថយក្នុងទីជនបទ និងគ្មានរបៀបរៀបរយក្នុងសង្គម ។

៣. ថែរក្សាធនធានធម្មជាតិចំពោះតំលៃសេដ្ឋកិច្ច និងតំលៃផ្សេងៗទៀតដែលទាក់ទងនោះគឺការទទួលស្គាល់ថា ប្រព័ន្ធអេកូឡូស៊ី :

- ផលិត និងកែច្នៃធនធានអោយទៅជាផលិតផលមានតំលៃមួយសំរាប់ការប្រើប្រាស់របស់មនុស្ស ជាអាហារ ភេសជ្ជៈ ថ្នាំពេទ្យ ជំរក វត្ថុធាតុដើម សំរាប់ការផលិត និងសាងសង់ សំលៀកបំពាក់ សិល្បៈ និងវត្ថុផ្សេងៗជាច្រើនទៀត ។

- ធ្វើអោយស្អាតដល់ ខ្យល់ និងទឹក ដោយប្រសិទ្ធភាព និងក្នុងខ្នាតធំមួយជាងប្រព័ន្ធរបស់មនុស្ស ។

- ក្នុងទំរង់ជា ដីសើម បានជួយដល់ការការពារទឹកជំនន់ និងសេវាកម្មសំអាតទឹក ជាកន្លែងបង្កកំណើតដល់ប្រភេទសត្វក្នុងទឹក និងលើដីជាច្រើន ជាជំរក និងកន្លែងស្នាក់នៅបណ្តោះអាសន្នសំរាប់សត្វស្លាបមួយចំនួនធំ

- អាចបង្កើតឡើងវិញដោយខ្លួនឯង ប្រសិនបើមានកន្លែង និងក្នុងរយៈពេលណាមួយ

- ប្តូរស្ថានភាពអាកាសធាតុ( ឧទាហរណ៍ព្រៃឈើគឺជាប្រភពខ្យល់ត្រជាក់ដោយមិនបាច់ចំណាយប្រាក់ )

- ផ្តល់នូវផលប្រយោជន៍ផ្នែកលំហែកាយ និងសោភ័ណភាព និងស្មារតី ដល់ប្រជាជនមូលដ្ឋាន និងអ្នកទេសចរណ៍

- គឺជាទីជំរកដល់សត្វមានជីវិតទាំងអស់នៅលើផែនដី ។

៤. ការតស៊ូដើម្បីអោយមានតុល្យភាពរវាងការគ្រប់គ្រងធនធានថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ដើម្បីការពារដល់សិទ្ធិរបស់សហគមន៍ និងផលប្រយោជន៍រួម ។

៥. រៀបចំបង្កើតមធ្យោបាយដើម្បីផ្តល់កម្មសិទ្ធ ដីធ្លី ការជួល ឬសិទ្ធប្រមូលផលដល់ប្រជាជនមូលដ្ឋានដោយមានការប្រុងប្រយត្ន័ ដើម្បីធានាដល់ការចែកចាយស្មើគ្នា ។

៦. អនុវត្តនូវការគិតគូរតំលៃដ៏ពេញលេញនៃគំរោងអភិវឌ្ឍន៍ រួមទាំងកត្តាខាងក្រៅ និងតំលៃវដ្តជីវិតនៃការប្រើប្រាស់ធនធាន និងទំនិញដែលបានផលិត ។

## ទ្រព្យសម្បត្តិជាមូលធន

សេដ្ឋកិច្ចជាលក្ខណៈប្រពៃណីទទួលស្គាល់តែមូលធនជាហិរញ្ញវត្ថុ ដែលជាចំនួនសរុបនៃទ្រព្យសម្បត្តិជាសាច់ប្រាក់ ទ្រព្យសម្បត្តិ ឧបករណ៍ និងកម្មសិទ្ធដទៃទៀតដែលបុគ្គល សហគមន៍ អង្គភាព ក្រុមហ៊ុន ប្រទេសជាតិមានតែប៉ុណ្ណោះ ។ ដើម្បីអោយការអភិវឌ្ឍន៍ដោយនិរន្តរភាពមានជោគជ័យ ការគិតគូរសរុបផ្នែកសេដ្ឋកិច្ចថ្មីមួយដែលទទួលស្គាល់នូវមូលធនបែបផ្សេងៗទៀតគឺជាការចាំបាច់ដូចជា :

- **មូលធនធម្មជាតិ** ៖ ធនធានបរិស្ថានមាន ព្រៃឈើ ទឹក ខ្យល់ ដី ត្រី និងរ៉ែដែលកត្តានិមួយៗនោះមានតំលៃដើមរបស់វាក៏ដូចជាការផ្តល់នូវផលិតផលដែលចាំបាច់សំរាប់ការរស់នៅ និងសុខុមាលភាពរបស់មនុស្ស ។

- **មូលធនសង្គម** ៖ ទំនាក់ទំនងនៃការជឿទុកចិត្ត និងកិច្ចសហប្រតិបត្តិការ ដែលនាំអោយក្លាយជាសមាជិកក្នុងក្រុមរៀបរយ និងមិនរៀបរយណាមួយ និងបណ្តាញដែលនាំអោយប្រជាជនអាចធ្វើការរួមគ្នា និងការងាររួមគ្នា និងការដែលអាចទាក់ទង និងមានឥទ្ធិពលក្នុងស្ថាប័ន និងសេវាកម្មណាមួយនោះ ។ ច្បាប់រៀបរយ (ច្បាប់ និង ជំនឿសាសនា) និងច្បាប់មិនរៀបរយ (ទំនៀមទំលាប់ តំលៃវប្បធម៌ និង ក្រិត្យក្រម) សុទ្ធតែជាមូលធន សង្គមមួយផងដែរ ។

- **មូលធនមនុស្ស** ៖ បណ្តុំវវាងជំនាញ ចំណេះដឹង ជំនឿ អត្តចរិត លទ្ធភាព ធ្វើការងារ និងសុខភាពល្អ គឺជាកត្តានាំអោយប្រជាជនអាចប្រកបរបររស់នៅ និងចូលរួមចំណែកក្នុងសង្គមជាតិ ។

- **មូលធនរូបសាស្ត្រ** ៖ គឺជាមូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធ និងផលិតផលដែលត្រូវការចាំបាច់សំរាប់ការរស់នៅ ដូចជាការដឹកជញ្ជូន ទឹក អនាម័យ ទីជំរក ថាមពល និងសេវាកម្មផ្សេងៗទៀត ។

- **មូលធនហិរញ្ញវត្ថុ** ៖ គឺជាទ្រព្យសម្បត្តិ និងកម្មសិទ្ធដីធ្លី ប្រាក់ឈ្នួល ប្រាក់សន្សំ ឥណទាន ប្រាក់ជំនួយ ប្រាក់កម្ចី និងប្រាក់ជំនួយឥតសំណង និងការបណ្តាក់ទុន ។

ដើម្បីសំរេចបាន នូវការអភិវឌ្ឍន៏ដោយនិរន្តរភាពដ៏ពិតប្រាកដត្រូវគិតបញ្ចូលប្រភេទនៃមូលធនទាំងនេះទៅក្នុងគំរោងការ និងលទ្ធផលដែលបានត្រួតពិនិត្យ និងវាស់ស្ទង់ ។

## គោលការណ៍របស់ព្រះពុទ្ធសាសនាចំពោះបរិស្ថាន

គោលការណ៍អភិវឌ្ឍន៏ដោយនិរន្តរភាពដែលបានលើកឡើង វាហាក់មានភាពស្របគ្នាច្រើនទៅនឹងជំនឿសាសនាព្រះពុទ្ធដែលបានអនុវត្តន៏ក្នុងប្រទេសជាសមាជិក MRB ។ គោលគំនិតសាសនាព្រះពុទ្ធ គោរពដល់ចង្វាក់ធម្មជាតិ ភាពសុខសាន្ត និងភាពទាក់ទងគ្នារវាងរបស់មានជីវិតទាំងអស់ ភាពស្របគ្នានៃមនុស្សជាមួយធម្មជាតិ និងការទទួលខុសត្រូវរបស់គេដើម្បីរស់នៅដោយសុខសាន្ត ដោយមានអត្តចរិតមិនឃោរឃៅហើយដឹងគុណ និងគោរពដល់របស់មានជីវិតទាំងអស់ ។ គោលគំនិតសាសនាព្រះពុទ្ធទទួលស្គាល់ថា បរិស្ថានធម្មជាតិផ្តល់នូវប្រព័ន្ធទ្រទ្រង់ជីវិតដែលត្រូវតែចិញ្ចឹមថែទាំ ដែលផ្ទុយអត្តចរិតលោកខាងលិច ដែលគិតតែផ្តល់អំណាចដ៏ងងឹតងងល់ដល់មនុស្សហើយគ្របដណ្តប់លើធម្មជាតិ ។ ជំនឿមួយក្រោយនេះបានជំរុញដល់ការបំផ្លិញបំផ្លាញដល់ប្រព័ន្ធអេកូឡូស៊ីហើយមានចរិតចង់គ្រប់គ្រង ជាជាងការធ្វើការងារក្នុងដំណើរការនៃធម្មជាតិ ។

សេដ្ឋកិច្ចក្នុងន័យព្រះពុទ្ធសាសនាបានអោយតំលៃទៅលើការរីកចំរើនតែលើចំណុចដែលគ្រប់គ្រាន់ ដែលក្នុងនោះបុគ្គលម្នាក់ៗប្រាថ្នាប្រើប្រាស់ធនធានអោយល្អបំផុត ដែលផ្ទុយពីសេដ្ឋកិច្ចបែបប្រពៃណីដែលចង់ប្រើប្រាស់អោយបានច្រើនបំផុត ។ គោលគំនិតព្រះពុទ្ធសាសនាអោយតំលៃលើការថែរក្សា កាត់បន្ថយ ការប្រើឡើងវិញ និងប្រើជាប្រយោជន៏ផ្សេងៗទៀតនូវសម្ភារៈផ្សេងៗ ដើម្បីអោយធម្មជាតិត្រូវបានគោរព ហើយមិនត្រូវបានរំលោភ

និងធ្វើអាជីវកម្មលើ ។ ទាំងអស់នេះគឺឋិតក្នុងផ្លូវនៃ "សិទ្ធនៃការរស់នៅ" ដែលអាចជាកត្តាស្ម័យសត្វដ៏សមស្រប មួយចំពោះការអភិវឌ្ឍន៍ដោយនិរន្តភាព ។

ជារួម សីលធម៌សាសនាព្រះពុទ្ធ គឺស្របគ្នាជាមួយនឹងគោលការណ៍នៃការអភិវឌ្ឍន៍ដោយនិរន្តភាព ។

## ការវាស់ស្ទង់នូវកិច្ចដំណើរការឆ្ពោះទៅរកការអភិវឌ្ឍន៍ដោយនិរន្តរភាព

សន្ទស្សន៍ផ្សេងៗនៃការអភិវឌ្ឍន៍ដោយនិរន្តភាពត្រូវបានបង្កើតឡើងដោយភ្នាក់ងារជាច្រើន ។ ការបង្កើតរបស់ភ្នាក់ងារចំនួនពីរដែលនឹងត្រូវរៀបរាប់សង្ខេបនៅពេលនេះគឺ សន្ទស្សន៍អភិវឌ្ឍន៍ធនធានមនុស្ស (HDI) របស់កម្មវិធីអភិវឌ្ឍន៍របស់សហប្រជាជាតិ (UNDP) និង បារ៉ូម៉ែត្រនៃនិរន្តភាព របស់សហភាពអន្តរជាតិដើម្បីការការពារធម្មជាតិ និងធនធានធម្មជាតិ (IUCN) ។ សន្ទស្សន៍ទាំងពីរនេះបានទាត់ចោលនូវការវាស់ស្ទង់លើភាពចំរើនរុងរឿងតាមលក្ខណទំនៀមទំលាប់ទៅលើផលិតផលជាតិសរុប (GDP) ដែលផ្អែកទៅលើសេដ្ឋកិច្ចបែបប្រពៃណី និងដែលផ្តោតជាពិសេសទៅលើតែទ្រព្យសម្បត្តិជាសម្ភារៈ ។ GDP បានលុបចោលនូវការគិតគូរផ្នែកខាងក្រៅ និងបញ្ហាដែលថាតើទ្រព្យសម្បត្តិនោះត្រូវបានចែកចាយស្មើគ្នា ឬក៏ទ្រព្យសម្បត្តិនោះកើតឡើងពីរបស់ចាំបាច់ ឬទំនិញមានប្រយោជន៍ ឬក៏គ្រាន់តែជារបស់កំប៉ិចកំប៉ុក ឬយ៉ាងណា ។ ទោះជានៅក្នុង GDP ក៏គ្មានការគិតគូរដល់ "សេដ្ឋកិច្ចសំរាប់ការថែទាំ" គឺការងារដែលមិនបានផ្តល់កំរៃនៃការថែទាំមនុស្សចាស់ អ្នកជម្ងឺ និងកុមារ សេវាកម្មសហគមន៍ និងចំណីអាហារដែលដាំដុះសំរាប់ការប្រើប្រាស់ក្នុងគ្រួសារផ្ទាល់ទេ ។ អង្គការសហប្រជាជាតិបានប៉ាន់ស្មានថាសេដ្ឋកិច្ចដែលមិនបានចំណាយថ្លៃនេះបានចូលរួមចំណែកគិតជាប្រាក់ចំនួន ១៦ កោដិ៍ ដុល្លាអាមេរិកក្នុងមួយឆ្នាំ ។

## សន្ទស្សន៍អភិវឌ្ឍន៍មនុស្សរបស់ UNDP

សន្ទស្សន៍នេះ ដែលបានក្លាយទៅជាការប្រើប្រាស់ និងធ្វើរបាយការណ៍យ៉ាងទូលំទូលាយនោះ បានផ្តោតទៅលើសុខុមាលភាពមនុស្សជាគោលដៅនៃការអភិវឌ្ឍន៍ ដោយយកប្រជាជនជាកត្តាសំខាន់នៃការផ្លាស់ប្តូរសេដ្ឋកិច្ច និងនយោបាយ ។ លក្ខខណ្ឌ័នៃគោលការណ៍បីត្រូវបានវាស់ស្ទង់នោះគឺ រយៈពេលនៃជីវិតរស់នៅ ការសិក្សា និងចំណូល ។ ដោយរួមបញ្ចូលនូវការគិតគូរផ្សេងៗទៀតក្រៅពីផ្នែកហិរញ្ញវត្ថុ សន្ទស្សន៍នេះមានគោលដៅវាយ-តំលៃលើជីវភាពរស់នៅជាទូទៅ គឺមិនមែនតែជីវភាពរស់នៅជាមធ្យមក្នុងប្រទេសមួយដែលផ្តោតទៅលើតែតួលេខ GDP នោះទេ ។ ក្នុងការចាត់ថ្នាក់ គ្រប់លក្ខខណ្ឌ័ HDI ទាំងអស់នោះត្រូវបានគេគិតគូរ ដើម្បីដាក់លេខសំរាប់ចាត់ថ្នាក់ដល់កំរិតអភិវឌ្ឍន៍របស់ប្រទេស ។

លក្ខខណ្ឌ័ទី ១ គឺរយៈពេលនៃជីវិតរស់នៅ ដែលគឺជាសន្ទស្សន៍នៃចំណីអាហាររួមរបស់ប្រជាជន សុខភាព និងសុខុមាលភាព ។ នៅពេលដែលស្ថានភាពរស់នៅរបស់ប្រទេសមួយត្រូវបានបង្កើន រយៈពេលនៃជីវិតរស់នៅរបស់ប្រជាជនក៏កើនឡើងដែរ ។ លទ្ធផលមួយនៃការមានសុខភាពល្អក្នុងការរស់នៅនោះគឺថា ប្រជាជនមាន

ពេលវេលាច្រើនដើម្បីឈានទៅដល់គោលដៅនៃការសំរេចបានបំណងរបស់ខ្លួនឱ្យប្រសើរឡើង ដើម្បីឱ្យគេអាចក្លាយទៅជាអ្នករួមចំណែកយ៉ាងពេញលេញដល់គ្រួសារ និងសង្គម ដែលជំរុញអោយគេអាចរុងរឿងឡើងទៀត ។

លក្ខខណ្ឌបន្ទាប់នៃ HDI គឺការសិក្សា និងចំណេះដឹងដែលត្រូវវាស់ស្ទង់ដោយចំនួនឆ្នាំដែលបានទៅសិក្សា និងកំរិតនៃការចេះដឹងរបស់មនុស្សពេញវ័យរបស់ប្រជាជន ។ នេះគឺជាសន្ទស្សន៍នៃលទ្ធភាពដែលប្រជាជនអាចសំរេចបាននូវការរីកចំរើនរបស់ខ្លួនជាមនុស្សជាតិនោះ ។

ប្រទេសមួយមានលទ្ធភាពនឹងប្រសើរឡើងបាននៅពេលការសិក្សា និងចំណេះដឹងរបស់ប្រជាជនបានត្រូវពង្រីក ទោះបីជាកត្តានេះតែមួយមិនអាចធានាដ៏ការអភិវឌ្ឍន៍ដ៏រុងរឿងក៏ដោយ ដូចដែលបានឃើញក្នុងបណ្តាប្រទេសអឺរ៉ុបខាងកើតជាច្រើននោះ ។

ការគិតគូរផ្នែកហិរញ្ញវត្ថុ គឺជាលក្ខខណ្ឌទី ៣ ដែលត្រូវវាស់ស្ទង់នៃ HDI របស់ប្រទេសមួយ ។ GDP គឺត្រូវប្រើជាមូលដ្ឋានសំរាប់ការអនុវត្តផ្នែកសេដ្ឋកិច្ច ប៉ុន្តែត្រូវទូទាត់ដោយគិតដល់ការទិញថាមពល ការចូលរួមចំណែកពីការងារដែលមិនបានទទួលកំរៃ និងអត្រាប្តូរប្រាក់ ។ ការអនុវត្តន៍នេះ គឺមានបំណងគិតគូរដល់ GDP ពិតប្រាកដ ។

អង្គការ UNDP បានចេញនូវរបាយការណ៍ការអភិវឌ្ឍន៍មនុស្សប្រចាំឆ្នាំ ដោយរៀបរាប់ HDI សំរាប់ប្រទេសជាសមាជិក UN ជាច្រើន ។ ក្នុងឆ្នាំ ២000 លេខលំដាប់សំរាប់ប្រទេសជាសមាជិក MRB ដែលមានគឺ : ប្រទេសថៃ ៧៤ វៀតណាម ១១៥ ឡាវ ១៤១ កម្ពុជា ១៤៨ ក្នុងបណ្តាប្រទេសសរុបចំនួន ១៧៤ ។ គួរកត់សំគាល់ថាលេខ HDI នេះរួមបញ្ចូលទាំងការគិតគូរផ្នែកសេដ្ឋកិច្ច និងសង្គម ប៉ុន្តែមិនគិតបញ្ចូលនូវការវាស់វែងនូវ សុខភាព និងសុខុមាលភាពបរិស្ថានទេ ។

## បារ៉ូម៉ែត្រនៃនិរន្តរភាព

បារ៉ូម៉ែត្រនៃនិរន្តរភាព គឺជាការវាស់ស្ទង់ដ៏សាំញ៉ាំមួយដែលបង្កើតឡើងដោយអង្គការ IUCN ។ គេបានបង្កើតឡើងដើម្បីវាស់ស្ទង់នូវសុខុមាភាពសង្គម និងដំណើរការឆ្ពោះទៅការអភិវឌ្ឍន៍ដោយនិរន្តរភាព ។ សុខភាពប្រព័ន្ធអេកូឡូស៊ីគឺជាកត្តាចំបងនៃលក្ខណ្ឌក្នុងការវាយតំលៃនេះ រួមជាមួយនឹងសុខុមាលភាព និងសុខភាពរបស់មនុស្ស ។ លក្ខខណ្ឌដែលប្រើក្នុងបារ៉ូម៉ែត្រគឺមានច្រើន ហើយនិងនៅតែកំពុងវិវត្តន៍នៅឡើយ ។

ការវាស់ស្ទង់ប្រព័ន្ធអេកូឡូស៊ីខ្លះដែលប្រើក្នុងបារូម៉ែត្រនៃនិរន្តរភាពគឺ គុណភាព និងបរិមាណនៃការផ្គត់ផ្គង់ទឹកសាប តំបន់នៃព្រៃដែលមិនទាន់ប៉ះពាល់ខូចខាត និងអត្រានៃដីព្រៃដែលថយចុះ និងប្រភេទផ្សេងៗនៃសត្វ និងរុក្ខជាតិ និងចំនួននៃប្រភេទដែលបានទទួលរងគ្រោះ ។

លក្ខណ្ឌមនុស្សនៃបារ៉ូម៉ែត្រដែលបានយកមកគិតគូរក្នុងការវាស់ស្ទង់គឺសុខភាព និងសន្តិសុខ (ដូចដែលបានបង្ហាញដោយកំរិតនៃឧក្រិដ្ឋកម្មឃោរឃៅ) ការចេះដឹង ការសិក្សា និងសមភាពផ្នែកយេនឌ័រ (ដូចជាស្ថានភាព និងមុខងាររបស់ស្ត្រីក្នុងសង្គម) និងការគិតគូរផ្នែកហិរញ្ញវត្ថុក្នុងរូបភាពជាចំណូល និង កម្មសិទ្ធទ្រព្យសម្បត្តិ ។

ការវាស់ស្ទង់នូវលក្ខខណ្ឌទាំងនេះ និងលក្ខខណ្ឌទាក់ទងឯទៀតត្រូវបានរួមបញ្ចូល និងផ្សៀងផ្ទាត់ក្នុងរបៀបត្រឹមត្រូវមួយដើម្បីទទួលបាននូវតួលេខមួយដែលគេអះអាងថា ជាចំណាត់ថ្នាក់នៃស្ថានភាពនិរន្តរភាពរបស់ប្រទេសមួយ ។

## សង្ខេបចំណុចសំខាន់ៗ

- ចំណុចយកចិត្តទុកដាក់ជាចំបងរបស់សេដ្ឋកិច្ចបែបប្រពៃណីគឺ ការបង្កើត និងចែកចាយទ្រព្យសម្បត្តិ ។

- គោលការណ៍ និងការអនុវត្តន៍សេដ្ឋកិច្ចបែបប្រពៃណី មិនបានគិតដល់តំលៃខាងក្រៅជាច្រើននៃការដកយកវត្ថុធាតុដើម និងការផលិតទំនិញទេ ។ តំលៃនោះត្រូវរ៉ាប់រងដោយអ្នកផ្សេងក្នុងសង្គមទៅវិញ គឺអ្នកអាចទទួល ឬមិនអាចទទួលផលប្រយោជន៍ ឬក៏គ្មានបានបញ្ចេញមតិយោបល់ក្នុងការសំរេចចិត្តចំពោះសកម្មភាពដែលពាក់ព័ន្ធនោះ ។

- នៅក្នុងអតីតកាល ការអភិវឌ្ឍន៍បានប្រើប្រាស់ធនធានជាច្រើនដោយគ្មាននិរន្តរភាព ប៉ុន្តែបានគិតដល់សេដ្ឋកិច្ច និងប្រសិទ្ធិភាពដោយលក្ខណៈជាប្រពៃណី ។

- ប្រជាជនក្រីក្រត្រូវបានគេមិនយកចិត្តទុកដាក់ក្នុងរូបភាពអភិវឌ្ឍន៍ជាច្រើន ។

- ការព្រួយបារម្ភសំខាន់របស់ប្រជាជនក្រីក្រគឺការរស់នៅប្រចាំថ្ងៃ និងសន្តិសុខ គេពុំមានការលើកទឹកចិត្តក្នុងការថែរក្សាធនធានដ៏មានកំណត់សំរាប់សេចក្តីត្រូវការនាពេលអនាគតទេ ។

- ការអភិវឌ្ឍន៍ដោយនិរន្តរភាពអាចប្រព្រឹត្តទៅបាន លុះត្រាណាមានការអនុវត្តនូវមូលដ្ឋានគ្រឹះទាំងបីគឺ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ។

- ការអភិវឌ្ឍន៍ដោយនិរន្តរភាពគឺពឹងផ្អែកមួយចំណែកលើមូលធនធម្មជាតិ ដី ខ្យល់ និងធនធានទឹកដែលត្រូវតែបានថែរក្សាមិនត្រូវបណ្តោយឱ្យធ្លាក់ចុះ ។

- ការថែរក្សាធនធានជួនកាលអាចត្រូវបង្កើនតាមរយៈការបែងចែកការទទួលខុសត្រូវ ដើម្បីបញ្ចូលក្នុងការគ្រប់គ្រងដោយសហគមន៍មូលដ្ឋាន ។

-គោលការណ៍នៃនិរន្តរភាព គឺស្របគ្នាជាមួយនឹងគោលគំនិតសាសនាព្រះពុទ្ធក្នុងប្រទេសជាសមាជិក MRB ។

- សន្ទស្សន៍នៃការអភិវឌ្ឍន៍ និងនិរន្តរភាពអាចជាសន្ទស្សន៍ដែលមានប្រយោជន៍នៃការអនុវត្តន៍ និងដំណើរការឈានឆ្ពោះទៅរកការអភិវឌ្ឍន៍ដោយនិរន្តរភាពរបស់ប្រទេសមួយ ។

# ទំនប់ និងការអភិវឌ្ឍន៍ដោយនិរន្តរភាព

~~~~~~~

## ប្រវត្តិសង្ខេបនៃទំនប់

| |
|---|
| ការពិភាក្សាអំពីទំនប់គឺជាការពិភាក្សាអំពីគោលបំណង និងមាគ៌ាដ៏មានន័យមួយដើម្បីសំរេចបាននូវការអភិវឌ្ឍន៍ដោយនិរន្តរភាព និងការបែងចែកដោយស្មើភាពនូវតំលៃ និងផលប្រយោជន៍ ។ |

ការជំរុញឱ្យមានការបង្វែរ និងទប់ទន្លេ និងផ្លូវទឹកផ្សេងៗហាក់ដូចជាសន្ទុះសកម្មភាពដ៏ខ្លាំងរបស់មនុស្ស ។ ជាង ៨០០០ឆ្នាំមុន ប្រជាជនរស់នៅក្នុងចក្រភព មេស៊ូប៉ូតាមៀ នៅក្នុងតំបន់នៃប្រទេស អ៊ីរ៉ង់សព្វថ្ងៃបានជីកប្រឡាយមកពីទន្លេធ្វើជាប្រឡាយស្រោចស្រព ។ ជនជាតិ រ៉ូម៉ាំង មានកេរ្តិ៍ឈ្មោះល្បីខាងស្នាដៃវិស្វកម្មរបស់គេក្នុងការបង្វែរ និងបញ្ជូនទឹកក្នុងរយៈចំងាយឆ្ងាយ ។ ទំនប់លើកទីមួយដែលគេបានដឹងនោះគឺបានសាងសង់តាំងពីប្រហែល ៥០០០ឆ្នាំមុនមកហើយនៅលើទន្លេ ទីគ្រីស និងទន្លេ អឺប្រេត្រ ក្នុងតំបន់ មេស៊ូប៉ូតាមៀ ក្នុងប្រទេសអេហ្សិប លើទន្លេ នីល និងទន្លេ អ៊ិនដាស់ ដែលស្ថិតក្នុងប្រទេសបាគីស្ថាន បច្ចុប្បន្ននេះ ។ ទំនប់ពីមុនៗទាំងអស់នោះត្រូវបានសាងសង់ឡើងដើម្បីផ្គត់ផ្គង់ទឹកដល់ការស្រោចស្រពដីកសិកម្ម និងការការពារទឹកជំនន់ ។ ការកសាងទំនប់សំរាប់ផលិតអគ្គិសនីបានចាប់ផ្តើមប្រហែលក្នុងឆ្នាំ ១៨៩០ ។

នៅពាក់កណ្តាលសតវត្សទី ២០ ទំនប់ធំៗ ៥០០០ ត្រូវបានសាងសង់ឡើងក្នុងពិភពលោក ។ តាមនិយមន័យទំនប់ធំៗគឺជាទំនប់ដែលមានកំពស់ខ្ពស់ជាង 15m ឬក៏ក្នុងករិតកំពស់ពី 5 ទៅ 15m ដែលមានទំហំអាងទឹកចំណុះជាង ៣ លានម$^{៣}$ ។ ក្នុងទសវត្ស ឆ្នាំ១៩៧០ មានពីរ ឬបីនៃទំនប់ធំៗត្រូវបានកំពុងដំណើរការរៀងរាល់ថ្ងៃហើយនៅចុងសតវត្សទំនប់ធំៗសរុបបានដំណើរការគឺ ៤៥ ០០០ ទំនប់ ។ បន្ថែមពីនោះទៀត មានទំនប់ប្រហែល ៨០០ ០០០ ទៀតក្នុងពិភពលោកដែលពុំមានន័យថាជាទំនប់ធំនោះ ។ តំលៃសាងសង់ទំនប់សរុបក្នុងសតវត្សទី ២០ ត្រូវបាន ប៉ាន់ស្មានថាអស់តំលៃប្រហែល ២ លាន លាន ដុល្លាអាមេរិក ។ឆ្លងតាមរយៈពេលជាច្រើនសតវត្សមកនេះ ទំនប់ត្រូវបានគេយល់ថាជានិមិត្តសញ្ញានៃការវិវត្តន៍នៃឧស្សាហកម្ម លទ្ធភាពគ្រប់គ្រងទន្លេរបស់មនុស្ស និងប្រើប្រាស់ធម្មជាតិ ។ ទំនប់ធ្វើជានិមិត្តរូបនៃអំណាច គឺ នយោបាយ សេដ្ឋកិច្ច សង្គម និងអគ្គិសនី ។ ចំពោះរដ្ឋាភិបាលជាច្រើន ការសាងសង់ទំនប់ត្រូវបានគេគិតថាជាការបង្ហាញនូវភាពខ្លាំងរបស់ប្រទេសជាតិ ។ ជាលទ្ធផលគឺថា ជាងពាក់កណ្តាលនៃទន្លេសំខាន់ៗក្នុងពិភពលោកត្រូវរងផលប៉ះពាល់ដោយសារទំនប់ ហើយគេប៉ាន់ស្មានថាមានប្រជាជនយ៉ាងតិចបំផុត ៤០ លាន នាក់ ត្រូវជំលៀសចេញដើម្បីយកកន្លែងសាងសង់ទំនប់ និងអាងទឹក ។ ប្រទេសចិនមានទំនប់ធំៗច្រើនជាងគេ គឺប្រហែលជាង ២២ ០០០ ទំនប់ សហរដ្ឋអាមេរិកប្រហែល ៦ ៤០០ ទំនប់ ឥណ្ឌា ៤ ០០០ ទំនប់ និង ជប៉ុន និងអេស្ប៉ាញ មានជាង ១ ០០០ ក្នុងប្រទេសនីមួយៗ ។
~~~~~~~

ទោះជាយ៉ាងណាក៏ដោយ ទំនោរប្រឆាំងនឹងការសាងសង់ទំនប់បានចាប់ផ្តើមមានឡើងក្នុងសហរដ្ឋ-អាមេរិក នៅពេលដែលទំនប់តូចៗជាង ៥០០ ត្រូវបានបញ្ឈប់ដំណើរការក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ។ ការផ្លាស់ប្តូរនេះបានកើតឡើង ដោយសារការកើនឡើងនូវការជំទាស់របស់សាធារណៈក្នុងឆ្នាំថ្មីៗកន្លងទៅនេះ ចំពោះផលប៉ះពាល់ផ្ទាល់ខ្លះ និងមិនផ្ទាល់ខ្លះនៃទំនប់ ។

## ទំនប់នៅក្នុងអាងទន្លេមេគង្គ

ក្នុងនាមឈ្មោះពីមុនជាគណៈកម្មាធិការទន្លេមេគង្គនោះ ការគាំទ្រដើម្បីសាងសង់ទំនប់នៅលើដងទន្លេមេគង្គ និងដៃជាច្រើនទៀតរបស់វាគឺជាអាទិភាពខ្ពស់មួយ ។ រហូតមកដល់សព្វថ្ងៃនេះមានទំនប់ធំៗបីបានសាងសង់ហើយនៅក្នុងអាងទន្លេមេគង្គក្រោម (LMRB) គឺ : ណាំងឹម និងណាំធឿន ហ៊ីនបុណ ក្នុងប្រទេសឡាវ និងទំនប់ យ៉ាលី ក្នុងប្រទេស វៀតណាម ។ ទំនប់តូចៗជាច្រើនក៏ត្រូវបានសាងសង់ផងដែរ ។ រហូតមកទល់ពេលនេះ មានតែទំនប់មួយទេ គឺទំនប់ ម៉ាន់វ៉ាន់ ក្នុងខេត្តយូណាន់នៃប្រទេស ចិន ដែលបានសាងសង់នៅលើដងទន្លេមេគង្គ ។ គណៈកម្មការទន្លេមេគង្គសព្វថ្ងៃ (MRC) ដែលបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ មានអាទិភាពផ្សេងពីគណៈកម្មាធិការមុន ទោះបីជាអនុសាសន៍ជាយុទ្ធសាស្ត្រនៃបេសកកម្មរបស់ MRC នៅតែមានជាផ្នែកនៃផែនការអភិវឌ្ឍន៍អាងទន្លេ និងកម្មវិធីប្រើប្រាស់ទឹកក៏ដោយ ។

## គណៈកម្មការពិភពលោកស្តីពីទំនប់

ជាលទ្ធផលនៃការព្រួយបារម្ភដោយអង្គការមិនមែនរដ្ឋាភិបាល (NGO) រដ្ឋាភិបាល និងសហគមន៍ជុំវិញពិភពលោកអំពីគ្រោះថ្នាក់ដែលកើតឡើងដោយសារទំនប់មួយចំនួនក្នុងឆ្នាំ ១៩៩៨ ធនាគារពិភពលោក និងសហភាពអន្តរជាតិដើម្បីថែរក្សាធម្មជាតិ និងធនធានធម្មជាតិ (IUCN) បានដឹកនាំការប្រជុំនៃក្រុមអ្នកជំនាញតំណាងឱ្យតំបន់ក្នុងពិភពលោក និងក្រុមអ្នកពាក់ព័ន្ធទាំងអស់ដើម្បី ÷

- ពិនិត្យមើលនូវប្រសិទ្ធិភាពនៃទំនប់ធំៗក្នុងការជួយសំរួលដល់ការអភិវឌ្ឍន៍
- វាយតំលៃលើជំរើសផ្សេងៗទៀត
- បង្កើតនូវលក្ខណ្ឌ សេចក្តីណែនាំ និង បទដ្ឋានផ្សេងៗសំរាប់ការធ្វើផែនការ លើកគំរោង សាងសង់ ដំណើរការ ត្រួតពិនិត្យ និងការបញ្ឈប់ដំណើរការរបស់ទំនប់ ។

ពីឆ្នាំក្រោយពីវេទិកាផ្សព្វផ្សាយជាសាធារណៈនៅជុំវិញពិភពលោកមក មានការដាក់ស្នើជាច្រើន រួមទាំងការស្នើដោយ MRC និងការត្រួតពិនិត្យពិចារណាលំអិតជាច្រើនទៀតនោះ គណៈកម្មការពិភពលោកស្តីពីទំនប់បានចេញនូវរបាយការណ៍របស់ខ្លួនក្នុងខែ វិច្ឆិកា ឆ្នាំ ២០០០ ។ ហើយពតិមានជាច្រើននៅក្នុងមេរៀននេះគឺដកស្រង់ចេញពីរបាយការណ៍នោះ ។

## ផលប្រយោជន៍ពីទំនប់

ជាទូទៅទំនប់ច្រើនសាងសង់ឡើងក្នុងគោលបំណងមួយ ឬច្រើននៃផ្នែកសេដ្ឋកិច្ច-សង្គម និងវិស្វកម្ម ដូចខាងក្រោម :

- ដើម្បីផលិតអគ្គិសនីសំរាប់ការប្រើប្រាស់តាមលំនៅដ្ឋាន និងឧស្សាហកម្ម ឬ/និងសំរាប់លក់ចេញ ដើម្បីរកចំណូលពីប្រទេសក្រៅ ។ ថាមពលអគ្គិសនីគឺជាកត្តាចាំបាច់សំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្ម និង បង្កើន ជីវភាពរស់នៅរបស់សហគមន៍ ។
- ដើម្បីស្តុកទឹកសំរាប់ស្រោចស្រពដីកសិកម្ម ដើម្បីបង្កើនទិន្នផល និងបង្កើនសន្តិសុខនៃការផ្គត់ផ្គង់ ស្បៀងអាហារ ។
- ដើម្បីរក្សាបង្អាក់ទឹកទុកក្នុងរយៈពេលដែលមានរំហូរទន្លេខ្លាំងដើម្បីការពារទឹកជំនន់នៅផ្នែកខ្សែទឹក ខាងក្រោម និងដើម្បីបញ្ចេញទឹកនៅពេលរំហូរទឹកនៅទន្លេតិច ។

ផលប្រយោជន៍បន្ថែមទៀតរបស់ទំនប់អាចរួមមាន :

- អគ្គិសនីភាវូបនីយកម្មជនបទ និងការអភិវឌ្ឍន៍
- បង្កើតបរិយាសការងារនៅពេលសាងសង់ទំនប់ និងក្នុងការអភិវឌ្ឍន៍សហគមន៍ និងឧស្សាហកម្ម បន្តបន្ទាប់
- បង្កើននូវសេវាកម្មសង្គម និងពង្រីងហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ដែលត្រូវប្រើទំនប់ដូចជាសាលារៀន មន្ទីរពេទ្យ និងផ្លូវថ្នល់
- លទ្ធភាពនៃការធ្វើការនេសាទ និងលំហែរកាយរបស់អាងទឹក ។

ផលប្រយោជន៍ទាំងនោះបានចូលរួមចំណែកមួយចំនួនធំដល់ការអភិវឌ្ឍន៍របស់មនុស្សក្នុងប្រទេសជាច្រើន ប៉ុន្តែមានឧទាហរណ៍នៃទំនប់ជាច្រើនដែលពុំបានផ្តល់នូវការអនុវត្តន៍ផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដែលបាន សង្ឃឹមទុក ហើយក៏មិនបានផ្តល់ផលប្រយោជន៍សេដ្ឋកិច្ច ជាពិសេសបើប្រៀបធៀបទៅ នឹងជំរើសផ្សេងទៀតដែល គេអាចយកមកអនុវត្តន៍នោះ ។

## បញ្ហាដែលមានចំពោះទំនប់

ជាទូទៅផលប្រយោជន៍របស់ទំនប់តែងតែមានតិចជាងការដែលគេសង្ឃឹមទុក ហើយផលប៉ះពាល់អាក្រក់ មានច្រើនជាងអ្វីដែលគេរំពឹងទុកនោះ ។ ក្នុងករណីជាច្រើនហេតុប៉ះពាល់លើបរិស្ថាន និងប្រជាជនដែលត្រូវ

ជំលៀសចេញដោយសារការអភិវឌ្ឍន៍ទំនប់មានច្រើន និងអាក្រក់ជាងអ្វីដែលអ្នកធ្វើគំរោងនោះបានលើកឡើងទៅទៀត ។ ហើយជាទូទៅ ផលប្រយោជន៍សេដ្ឋកិច្ចបានធ្លាក់ទៅកន្លែងឆ្ងាយពីតំបន់ទំនប់ ចំណែកឯកសហគមន៍មូលដ្ឋាន និងក្រុមអ្នករងគ្រោះដ៏ទៃទៀតត្រូវបានបង្ខំឱ្យរស់នៅក្នុងជីវភាពលំបាកជាងមុនពេលអភិវឌ្ឍន៍នោះ ។

ទំនប់ជាមូលដ្ឋានគ្រឹះនៃការផ្លាស់ប្តូរស្ថានភាពទន្លេ និងការប្រើប្រាស់ធនធានធម្មជាតិ ជាទូទៅតែងតម្រូវឱ្យមានការរៀបចាត់ចែងនូវផលប្រយោជន៍ឡើងវិញ ដោយយកពីអ្នកប្រើប្រាស់ក្នុងមូលដ្ឋានទៅឱ្យក្រុមមនុស្សថ្មីនៅថ្នាក់តំបន់ ឬថ្នាក់ជាតិវិញ ។ បញ្ហាចំបងនៃការពិភាក្សាបញ្ហាទំនប់គឺបញ្ហា សមភាព ការគ្រប់គ្រងយុត្តិធម៌ និងអំណាចនោះ គឺជាបញ្ហាជាមូលដ្ឋាននៃបញ្ហាទាក់ទងគ្នាទាំងអស់ដែលមនុស្សជាតិកំពុងប្រឈមមុខ

ទំនប់ធំៗជាច្រើនមិនត្រូវបានធ្វើការត្រួតពិនិត្យអគ្គិសនី ទឹក ឬក៏ចែកចាយផលប្រយោជន៍ដែលគេបានសន្យានោះទេ ហើយដែលផ្អែកលើការសន្យានោះ គំរោងនេះបានត្រូវទទួលការយល់ព្រមឱ្យអនុវត្តន៍ ។ ហើយជាលទ្ធផល ផលប្រយោជន៍សេដ្ឋកិច្ចរបស់គំរោង និងចំណូលហិរញ្ញវត្ថុពុំត្រូវបានសំរេចទេ ។ មូលដ្ឋានសេដ្ឋកិច្ចនៃទំនប់ដែលសាងសង់ឡើងដើម្បីផ្តល់ចរន្តអគ្គិសនីសំរាប់លក់ចេញ ពឹងផ្អែកលើការធានាបន្តត្រូវការពីប្រទេស និងឧស្សាហកម្មដែលទិញថាមពល ។ ប៉ុន្តែឥទ្ធិពលសេដ្ឋកិច្ច និងនយោបាយអាចធ្វើការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនូវផែនការ និងកម្មវិធីនៃអ្នកប្រើប្រាស់ថាមពលដូចដែលយើងបានឃើញក្នុងវិបត្តិរូបិយវត្ថុក្នុងបណ្តាប្រទេសអាស៊ាននាពេលថ្មីៗនេះ ។ ដូចនោះប្រទេសដែលលក់ថាមពលចេញត្រូវប្រឈមមុខ និងបន្ទុកបំណុលទុន និងតំលៃដំណើរការដ៏ធំធេងសំរាប់ទំនប់នៅពេលដែលថាមពលមិនត្រូវបានគេត្រូវការក្នុងអត្រាដូចដែលបានគិតទុកទៀតនោះ ។

ទោះបីជានៅមុនពេលចាប់ដំណើរការទំនប់ក៏ដោយ តំលៃនៃការសាងសង់ និងរយៈពេលច្រើនតែធំជាង និងយូរជាងការគ្រោងទុកដោយសារតែបញ្ហានៃការដែលមិនបានគិតមុន ធ្វើផែនការមុន ឬក៏មិនបានគិតគូរដល់យ៉ាងច្រើននោះ ។ ការពន្យាពេលគឺវាមានតំលៃជាទឹកប្រាក់ និងធ្វើឱ្យល្អក់កករដល់ការទុកចិត្តនៃអ្នកផ្តល់ហិរញ្ញវត្ថុ អ្នកប្រើប្រាស់ និងសហគមន៍មូលដ្ឋាន ។

ក្រោយពេលទំនប់ត្រូវដាក់ឱ្យដំណើរការ ហេតុប៉ះពាល់បរិស្ថាន និងសេដ្ឋកិច្ចសង្គមអាក្រក់ៗតែងតែកើតមានលើសអ្វីដែលអ្នកធ្វើគំរោងទំនប់គិតទុក ដោយមានលទ្ធផលដែលមិនចង់បានជាច្រើន ។ ឧទាហរណ៍ដូចជាការស្រោចស្រពអាចបណ្តាលឱ្យកើនឡើងនូវជាតិអំបិលក្នុងដីដែលធ្វើឱ្យចុះថយនូវទិន្នផលដំណាំជាជាងបង្កើនទិន្នផលនោះ ។ ទំនប់បានប៉ះពាល់យ៉ាងខ្លាំងដល់ផ្នែកក្នុងទឹក និងលើដីនៃប្រព័ន្ធអេកូឡូស៊ី ដោយបានកាត់បន្ថយរំហូរទឹកនៅខ្សែទឹកខាងក្រោមពីប្រភពរបស់វា និងធ្វើឱ្យលិចតំបន់ដែលរស់នៅដោយសត្វ និងមនុស្ស ។ ការបាត់បង់នូវជំរកលើដី និងក្នុងទឹកនាំឱ្យថយចុះនូវចំនួន និងប្រភេទសត្វ និងរុក្ខជាតិក្នុងមូលដ្ឋាន ។

## ហេតុអ្វីបានជាមានបញ្ហាទំនប់កើតឡើង

ការប្រឆាំងទល់នឹងទំនប់បានផ្ទុះឡើងនៅពេញពិភពលោកក្នុងឆ្នាំថ្មីៗកន្លងទៅនេះ គឺដោយសារគេយល់ឃើញថាដំណើរការអភិវឌ្ឍន៍ទំនប់ជាច្រើនបាននាំឱ្យមានគ្រោះថ្នាក់យ៉ាងខ្លាំង ។ បញ្ហាមួយចំនួននឹងត្រូវបង្ហាញក្នុងមេរៀននេះ ។

វាប្រហែលជាផលប៉ះពាល់ដ៏អាក្រក់បំផុតរបស់ទំនប់នោះ គឺការប៉ះពាល់ទៅលើប្រជាជនដែលវាជាគ្រោះអាក្រក់ដោយសារទំនប់នោះត្រូវកើតឡើងនៅកន្លែងរបស់គេ ។ មូលហេតុដែលបណ្តាលឱ្យកើតមានគ្រោះអាក្រក់នេះក៏ដូចជាផលប៉ះពាល់សំខាន់ៗដទៃទៀតដែរគឺជាការដែលមិនបានគិតគូរដោយអ្នកធ្វើគំរោងទំនប់ និងភ្នាក់ងាររដ្ឋាភិបាលក្នុងការវាយតំលៃឱ្យបានត្រឹមត្រូវនូវផលប៉ះពាល់វិជ្ជមាន និងចាត់វិធានការកាត់បន្ថយឱ្យបានមុនពេលចាប់ផ្តើមដំណើរការអភិវឌ្ឍន៍ ។ គោលការណ៍នៃកន្លែងដែលយើងឃើញមានការមិនយកចិត្តទុកដាក់នេះកើតឡើងគឺ ÷

- ក្នុងកម្មវិធីសំរាប់ផ្លាស់ប្តូរទីលំនៅអ្នកដែលត្រូវជំលៀសចេញ នោះគឺប្រជាជនដែលត្រូវជំលៀសចេញពីផ្ទះរបស់គេដើម្បីទុកកន្លែងសំរាប់ការអភិវឌ្ឍន៍ទំនប់
- ផលប៉ះពាល់ដែលធ្វើឱ្យផ្លាស់ប្តូរនូវរំហូរទឹកទន្លេទៅលើជីវភាពរស់នៅរបស់ប្រជាជនក្នុងសហគមន៍នៃខ្សែទឹកខាងក្រោម
- ខ្វះការយកចិត្តទុកដាក់ដល់ការឈឺចាប់របស់បុគ្គល និងភាពខ្វះខាតរបស់ប្រជាជនដែលទទួលរងគ្រោះផ្ទាល់ពីការអភិវឌ្ឍន៍ទំនប់ គឺអ្នកដែលភាគច្រើនជាអ្នកក្រ នៅទីជនបទ និងមិនមានអំណាច
- បាត់បង់នូវផ្នែកសំខាន់ៗនៃប្រព័ន្ធអេកូឡូស៊ី ទាំងផ្នែកក្នុងទឹក និងលើដីតាមរយៈទឹកជំនន់លិចដីដោយសារអាងទឹក និងការរារាំងដល់រំហូរនៃកករ និងទន្លេដោយសារការកាត់ផ្តាច់ទន្លេពីប្រភពរបស់វា ។

## មូលហេតុសំខាន់ៗចំពោះបញ្ហា

មូលហេតុមួយចំនួននៃបញ្ហាដែលទាក់ទងនឹងទំនប់នឹងត្រូវបញ្ជាក់ក្នុងផ្នែកខាងក្រោមនេះ ។

នៅក្នុងសតវត្សទី ២០ ទំនប់ធំៗតែងត្រូវបានជាស្នាដៃដ៏អស្ចារ្យសំរាប់អ្នកនយោបាយរដ្ឋាភិបាល វិស្វករ និងភ្នាក់ងារផ្តល់ជំនួយហិរញ្ញវត្ថុ ។ វាបានធ្វើជានិមិត្តរូបនៃការរីកដាលនៃមនោគមវិជ្ជា បច្ចេកវិទ្យា និង ការប្រើអំណាចរបស់មនុស្សទៅលើធម្មជាតិ ។ គោលគំនិតនៃភាពអមតៈរបស់ទំនប់ និងការដែលទទួលបានផលផ្នែកហិរញ្ញវត្ថុបានជំរុញឱ្យអ្នកធ្វើការសំរេចចិត្តគិតថា មានតែទំនប់នេះដែលនឹងធ្វើឱ្យគេអាចឆ្លើយតបបាននាពេលអនាគតនូវតំរូវការថាមពល ឬទឹកស្រោចស្រពដែលជាជំរើសដែលមានតំលៃតិចក្នុងចំណោមជំរើសផ្នែកសេដ្ឋកិច្ច និងវិស្វកម្មជាច្រើនប្រភេទនោះ ។ ដោយជ្រើសរើសយកដំណោះស្រាយដែលថោកបំផុត ការកាត់បន្ថយនូវផលប៉ះពាល់បរិស្ថាន និងសង្គមនឹងត្រូវបានធ្វើឡើងក្នុងកំរិតមួយដែលមិនប៉ះពាល់ដល់គំរោងតែប៉ុណ្ណោះ ។ ក្នុងស្ថានភាពបែបនេះ បក្សពួកនិយម អំពើពុករលួយ និងវិទ្យាសាស្ត្រមិនត្រឹមត្រូវអាចកើតមានឡើងយ៉ាងច្រើន ។

ទោះបីជាមានការលើកឡើងនូវការព្រួយបារម្ភក្នុងពេលធ្វើផែនការ ឬសាងសង់ក៏ដោយនៅពេលដែលត្រូវបានសំរេចចិត្តថាអនុវត្តនោះ គំរោងច្រើនបានប្រព្រឹត្តទៅតាមតែនិចលភាពរបស់វា ដោយពុំបានគិតបញ្ហាជាក់ស្តែងនៃបរិស្ថាន និងសង្គមទេព្រោះថាវានឹងនាំឱ្យដំណើរការយឺត និងត្រូវចំណាយប្រាក់ផល ។ មានតែការធ្វើឱ្យតំលៃនោះមានទៅខាងក្រៅ និងទុកឱ្យអ្នកដទៃជាអ្នករ៉ាប់រងដូចដែលគំរោងជាច្រើនបានអនុវត្តន៍នោះ ។ ការផ្តោតការយកចិត្តទុកដាក់តិចតួចដល់វិស្វកម្ម និងសេដ្ឋកិច្ចបែបបុរាណ និងការខ្វះនូវការគិតគូរឱ្យបានត្រឹមត្រូវនោះគឺជាកត្តាសំខាន់នៃការអភិវឌ្ឍន៍ដោយគ្មាននិរន្តរភាព ។

ការវាយតំលៃលើហេតុប៉ះពាល់បរិស្ថាន (EIA) ក៏រិតគំរោង និងការវាយតំលៃលើកត្តាសេដ្ឋកិច្ច-សង្គមច្រើនតែមានលំអៀងទៅខាងការអភិវឌ្ឍន៍ ដោយច្រើនលើកឡើងនូវវិធានការកាត់បន្ថយមានតំលៃថោកៗដើម្បីធានាដល់ជោគជ័យផ្នែកហិរញ្ញវត្ថុសំរាប់ការអភិវឌ្ឍន៍ដែលកំពុងឈានទៅមុខដោយមិនគិតដល់លទ្ធផលនៃ EIA ។ ជាទូទៅច្រើនតែធ្វើការវាយតំលៃយឺត មិនគ្រប់ជ្រុងជ្រោយ ឬក៏លទ្ធផលនៃការវាយតំលៃនោះមិនត្រូវបានចិត្តទុកដាក់ ។ ការរៀបរាប់លំអិតពី EIA និងមានបង្ហាញក្នុងមេរៀន D និង E ប៉ុន្តែវាត្រូវតែលើកឡើងនៅពេលនេះដើម្បីពុះពាររកការអភិវឌ្ឍន៍ដោយនិរន្តរភាពពិតប្រាកដ ដែលក្នុងករណីជាច្រើន EIA បានធ្វើឡើងគ្រាន់តែសំរាប់តំរូវតាមតំរូវការរបស់រដ្ឋាភិបាលតែប៉ុណ្ណោះ ។

ជាលទ្ធផលនៃ EIA និងការសិក្សាផ្នែកធារាសាស្ត្រ និងវិស្វកម្មមិនគ្រប់ជ្រុងជ្រោយនោះ បានធ្វើឱ្យអ្នកធ្វើគំរោង ក្នុងករណីជាច្រើន បានប៉ាន់ស្មានខុសលើៈ

- អត្រានៃការកក កកក្នុងអាងទឹក ដែលបណ្តាលឱ្យមានការបាត់បង់សមត្ថភាពស្តុកទឹក
- មានគ្រោះថ្នាក់នៃការបាក់ដី និងដាច់ដី និងបណ្តាលឱ្យបាក់ទំនប់
- បាត់បង់ទឹកពីក្នុងអាងដោយសារការលេចជ្រាប និងហួត

ការវាយតំលៃហេតុប៉ះពាល់រួម (CEA) លើផ្ទៃរងទឹកភ្លៀង ឬអាងទន្លេមិនទាន់បានអនុវត្តទេ ដែលជាលទ្ធផលការអភិវឌ្ឍន៍និមួយៗត្រូវបានគិតគូរក្នុងភាពដាច់តែឯង ដូចនេះផលប៉ះពាល់នៃការប្រើប្រាស់ទឹកនៅខ្សែទឹកខាងក្រោម និងខាងលើនាពេលអនាគតមិនត្រូវបានគិតគូរទេ ។ និយាយរួម គឺមិនបានប្រើប្រាស់ក្នុងការគិតគូរដល់ប្រព័ន្ធអេកូឡូស៊ី ឬអាងទន្លេទេ ។

## បញ្ហាសំខាន់ៗ

មានបញ្ហាដែលទាក់ទងគ្នាបីដែលមានសារៈសំខាន់ក្នុងគំរោងទំនប់ ហើយដែលត្រូវយកចិត្តទុកដាក់ផ្សេងៗគ្នាក្នុងការអភិវឌ្ឍន៍នាពេលអនាគត ។ នោះគឺការផ្លាស់ប្តូរទីលំនៅប្រជាជនដែលត្រូវជំលៀសចេញ និងបញ្ហាសេដ្ឋកិច្ច-សង្គមដែលទាក់ទង ការប្រែប្រួលជលផល និងការប្រើប្រាស់ធនធានក្នុងមូលដ្ឋាន និងផលប៉ះពាល់លើប្រព័ន្ធអេកូឡូស៊ី ។

ក្នុងករណីជាច្រើននៃការអភិវឌ្ឍន៍ទំនប់ ការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនដែលរស់នៅក្នុងសហគមន៍នៅក្នុងតំបន់ទំនប់នោះ និងនៅលើដីដែលនឹងត្រូវលិចទឹក និងក្លាយជាអាងទឹកតែងតែត្រូវអនុវត្តន៍ឡើងតាមបទបញ្ជារបស់រដ្ឋាភិបាល មិនមែនតាមរយៈការពិភាក្សាទេ ។ អត្តចរិតដែលគេអនុវត្តន៍នោះគឺថាត្រូវតែមានមនុស្សខ្លះទទួលរងការលំបាក និងធ្វើពលិកម្មដើម្បីជាប្រយោជន៍ដល់មនុស្សភាគច្រើន (ទោះបីជាផលប្រយោជន៍ដែលបានទទួលនោះ ជាយថាហេតុ តិចជាងអ្វីដែលគេបានសន្យាច្រើនដងក៏ដោយ) ។ ទំហំនៃការរើទីតាំង និងផលប៉ះពាល់លើសេដ្ឋកិច្ច-សង្គមពុំត្រូវបានវាយតំលៃឱ្យគ្រប់ជ្រុងជ្រោយជាមុនទេ ។ ផលប៉ះពាល់នោះ រួមមាន ជម្លោះរវាងអ្នកដែលត្រូវជំលៀសចេញ (ប្រជាជនដែលត្រូវផ្លាស់ទីលំនៅ ) នឹងប្រជាជនដើមនៃតំបន់ដែលគេត្រូវផ្លាស់ទៅនៅ (ហៅថាអ្នកម្ចាស់ទទួលភ្ញៀវ ) ដោយសារ ឧទាហរណ៍ ដូចជា មានការដណ្តើមយកដី ការងារ និងធនធានភាពគ្មានអំណាចនៃអ្នកទៅនៅថ្មី និងអ្នកនៅចាស់ ដែលជាលទ្ធផលនៃការពឹងផ្អែកលើការឧបត្ថម្ភរបស់រដ្ឋាភិបាលដោយសារថាខ្វះខាតធនធានក្នុងមូលដ្ឋាន និងការងារ ការបាត់បង់នូវរបៀបរស់នៅជាលក្ខណៈប្រពៃណី និងទំនៀមទំលាប់ដោយអ្នកមករស់នៅថ្មីក្នុងស្ថានភាពបរិស្ថានថ្មី ការថ្នាំងថ្នាក់ចិត្តរបស់អ្នកម្ចាស់ដើមចំពោះប្រពៃណីនិងរបៀបរស់នៅដែលនាំចូលមកដោយអ្នកមករស់នៅថ្មី ។

ប្រជាជនដែលទទួលរងគ្រោះដោយគំរោងផ្សេងទៀត (OPAP) ក៏ត្រូវទទួលរងគ្រោះដោយផលប៉ះពាល់អាក្រក់នៃកិច្ចដំណើរការទំនប់ដែរ ។ OPAP រួមមានអ្នកដែលរស់នៅខ្សែទឹកខាងលើ និងខាងក្រោមនៃទីតាំងទំនប់ហើយដែលមិនចាំបាច់ផ្លាស់ទីតាំង ប៉ុន្តែជីវភាពរស់នៅរបស់គេត្រូវបានផ្លាស់ប្តូរដោយសារការផ្លាស់ប្តូររបបទឹកនៅក្នុងទន្លេគឺ ធារទឹក រយៈពេលរំហូរទឹកខ្លាំង និងខ្សោយ និងការផ្លាស់ប្តូររបបទឹករយៈពេលខ្លីហើយ និងដោយសារការផ្លាស់ប្តូរស្ថានភាពដី ឧទាហរណ៍ ដូចជា ការដែលបណ្តាលមកពីខ្សែបញ្ជូនអគ្គិសនី ផ្លូវថ្នល់ ទីក្រុង ប្រព័ន្ធស្រោចស្រព អាងទឹក ការបាត់បង់ធនធានព្រៃឈើ ឬកសិកម្មក្នុងស្រុកដែលផ្លាស់ប្តូរដល់ការរស់នៅជាលក្ខណៈប្រពៃណីរបស់គេ ។ចំនួន OPAP តែងតែច្រើនជាងចំនួនអ្នកដែលបានជំលៀសចេញគឺអ្នកដែលត្រូវតាំងទីលំនៅថ្មី ។

ទោះបីជាអ្នកធ្វើគំរោងទំនប់តែងតែសន្យាថា នឹងផ្តល់ការងារ នៅក្នុងដំណាក់កាលសាងសង់ដល់អ្នកមូលដ្ឋានក៏ដោយ ក្នុងស្ថានភាពជាក់ស្តែង ការងារដែលត្រូវការជំនាញ និងការងារមិនជំនាញជាច្រើនទៀតត្រូវបានធ្វើដោយអ្នកចំណូលមកពីក្រៅគឺអ្នកដែលធ្លាប់មានបទពិសោធន៍លើគំរោងនេះ ។ ប្រជាជនមូលដ្ឋានត្រូវបានដាក់ឱ្យនៅដាច់ឆ្ងាយពីភាពរីកចំរើនដែលកើតពីការងារទាំងនេះ ។ ដូចគ្នានេះដែរនៅពេលទំនប់ត្រូវរាំងដល់រំហូរទឹកនៃទន្លេហើយបង្កើតជាអាងទឹក ប្រភេទត្រីដែលរស់នៅក្នុងអាងទឹក និងរបៀបចាប់ត្រីគឺខុសគ្នាទាំងស្រុងពីស្ថានភាពរំហូរទឹកដោយធម្មជាតិក្នុងទន្លេដែលអ្នករស់នៅក្នុងមូលដ្ឋានធ្លាប់បានស្គាល់នោះ ។ ដូចគ្នានោះទៀតដែរ អ្នកមកនៅថ្មីពីតំបន់ផ្សេងដែលធ្លាប់មានជំនាញ និងចេះរបៀបនោះបានធ្វើអាជីវកម្មយ៉ាងឆាប់រហ័សលើប្រភពធនធានថ្មីហើយនិងកសាងជីវភាពរស់នៅរបស់គេ ។ សហគមន៍មូលដ្ឋានជាអ្នកដែលមិនបានទទួលផល ហើយធ្លាក់ក្រចុះហើយដែលអាចក្លាយជាបញ្ហា ឬបន្ទុកចំពោះរដ្ឋាភិបាល ។

ទំនប់បានរារាំងដល់ការផ្លាស់ទីរបស់ត្រីទៅពងនៅតំបន់មួយ ហើយជណ្តើរសំរាប់ត្រីឡើងដែលបានប្រើសំរាប់ប្រភេទត្រី ស៊ុលម៉ុង ដោយមានប្រសិទ្ធភាពបង្គួរ នៅតំបន់មានអាកាសធាតុមធ្យមមួយនោះ ត្រូវបានគេពិនិត្យឃើញថាពុំមានប្រសិទ្ធភាពសំរាប់ប្រភេទត្រីក្នុងតំបន់ត្រូពិចទេ ។

ទំនប់ក៏បានធ្វើឱ្យប្រែប្រួលផងដែរនូវគុណភាពទឹកក្នុងអាង និងនៅខ្សែទឹកខាងក្រោមទំនប់ បើប្រៀបធៀបទៅនឹងស្ថានភាពរំហូរទឹកដោយធម្មជាតិក្នុងទន្លេ ។ ទឹកដែលហូរវិវក់នៅផ្នែកខាងក្រោមជាប់ទំនប់អាចមានទីត្រូហ្សែន និងអុកស៊ីស្សែន ដែលរលាយក្នុងទឹកច្រើនហួស ដែលអាចបណ្តាលឱ្យកើតជម្ងឺពពុះឧស្ម័នចំពោះត្រី ។ សីតុណ្ហភាព ភាពកករវិវក់ សារជាតិ និងធាតុរឹងក្នុងទឹក គឺត្រូវផ្លាស់ប្តូរដោយរយៈពេលតាំងនៅនៃទឹកក្នុងអាង បើប្រៀបធៀបទៅនឹងរំហូរធម្មជាតិក្នុងទន្លេ។

ត្រីនៅក្នុងអាង គឺខុសពីត្រីនៅក្នុងទន្លេធម្មជាតិ ដូចបានកត់សំគាល់ពីមុនមក និងដោយសារតែលក្ខណៈរូប និងគីមីនៃទឹកនៅផ្នែកខាងក្រោមទំនប់ ត្រីដែលរស់នៅកន្លែងនោះអាចស្ថិតក្នុងស្ថានភាពសុខភាពមិនល្អ ហើយចំនួន និងប្រភេទក៏ត្រូវផ្លាស់ប្តូរ ។

ជាទូទៅការចាប់ត្រីមានច្រើននៅពេលកកើតអាងទឹកដំបូងបន្ទាប់មកក៏ថយចុះ ដោយសារផលិតភាពវាថយចុះ ។ ការនាំមកនូវត្រីប្រភេទថ្មីអាចធ្វើឱ្យបាត់បង់ដល់ប្រភេទក្នុងស្រុកហើយធ្វើឱ្យផ្លាស់ប្តូរនូវអេកូឡូស៊ីទន្លេ។

តើការផ្លាស់ប្តូរទីលំនៅនោះទទួលបានជោគជ័យ ឬអត់គឺមិនអាចវាយតំលៃបានសំរាប់មនុស្សទាំងពីរជំនាន់ក្រោយពីបានធ្វើការផ្លាស់ប្តូរទីលំនៅនោះទេ ។ លុះត្រាតែកូនចៅនៃអ្នកត្រូវតាំងទីលំនៅថ្មី និងអ្នករស់នៅដើមនៅទីនោះមានជីវភាពរស់នៅល្អប្រសើរ និងបានបញ្ចូលគ្នាយ៉ាងល្អ នោះទើបការផ្លាស់ប្តូរទីលំនៅនោះអាចនិយាយបានថាមានជោគជ័យ ។

ជាគោលការណ៍ និងគោលនយោបាយ អ្នកអភិវឌ្ឍន៍ និងរដ្ឋាភិបាលត្រូវផ្តល់នូវធនធានជាឧបករណ៍ និងហិរញ្ញវត្ថុដើម្បីអនុវត្តន៍នូវកម្មវិធីផ្លាស់ទីលំនៅក្នុងរបៀបមួយដែលនាំឱ្យមានការបង្កើនឡើងនូវជីវភាពរស់នៅ និងស្ថានភាពរស់នៅរបស់អ្នកដែលត្រូវជំលៀសទៅ និងអ្នកដែលរស់នៅដើមនៅទីនោះ ។ ត្រូវកាត់បន្ថយភាពក្រីក្រជាបន្ទាន់ ។ បើពុំនោះទេតំលៃ និងផលប្រយោជន៍នឹងនៅតែបន្តចែកចាយដោយមិនស្មើភាពរវាងអ្នកនៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធមកពីទីឆ្ងាយ ។

នៅក្នុងឆ្នាំកន្លងទៅថ្មីៗនេះគេបានយល់ឃើញថា ផ្ទុយពីអំណះអំណាងពីមុនៗគឺ វារីអគ្គិសនីមិនមែនគ្មានភាពក្រខ្វក់ខូចខាតនោះទេ ។ អាងទឹកដែលពុំបានកាប់ដើមឈើ ឬរុក្ខជាតិចេញនោះគឺជាប្រភពនៃការបំភាយឧស្ម័នដ៏សំខាន់មួយទៅក្នុងបរិយាកាសគឺឧស្ម័ន កាបូន ឌីអុកស៊ីត និងមេតាន ដែលចេញពីសារជាតិរលួយ អារូបិក និងអាណារូប៊ិក នៃអង្គជាតិសរីរាង្គក្នុងទឹក ។ បន្ថែមពីនោះទៀតទឹកដែលនៅជាយអាងជាជំរកនៃខ្យងដែលជាអ្នកទទួលនូវ បារ៉ាស៊ិត ពពួក ស៊ីតូសូមីញ៉ាស៊ីស និងមូសដែលមានមេរោគគ្រុនចាញ់ ។ គ្រោះថ្នាក់នៃជម្ងឺដែលបណ្តាលមកពីកត្តានេះអាចកើនឡើងយ៉ាងខ្លាំងក្រោយពេលអភិវឌ្ឍន៍ទំនប់ ។

ការដឹកជញ្ជូន និងធ្លាក់ចុះនៃកករ និងដីល្បាប់ដោយទឹកទន្លេ គឺជាប្រព័ន្ធអេកូឡូស៊ីដ៏សំខាន់មួយក្នុងពេលដែលទឹកធ្វើចលនា ។ ទំនប់បានធ្វើឱ្យប្រែប្រួលនូវចលនារបស់កករដែលត្រូវធ្លាក់ចុះ ហើយជាទូទៅក្នុងអាងតែងតែមានអត្រាច្រើនជាងអ្វីដែលគេបានគិតទុក ដែលនាំឱ្យបាត់បង់នូវសមត្ថភាពស្តុករបស់អាង ។ កករទាំងនេះនឹងមិនមែនសំរាប់បំពេញដី និងសារជាតិនៅតំបន់លិចទឹកផ្នែកខាងក្រោមទៀតទេ ឬក្នុងដីសណ្តមេគង្គទេ ហើយក៏មិនបានផ្តល់ជាជំរកដល់ប្រភេទសត្វនៅក្នុងទន្លេដែរ ។

ប្រព័ន្ធអេកូឡូស៊ីនៅលើដីដែលរួមមានព្រៃឈើ ដីសើម និងភ្នំ និងទីជំរកសត្វព្រៃដែលទាក់ទងតែងតែត្រូវបានបំផ្លាញទាំងស្រុង ឬផ្នែកខ្លះៗដោយសារអាងទឹក ។ គ្មានមធ្យោបាយណា ដើម្បីកាត់បន្ថយផលប៉ះពាល់នេះទេ ទោះជានៅពេលខ្លះអ្នកអភិវឌ្ឍន៍ត្រូវបានតំរូវឱ្យផ្តល់ថវិកាសំរាប់ការបង្កើតជំរកធម្មជាតិនៅកន្លែងដដែល ឬកន្លែងណាផ្សេងទៀតក៏ដោយវាអាចនៅតែបាត់បង់ដោយសារមូលហេតុណាមួយផ្សេងទៀតនោះដដែល ។

## ដំណោះស្រាយមួយចំនួនចំពោះការអភិវឌ្ឍន៍ទំនប់នាពេលអនាគត

នៅដំណាក់កាលដំបូងបង្អស់នៃគំរោង នៅមុនពេលដែលការជ្រើសរើសទីតាំង ឬផែនការវិស្វកម្មត្រូវបានកំណត់ រដ្ឋាភិបាល អ្នកធ្វើទំនប់ និងអ្នកធ្វើផែនការត្រូវតែឱ្យអ្នកពាក់ព័ន្ធទាំងអស់ចូលរួម គឺអ្នកដែលមានជីវិតរស់នៅ និងសិទ្ធរបស់គេដែលអាចត្រូវរងផលប៉ះពាល់សំខាន់ដោយគំរោងអភិវឌ្ឍន៍ទំនប់នោះ ។ អ្នកពាក់ព័ន្ធដែលអាចទទួលរងគ្រោះដោយការអភិវឌ្ឍន៍នោះត្រូវតែបានពិភាក្សាជាមួយលើបញ្ហាថា តើត្រូវអនុវត្តន៍គំរោងនោះតាមរបៀបណា ។ ក្នុងករណីនេះគំនិតដែលអាចនាំឱ្យមានគ្រោះថ្នាក់ នឹងមិនមានទេនៅពេលដែលបានធ្វើកិច្ចសន្យា និងជំរើសដ៏ល្អបំផុតនោះ អាចត្រូវយកមកជជែកពិភាក្សាដោយមានភាពយុត្តិធមិត្រឹមត្រូវចំពោះអ្នកដែលត្រូវទទួលរងគ្រោះ និងចំណាយនោះ ប៉ុន្តែនៅក្នុងពេលអតីតកាលពុំមានឥទ្ធិពលអ្វីទៅលើលទ្ធផលនោះទេ ។

ការសិក្សារៀនសូត្រពីគំរោងទំនប់មុនៗគឺជាភារៈកិច្ចសំខាន់ មុននឹងចាប់ផ្តើមគិតអនុវត្តន៍គំរោងថ្មីដូចគ្នានេះ ។ អង្គការ WCD បានរកឃើញថាក្រោយពេលបញ្ចប់ហើយ គំរោងធំៗមួយចំនួនត្រូវបានធ្វើការវាយតំលៃយ៉ាងត្រឹមត្រូវលើផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ បរិស្ថាន ឬជោគជ័យ និងបរាជ័យផ្នែកសង្គម ។ ជាលទ្ធផលគេឃើញមានកំហុសដដែលៗបានកើតឡើងម្តងហើយម្តងទៀត ។

ដូចបានកត់សំគាល់ក្នុងពេលមុន CEA អាចជួយផ្តល់នូវរូបភាពធំៗមួយនៃផលប៉ះពាល់ដែលអាចលើប្រព័ន្ធអេកូឡូស៊ីពីគំរោងអភិវឌ្ឍន៍ផ្សេងៗជាច្រើនក្នុងផ្ទៃរងទឹកភ្លៀងណាមួយ និងក្នុងអាង MRB ទាំងមូល ។ ហើយការវាយតំលៃ EIA លើគំរោងណាមួយ ដែលបានធ្វើយ៉ាងល្អិតល្អន់ និងក្នុងដំណាក់កាលដើមដំបូងនៃគំរោងអភិវឌ្ឍន៍ទំនប់អាចបញ្ជាក់ប្រាប់ពីការសំរេចចិត្តត្រូវសង់ ឬមិនសង់ ហើយនិងបញ្ជាក់ប្រាប់ពីបញ្ហាចំបង ដែលចាំបាច់ត្រូវមានវិធានការកាត់បន្ថយ ប្រសិនបើមានការសំរេចចិត្តត្រូវធ្វើនោះ ។

## ជំរើសផ្សេងៗមួយចំនួនក្រៅពីការសង់ទំនប់ធំៗ

នៅពេលមានការខ្វះថាមពល មុននឹងគិតថាតើត្រូវសង់ទំនប់ ឬទេដើម្បីផ្គត់ផ្គង់ដល់តំរូវការនោះ រដ្ឋាភិបាលត្រូវពិនិត្យមើលដោយយកចិត្តទុកដាក់នូវលទ្ធភាពក្នុងការសន្សំសំចៃនូវការប្រើប្រាស់បច្ចុប្បន្ននៃចរន្តអគ្គិសនី (ដែលហៅថាការគ្រប់គ្រងផ្នែកខាងតំរូវការ) ហើយក៏ត្រូវកាត់បន្ថយការបាត់បង់ដែលកើតឡើងខាងផ្នែកផលិតបញ្ជូន និងចែកចាយថាមពលនោះដែរ (ដែលហៅថាការគ្រប់គ្រងផ្នែកខាងផ្គត់ផ្គង់ ) ។ ជាការជាក់ស្តែងនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ គោលគំនិតនៃការសន្សំសំចៃផ្នែកតំរូវការ គឺនៅទាប បើប្រៀបធៀបទៅអ្នកប្រើប្រាស់ថាមពលច្រើននៅក្នុងប្រទេសលោកខាងលិច ។ ប៉ុន្តែក៏អាចឃើញមានការសន្សំសំចៃខ្លះដែរ ។

បច្ចេកវិជ្ជាដ៏សមរម្យ ក្នុងរូបភាពជាម៉ាស៊ីនផលិតអគ្គិសនីខ្នាតតូចអាចប្រើប្រាស់ក្នុងការឆ្លើយតបនឹងតំរូវការរបស់សហគមន៍មូលដ្ឋាន ប្រហែលជាការប្រើពន្លឺព្រះអាទិត្យ ខ្យល់ ឬបច្ចេកវិជ្ជាជីវម៉ាស់ ។ ការសាងសង់នូវទំនប់តូចៗច្រើន ជាជាងការសង់ទំនប់ធំមួយគឺត្រូវបានកំពុងលើងតំកើងថាជាជំរើសដែលមានប្រសិទ្ធិភាពខាងតំលៃ និងហិរញ្ញវត្ថុសំរាប់ការផ្គត់ផ្គង់ដល់តំរូវការក្នុងមូលដ្ឋាន ។ ជាទូទៅទំនប់កាត់ទន្លេ ដែលទន្លេមិនត្រូវបានស្ទាក់ទឹកធ្វើជាអាង ហើយរំហូរទឹកមិនបានបង្អាក់តាមរយៈទួប៊ីនទេនោះ គឺវាមានលក្ខណៈខូចខាតតិចជាងទំនប់ដែលត្រូវស្តុករំហូរទឹកទន្លេនោះ ។ ទំនប់ប្រភេទនេះតែងតែត្រូវបានសាងសង់នៅផ្នែកខាងក្រោមនៃទំនប់ដែលស្តុកទឹកដើម្បីចាប់យកប្រយោជន៍ពីទឹកដែលបានគេប្រើរួចទៅហើយនោះ ។ ហើយវាក៏បណ្តាលឱ្យមានផលប៉ះពាល់បរិស្ថានតិចផងដែរជាងទំនប់ដែលសង់លើទន្លេដែលមិនទាន់បានធ្វើអ្វីនោះ ដោយសារការខូចខាតធំៗបានកើតឡើងរួចទៅហើយ នៅពេលដែលទំនប់មុននោះត្រូវបានគេសាងសង់នោះ ។

## សង្ខេបចំណុចសំខាន់ៗ

- ការចាំបាច់ត្រូវគិតគូរឱ្យបានល្អិតល្អន់ថា តើត្រូវគ្រប់គ្រងធនធានទឹកសាបដោយរបៀបណា គឺជាការខិតខំប្រឹងប្រែងដ៏សំខាន់មួយ ដែលពិភពលោកកំពុងប្រឈមមុខក្នុងសតវត្សថ្មីនេះ ។
- របរជំនួញ ជាធម្មតា គឺវាមិនមានលក្ខណៈប្រសិទ្ធភាពល្អ និងគួរឱ្យចង់បានទេ ។
- ត្រូវរកមធ្យោបាយក្នុងការចែកចាយឱ្យបានស្មើភាពគ្នានូវធនធានទឹក និងដោយនិរន្តរភាព ដោយឆ្លើយតបនឹងតំរូវការរបស់ប្រជាជន បរិស្ថាន និងការអភិវឌ្ឍន៍សេដ្ឋកិច្ច ។
- អនាគតនៃការអភិវឌ្ឍន៍ធនធានទឹក គឺឋិតក្នុងការចូលរួមក្នុងការសំរេចចិត្ត ដោយប្រើវិធីសាស្ត្រដែលគិតគូរដល់ សិទ្ធិ និងគ្រោះថ្នាក់ ។
- ត្រូវអនុវត្តន៍នូវការចូលរួមដោយមានន័យ និង ទូលំទូលាយ នៅគ្រប់ដំណាក់កាលទាំងអស់ ដែលនាំឱ្យមានការជជែកពិភាក្សាពីលទ្ធផលដោយចំហរ ។
- ផលប៉ះពាល់នៃទំនប់លើបរិស្ថាន និងសង្គមគួរត្រូវផ្តល់នូវការគិតគូរស្មើៗគ្នាលើគ្រប់កត្តាសេដ្ឋកិច្ចទាំងអស់ ។

- រដ្ឋាភិបាលត្រូវត្រួតពិនិត្យ និងទាត់ចោលនូវគំរោងដែលមិនសមស្របឱ្យបានមុន និងធ្វើការសំរបសំរួលគ្នារវាងវិស័យផ្សេងៗនៅក្នុងអាងទន្លេ ។
- អ្នកអភិវឌ្ឍន៍ត្រូវទទួលខុសត្រូវដោយមានការប្តេជ្ញាចិត្ត ដើម្បីកាត់បន្ថយនូវផលប៉ះពាល់លើសង្គម និងបរិស្ថាន។
- ការបង្កើននូវការអនុវត្តន៍តាមច្បាប់ អាចធ្វើទៅបានតាមរយៈការត្រួតពិនិត្យដោយឯករាជ្យនូវការអនុវត្តផ្នែកសេដ្ឋកិច្ច បរិស្ថាន និងសង្គម ។
- អ្នកធ្វើទំនប់ត្រូវរៀនសូត្រនូវបទពិសោធន៍ពីអតីតកាល ហើយមិនត្រូវធ្វើកំហុសដដែលនោះទេ ។
- ត្រូវផ្តោតការយកចិត្តទុកដាក់លើ :
  - ការវាយតំលៃនៃមតិយោបល់ទាំងអស់រួមទាំង "មិនត្រូវសាងសង់"ផង
  - លទ្ធភាពក្នុងការបង្កើនការអនុវត្តន៍
  - លើកឡើងពីបញ្ហាមរតកនៃទំនប់ដែលមានស្រាប់
  - ការបែងចែកស្មើភាពនូវផលប្រយោជន៍ក្នុងការអភិវឌ្ឍន៍ធនធានទឹកដោយនិរន្តរភាព ។

## អនុសាសន៍មួយចំនួនរបស់គណៈកម្មការពិភពលោកស្តីពីទំនប់

របាយការណ៍របស់គណៈកម្មការពិភពលោកស្តីពីទំនប់ (WCD) បានលើកឡើងនូវអនុសាសន៍ជាច្រើន និងកំណត់នូវលក្ខខណ្ឌ និងគោលការណ៍ណែនាំ ដែលគេជឿថាគួរត្រូវអនុវត្តន៍លើទំនប់ដែលឋិតក្នុងដំណាក់កាលធ្វើផែនការ ដំណាក់កាលសាងសង់ និងទំនប់ដែលបានដំណើរការហើយ ។ និយាយម្យ៉ាងទៀត គឺថា WCD មានបំណងចង់អនុវត្តន៍នូវការរកឃើញរបស់ខ្លួនទៅលើទំនប់ទាំងអស់ ទោះជាក្នុងដំណាក់កាលអភិវឌ្ឍន៍ និងដំណើរការណាក៏ដោយ ។ ចំណុចសំខាន់ៗនៃការរកឃើញ អនុសាសន៍ លក្ខខណ្ឌ និងគោលការណ៍ណែនាំមួយចំនួនក្នុងរបាយការណ៍របស់ WCD មានសង្ខេបដូចខាងក្រោមនេះ ។

### ផលប្រយោជន៍ និងតំលៃនៃទំនប់

អង្គការ WCD បានសន្និដ្ឋានថា ទំនប់បានចូលរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍន៍របស់មនុស្ស និងបានផ្តល់នូវផលប្រយោជន៍យ៉ាងច្រើន ។ ប៉ុន្តែក្នុងករណីជាច្រើន វាមានតំលៃថ្លៃក្នុងន័យនៃការប៉ះពាល់លើការជំលៀសប្រជាជន សហគមន៍ខាងក្រោមខ្សែទឹក ប្រជាពលរដ្ឋដទៃទៀត និងបរិស្ថានធម្មជាតិ ។ ការចែកចាយនូវផលប្រយោជន៍នៃការអភិវឌ្ឍន៍ច្រើនមានភាពមិនស្មើភាព ។ ការអភិវឌ្ឍន៍ទំនប់ត្រូវរួមបញ្ចូលគ្នា និងមានតុល្យភាពរវាងសង្គម បរិស្ថាន និង សេចក្តីត្រូវការផ្នែកសេដ្ឋកិច្ច ។ ការអភិវឌ្ឍន៍ដោយគ្មាននិរន្តរភាពត្រូវតែលុបបំបាត់ជាមុនក្នុងដំណើរការសំរេចចិត្ត ហើយលក្ខណ្ឌ និងដំណើរការជ្រើសរើសយកការអភិវឌ្ឍន៍ទំនប់ត្រូវតែមានតម្លាភាព ។ កិច្ចសហការរវាងសហគមន៍ និងថ្នាក់ជាតិដើម្បីសំរេចបាននូវនិរន្តរភាព និងការចែកចាយនូវធនធានទឹកដ៏ស្មើភាព គឺជាគោលដៅចំបង ។

ត្រូវជៀសវាងផលប៉ះពាល់ខ្លាំងមិនអាចកែបានលើប្រព័ន្ធអេកូឡូស៊ី ដោយកែតំរូវគំរោងទំនប់ប្រសិនបើចាំបាច់ ។ រំហូរទឹកនៅខ្សែទឹកខាងក្រោម គួរត្រូវស្របតាមសេចក្តីត្រូវការរបស់បរិស្ថាន ហើយត្រូវកាត់បន្ថយ ឬធ្វើការទូទាត់ចំពោះផលប៉ះពាល់លើប្រព័ន្ធអេកូឡូស៊ីដែលមិនអាចជៀសវាងបាន ។ តំរូវការត្រូវតែបានកំណត់ឱ្យច្បាស់លាស់ ចំពោះភាពស្របច្បាប់ ការត្រួតពិនិត្យ និងលទ្ធផលនៃភាពមិនស្របច្បាប់ ។

### វិធីសាស្រ្តដែលគិតដល់គ្រោះថ្នាក់ និងសិទ្ធិ ចំពោះការសំរេចចិត្តលើការអភិវឌ្ឍន៍ទំនប់

អនុសាសន៍នេះបញ្ជាក់ពីគោលការណ៍របស់ប្រជាជនដែលសិទ្ធិរបស់គេអាចរងផលប៉ះពាល់ និងអ្នកដែលទទួលរងគ្រោះថ្នាក់ដោយការអភិវឌ្ឍន៍ទំនប់ (ជាពិសេសអ្នកដែលគ្រោះថ្នាក់ត្រូវធ្លាក់ទៅលើ) ត្រូវចូលរួមតាំងពីដំណាក់កាលចាប់ផ្តើមដំបូងជាអ្នកចូលរួមស្មើភាពគ្នាក្នុងការចរចារដោយមានតម្លាភាព ដើម្បីដោះស្រាយការប្រកួតប្រជែងផលប្រយោជន៍ ដោយមិនគិតពីស្ថានភាពសេដ្ឋកិច្ច និង សង្គមរបស់គេ ។ សិទ្ធនៃក្រុមអ្នកពាក់ព័ន្ធស្របច្បាប់ទាំងអស់ត្រូវតែបានបញ្ជាក់ឱ្យច្បាស់ដើម្បីឱ្យគេមានតួនាទីត្រឹមត្រូវក្នុងការពិភាក្សា និងការសំរេចចិត្ត

ឱ្យសមនឹងគ្រោះថ្នាក់ដែលត្រូវធ្លាក់មកលើគេ ។ ការវិភាគលើការចែកចាយគឺជាការចាំបាច់ដើម្បីកំណត់ថាក្រុមណាដែលរ៉ាប់រងតំលៃ និងក្រុមណាមួយដែលទទួលបានផលប្រយោជន៍ពីគំរោង ។

## អាទិភាពជាយុទ្ធសាស្ត្រ លក្ខខណ្ឌ និងគោលការណ៍ណែនាំរបស់អង្គការ WCD

**អាទិភាពជាយុទ្ធសាស្ត្រទី ១ :** ការទទួលបាននូវការយល់ស្របរបស់សាធារណៈ

លក្ខណ្ឌ ( • ) និង គោលការណ៍ណែនាំ ( - )

- កំណត់ថាអ្នកណាជាអ្នកពាក់ព័ន្ធស្របច្បាប់
- បង្កើតនូវដំណើរការធ្វើការសំរេចចិត្តដោយមានការជជែកពិភាក្សា
- ធានាឱ្យមានការយល់ព្រម និងជូនដំណឹងជាមុនពីគ្រប់បណ្តាអ្នកចូលរួមក្នុងការសំរេចចិត្ត

- ទទួលស្គាល់នូវសិទ្ធិរបស់ក្រុមអ្នកដែលទទួលរងផលប៉ះពាល់ ជាពិសេសប្រជាជនមូលដ្ឋាន ស្ត្រី និងអ្នករងគ្រោះផ្សេងទៀត
- ជំរុញឱ្យមានការចូលរួមដោយស្ម័គ្រចិត្តពីគ្រប់ក្រុមទាំងអស់ក្នុងការសំរេចចិត្ត

**អាទិភាពជាយុទ្ធសាស្ត្រទី ២ :** ការវាយតំលៃដ៏ល្អិតល្អន់លើជំរើសផ្សេងៗ

លក្ខណ្ឌ (• ) និង គោលការណ៍ណែនាំ ( - )

- អនុវត្តន៏នូវការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសេដ្ឋកិច្ច-សង្គមក្នុងកំរិតគំរោង និងកំរិតរួម និងកំរិតយុទ្ធសាស្ត្រ
- អនុវត្តនូវការវិភាគលើលក្ខណ្ឌច្រើនករណី
- អនុវត្តន៏នូវការវាយតំលៃលើរយៈពេលរស់នៅ
- វាយតំលៃលើលទ្ធភាពបំភាយឧស្ម័ន
- អនុវត្តន៏នូវការវិភាគលើការចែកចាយ

- វាយតំលៃលើគ្រប់ជំរើសក្រៅពីទំនប់ក្នុងពេលធ្វើសមិទ្ធិសិក្សា និងបន្តរហូតដំណាក់កាលធ្វើផែនការអភិវឌ្ឍន៏ និងកិច្ចដំណើរការ
- ផ្តល់នូវការគិតគូរដល់ផ្នែកសង្គម និងបរិស្ថាននូវតំលៃស្មើគ្នាដូច នឹងកត្តាសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែរ

**អនិភាពជាយុទ្ធសាស្ត្រទី ៣ :** លើកឡើងពីទំនប់ដែលមានស្រាប់

លក្ខណ្ឌ (•) និង គោលការណ៍ណែនាំ ( - )

- ធានាថាច្បាប់នៃកិច្ចដំណើរការបានឆ្លើយតបទៅ នឹងការព្រួយបារម្ភផ្នែកសង្គម និងបរិស្ថាន
- បង្កើនកិច្ចដំណើរការរបស់អាងទឹក

\- កាលៈទេសៈផ្លាស់ប្តូរទៅតាមពេលវេលា ត្រូវពិនិត្យឡើងវិញនូវផលប៉ះពាល់នៃកិច្ចដំណើររបស់ទំនប់ដែលមាន រួមទាំងវិធានការ និងភារៈកិច្ច

**អនិភាពជាយុទ្ធសាស្ត្រទី ៤ :** ធ្វើឱ្យមានស្ថេរភាពទន្លេ និងការរស់នៅ

លក្ខណ្ឌ (•) និង គោលការណ៍ណែនាំ ( - )

- ធ្វើការសង្កេតលើស្ថានភាពប្រព័ន្ធអេកូឡូស៊ីជាមូលដ្ឋាន
- វាយតំលៃលើតំរូវការបរិស្ថាននៃរំហូរទឹក
- ថែរក្សានូវផលិតភាពជលផល

\- ការអភិវឌ្ឍន៏របស់មនុស្សដោយស្មើភាព និងសុខុមាលភាពនៃប្រភេទសត្វទាំងអស់ អាស្រ័យលើការយល់ដឹង ការការកាពារ និងការស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីទន្លេ

\- អាទិភាព គឺជាការវាយតំលៃលើជំរើសផ្សេងៗ ការជៀសវាងផលប៉ះពាល់ការកាត់បន្ថយគ្រោះថ្នាក់ដល់សុខភាព និងការគិតបញ្ចូលគ្នានូវប្រព័ន្ធទន្លេ ការជ្រើសរើសទីតាំង និងការគិតគូរគំរោង

\- ប្រព័ន្ធអេកូឡូស៊ីនៅខ្សែទឹកខាងក្រោម និងសហគមន៏អាចត្រូវថែរក្សាបានដោយការបញ្ចេញនូវទឹកដោយក្នុងលក្ខណៈបរិស្ថានល្អមួយ ។

**អនិភាពជាយុទ្ធសាស្ត្រទី ៥ :** ការទទួលស្គាល់នូវការចែកសិទ្ធអំណាច និងផលប្រយោជន៏

លក្ខណ្ឌ (•) និង គោលការណ៍ណែនាំ ( - )

- វាយតំលៃលើមូលដ្ឋានស្ថានភាពសង្គមមុននឹងធ្វើការអភិវឌ្ឍន៏
- ធ្វើការវិភាគលើគ្រោះថ្នាក់ដល់ភាពក្រីក្រពីការអភិវឌ្ឍន៏
- បង្កើតនូវយន្តការបែងចែកផលប្រយោជន៏ពីគំរោង
- អនុវត្តន៏នូវវិធានការកាត់បន្ថយការផ្លាស់ទីលំនៅ និងផែនការសកម្មភាពអភិវឌ្ឍន៏

\- ការពិភាក្សាជាមួយអ្នកដែលត្រូវទទួលផលប៉ះពាល់អាក្រក់គឺត្រូវឱ្យមានលទ្ធផលក្នុងលក្ខណៈយោគយល់គ្នាទៅវិញទៅមក និងដែលអាចធ្វើទៅបានតាមលក្ខណៈច្បាប់

- ការអភិវឌ្ឍន៍ និងការកាត់បន្ថយផលប៉ះពាល់ និងការផ្លាស់ប្តូរទីលំនៅដោយជោគជ័យ គឺជាការទទួលខុសត្រូវរបស់រដ្ឋ និងអ្នកអភិវឌ្ឍន៍
- ជីវភាពរស់នៅរបស់ប្រជាជនដែលរងផលប៉ះពាល់ត្រូវតែបានបង្កើនជាបន្ទាន់

**អនិភាពជាយុទ្ធសាស្ត្រទី ៦ :** ធានានូវភាពសមស្រប

លក្ខណ្ឌ (•) និង គោលការណ៍ណែនាំ ( - )

- បង្កើតនូវផែនការនៃភាពសមស្រប
- បង្កើតវេទិកាត្រួតពិនិត្យឯករាជ្យចំពោះបញ្ហាបរិស្ថាន និងសង្គម
- ការធានាក្រោយពេលអនុវត្តន៍
- បង្កើតនូវមូនិធិនៃការទុកចិត្ត
- បង្កើតនូវកតិកាសញ្ញា ស្តីពីភាពសុចរិត

- រដ្ឋាភិបាល អ្នកអភិវឌ្ឍន៍ និងអ្នកអនុវត្តន៍ត្រូវធ្វើតាមការប្តេជ្ញារបស់ខ្លួន
- អ្វី១ទាំងអស់ត្រូវតែសមស្របតាមបទញ្ញាតិដែលទាក់ទង លក្ខណ្ឌ សេចក្តីណែនាំ និងកិច្ចព្រមព្រៀងក្នុងគ្រប់ដំណាក់ការនៃការអភិវឌ្ឍន៍ និងដំណើរការ
- ការប្រើប្រាស់នូវការលើកចិត្ត និងការដាក់ទណ្ឌកម្មអាចជួយក្នុងការឆ្លើយតបទៅ នឹងកាលៈទេសៈដែលបានផ្លាស់ប្តូរ

**អនិភាពជាយុទ្ធសាស្ត្រទី ៧ :** ចែកចំណែកទន្លេ ដើម្បីសន្តិភាព ការអភិវឌ្ឍន៍ និងសន្តិសុខ

គោលការណ៍ណែនាំ ( - )

- ក្នុងប្រព័ន្ធទន្លេដែលឆ្លងដែន ទំនប់ និងការបង្វែរទឹក តំរូវឱ្យមានកិច្ចសហការពីរដ្ឋដែលរងផលប៉ះពាល់ទាំងអស់
- រដ្ឋត្រូវតែយល់ព្រមប្រើប្រាស់ និងគ្រប់គ្រងធនធាន ដើម្បីបង្កើននូវកិច្ចសហការក្នុងតំបន់ និងសហប្រតិបត្តិការដោយសន្តិភាព
- ចាំបាច់ត្រូវមានការផ្លាស់ប្តូរពីការរក្សាទុកនូវធនធានទឹក ទៅជា ការចែករំលែកនូវប្រព័ន្ធទន្លេ និងផលប្រយោជន៍ដែលពាក់ព័ន្ធផ្សេង១របស់វា ។

# សារៈសំខាន់នៃព្រៃឈើចំពោះអាង MRB

~~~~~~~

ព្រៃឈើដែលមានស្ថានភាពសុខភាពល្អដែលជាផ្នែកមួយនៃប្រពន្ធ័អេកូឡូស៊ី និងប្រពន្ធ័អេកូឡូស៊ីខ្លួនឯងនេះបានជួយដល់ការថែរក្សាគុណភាពទឹក និងការពារធនធានទឹកពីភាពក្រខ្វក់ ។ ព្រៃឈើគឺជាផ្នែកមួយនៃធារាសាស្ត្ររបស់អាងទន្លេមេគង្គ (MRB) ដែលជួយទ្រទ្រង់ដល់ផ្លូវទឹក និងទន្លេជាមួយនិងរំហូរទឹក និងកករវិលវល់ក្នុងទឹកដែលវាបង្កើតជាគន្លងទន្លេ និងទ្រង់ទ្រាយរបស់វា ។ ដើមឈើ និងប្រព័ន្ធឫសដែលផ្តល់ដោយរុក្ខជាតិបានធ្វើឱ្យមានស្ថេរភាពដី ដោយការពារនូវសំណឹកដីនៅពេលមានភ្លៀង និងជួយកុំឱ្យបាក់ដីនៅតំបន់ភ្នំ ។ ដោយរក្សាទឹកទុក និងបញ្ចេញវាទៅក្នុងផ្លូវទឹកជាបន្តបន្ទាប់ ព្រៃឈើបានកាត់បន្ថយនូវដង់ស៊ីតេទឹកជំនន់នៅរដូវវស្សា ។

ជាក់ស្តែងនូវពេលដែលព្រៃឈើត្រូវបានគេកាប់ ការការពារដែលវាធ្លាប់មានក៏ត្រូវបានបាត់បង់ដែរនាំឱ្យមានការប្រែប្រួលនូវផ្លូវទឹក និងទន្លេ មានការកើនឡើងនូវកករនិងបាត់បង់ដី បាក់ដី និងមានទឹកជំនន់ ។ ផ្ទៃដីដ៏ធំធេងក្នុងប្រទេស វៀតណាម និង ថៃ បានត្រូវបាត់បង់ដោយសារការបាក់ដី និងទឹកជំនន់ដែលបណ្តាលមកពីការបំផ្លាញព្រៃឈើ ។ ការកាប់ដើមឈើក្នុងព្រៃលិចទឹក និង តំបន់ដីសើមនៅប្រទេស កម្ពុជា និង វៀតណាម ការបំផ្លាញដល់ជំរកត្រី សត្វស្លាប និង សារធាតុសរីរាង្គផ្សេងៗដែលវាបានចិញ្ចឹមជីវិត ។

ព្រៃឈើក្នុងអាង MRB បានផ្តល់នូវសេវាកម្មជាច្រើនទៀតដោយមិនគិតថ្លៃ ។ វាបានផ្តល់នូវឈើមានតំលៃ អាហារ និងថ្នាំធម្មជាតិ ទីជំរកសំរាប់សហគមន៍មូលដ្ឋាន និងជាជំរកសំរាប់ជីវិតសត្វ និងរុក្ខជាតិជាច្រើនប្រភេទទៀត ។ ព្រៃឈើគឺជាប្រភពខ្យល់ត្រជាក់ធម្មជាតិ និងប្រពន្ធ័សំអាតធម្មជាតិ វាបានស្រូបយកកំដៅថ្ងៃ និងកាបូនឌីអុកស៊ីតដែលអាចធ្វើឱ្យបន្ថែមភាពក្តៅទៅក្នុងបរិយាកាស ព្រៃឈើក៏បានស្រូបយកខ្យល់ក្រខ្វក់ និងបញ្ចេញអុកស៊ីសែ្សន ។ សំរាប់ប្រជាជនមូលដ្ឋាន ព្រៃឈើជាកន្លែងសក្ការៈវប្បធម៌ប្រពៃណីនៃរបៀបរស់នៅ ។ ហើយ ទោះជាមិនទាន់បានអភិវឌ្ឍន៍ឱ្យបានល្អក៏ដោយព្រៃឈើនៅក្នុងអាង MRB មានលទ្ធភាពទាក់ទាញភ្ញៀវទេសចរណ៍ និងជាកន្លែងមានតំលៃផ្នែកសោភណ៍ភាព និងការលំហែរកាយ ។ ផលប្រយោជន៍ទាំងនេះត្រូវផ្តល់ដោយគ្មានការជួយ និងប្រឹងប្រែងរបស់មនុស្សឡើយ ។ ព្រៃឈើធម្មជាតិក្នុងអាង MRB មិនត្រូវការការថែរក្សាហ្មត់ចត់ណាស់ណាទេ ប៉ុន្តែគ្រាន់តែការពារកុំឱ្យមានការរំខានទៅបានហើយ ។
~~~~~~~

## ការគំរាមគំហែងលើព្រៃឈើក្នុងអាង MRB

តើអ្វីជាការរំខានដល់ព្រៃឈើក្នុងអាង MRB ?

គ្រោះថ្នាក់ធំបំផុតគឺការកើតឡើងនៃការកាប់ឈើខុសច្បាប់ កាប់ឈើសំរាប់លក្ខណៈពាណិជ្ជកម្ម និងរបៀបកាប់ឈើមិនសមរម្យ ។ នៅក្នុងអាង MRB ទាំងមូលមានការខ្វះខាតធនធានមនុស្ស ចំណេះដឹង និងហេដ្ឋារចនាសម្ព័ន្ធដើម្បីត្រួតពិនិត្យការកាប់ឈើខុសច្បាប់ ហួសហេតុ និងបំផ្លិចបំផ្លាញ ។ នៅក្នុងប្រទេសកម្ពុជាគេបានប៉ាន់ស្មានថាមានឡានដឹកឈើចំនួន ២៥០០ឡាន បានដឹកចេញពីប្រទេសរៀងរាល់ថ្ងៃ ដែលបណ្តាលឱ្យបាត់បង់ដីព្រៃអស់ ២៥០០០០ ហត រៀងរាល់ឆ្នាំ ។ មានព្រៃឈើតែ ៤.៥% ប៉ុណ្ណោះនៅក្នុងប្រទេសឡាវដែលគេចាត់ទុកថាមានតំលៃជាលក្ខណៈពាណិជ្ជកម្ម ។ ផ្ទៃដីនៅក្នុងប្រទេសថៃ ដែលឋិតនៅក្នុងផ្ទៃអាងទន្លេមេគង្គមានដីព្រៃតែ ១៣% ប៉ុណ្ណោះគឺមានការថយចុះ ៦៩% ក្នុងរយៈពេល ៣០ឆ្នាំកន្លងមកនេះ ។ ហើយក្នុងប្រទេសវៀតណាម ដីព្រៃ ៣០% ត្រូវបាត់បង់ក្នុងរយៈពេល ៣០ ឆ្នាំកន្លងមកនេះ ហើយព្រៃឈើនៅក្នុងដីសណ្តមេគង្គមានតែ ៩% ប៉ុណ្ណោះក្នុងឆ្នាំ ១៩៩១ (ADB 2000, MRC 1997) ។

ការរកឧសរបស់ប្រជាជនមូលដ្ឋានក៏ជាការរួមចំណែកក្នុងការបាត់បង់ព្រៃឈើក្នុងអាង MRB ដែរ ទោះបីជាការប៉ះពាល់នោះមិនមានភាពច្បាស់លាស់ បើប្រៀបធៀបទៅនឹងការកាប់ឈើជាលក្ខណៈពាណិជ្ជកម្ម និងឧស្សាហកម្មក៏ដោយ ។ ការដុតព្រៃដើម្បីរានដីធ្វើកសិកម្ម និងវាលស្មៅគឺជាមូលហេតុធំមួយទៀតនៃការបាត់បង់ ហើយការកាប់នូវរុក្ខជាតិមានតំលៃ និងកំរដោយអ្នកដើររកនោះក៏ជាលទ្ធផលនាំឱ្យបាត់បង់ជំរកព្រៃឈើដែរ ។

មានការធ្លាក់ចុះព្រៃឈើដោយការគំរាមគំហែងក្នុងអាង MRB ការបាត់បង់របស់វាបានកើនឡើងនូវភាពក្តៅក្នុងបរិយាកាស ដែលនាំឱ្យមានកើននូវសម្ពាធលើធនធានព្រៃឈើដែលនៅសល់តាមរយៈការប្រែប្រួលអាកាសធាតុ និងការបង្កើនគ្រោះថ្នាក់នៃការឆេះព្រៃ ។

## ផលប៉ះពាល់នៃការបាត់បង់ព្រៃឈើក្នុងអាង MRB

បន្ថែមពីលើផលប៉ះពាល់ទៅលើធនធានទឹកក្នុងអាង MRB ក្នុងរូបភាពនៃការកើនឡើងនូវការហូរដាច់ដីល្បាប់កករ ការបាក់ដី និងការបាត់បង់នូវជំរកបង្កកំណើត និងចិញ្ចឹមត្រីក្នុងបឹងទន្លេសាបនោះ ការកាប់ព្រៃបានធ្វើឱ្យថយចុះនូវជីវចំរុះ បំផ្លាញនូវជំរកសត្វលើគោក និងថយចុះគុណភាពដី ដោយសារសារជាតិភាគច្រើននៅក្នុងប្រព័ន្ធអេកូឡូស៊ីព្រៃឈើគឺត្រូវបានផ្ទុកនៅក្នុងរុកជាតិគឺមិនមែននៅក្នុងដីទេ ។ នៅក្នុងតំបន់ដីសណ្តមេគង្គ ការកាប់នូវព្រៃកោងកាង បាននាំឱ្យតំបន់ឆ្នេរទទួលរងគ្រោះខ្លាំងនៃការហូរដាច់ដីដោយសាររលកដែលនាំឱ្យមានការកើនឡើងនូវការជ្រាបទឹកជាតិអំបិលទៅក្នុងដីមានជីជាតិនៅតំបន់ដីសណ្ត និងការបំផ្លាញជំរកបង្ករកំណើត និងចិញ្ចឹមសំខាន់ៗសំរាប់ជីវិតសត្វក្នុងទឹក ។

## ព្រៃដាំ

ផលប៉ះពាល់នៃភាពគ្មាននិរន្តរភាពនៃព្រៃដាំបានបង្ហាញនៅក្នុងមេរៀន ទី ២ ដូចនេះ យើងគ្រាន់តែពិនិត្យមើលឡើងវិញដោយសង្ខេបទេនៅពេលនេះ ។ ដើមឈើដាំតែងតែជាប្រភេទនាំមកពីខាងក្រៅ ( គឺមិនមែនប្រភេទក្នុងតំបន់អាង MRB ) ដែលអាចដុះលឿន និងផ្តល់នូវគុណភាពពិសេសណាមួយ ហើយដែលអាចគ្រប់គ្រងជាលក្ខណៈដំណាំកសិកម្ម ។ ដើមឈើប្រភេទនេះតែងតែត្រូវការកំរិតជីវជាតិខ្ពស់ ហើយស្លឹកដែលជ្រុះមករបស់វាអាចធ្វើឱ្យខូចដល់កំរិត pH របស់ដី ។ ដោយសារតែព្រៃដាំច្រើនតែជាព្រៃដែលមានដើមឈើតែមួយប្រភេទ ដែលរុក្ខជាតិបន្ទាប់បន្សំផ្សេងទៀតត្រូវបានគ្របដណ្តប់ ជីវចំរុះអាចមានតិចហើយគ្រោះថ្នាក់នៃការបាត់បង់ដោយជម្ងឺមានខ្ពស់ ។ ព្រៃដាំផ្តល់នូវលទ្ធភាពការពារការហូរដាច់ដីតិចជាងព្រៃធម្មជាតិដែលសំបូរឈើច្រើនប្រភេទ ។

## ការឆ្លើយតបនៅនឹងការបាត់បង់ព្រៃក្នុងអាង MRB

យើងបានដឹងហើយថាព្រៃឈើវាមានសារៈសំខាន់យ៉ាងណាចំពោះគុណភាពទឹក ធារាសាស្ត្រ ជីវចំរុះ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងអាង MRB និងថាតើភាពធន់របស់វានោះខ្លាំងយ៉ាងណាចំពោះការគំរាមគំហែងដ៏ធ្ងន់ធ្ងរនោះ ។ ឥឡូវនេះយើងត្រូវពិនិត្យមើលថាតើត្រូវធ្វើអ្វីខ្លះចំពោះបញ្ហាដ៏ធ្ងន់ធ្ងរទាំងនេះ ។

កម្មវិធី Agenda 21 គោលនយោបាយ និងគោលការណ៍ដែលបានឯកភាពនៅក្នុងកិច្ចប្រជុំកំពូលស្តីពីផែនដីក្នុងឆ្នាំ ១៩៩២ បានផ្តល់នូវប្រយោជន៍ដូចខាងក្រោមជាពិសេសចំពោះព្រៃឈើ :

- ធ្វើឱ្យមានភាពស្របគ្នារវាងគោលនយោបាយថ្នាក់ជាតិ និងតំបន់ ច្បាប់ស្ថាប័ន និងការធ្វើផែនការសំរាប់ព្រៃឈើដើម្បីលុបបំបាត់នូវភាពត្រួតស៊ីគ្នា និងភាពមិនស្របគ្នារវាងកត្តាទាំងនោះ ។
- បញ្ចូល និងទំនាក់ទំនងគ្នា និងធ្វើវិមជ្ឈការស្ថាប័នគ្រប់គ្រងព្រៃឈើដើម្បីបង្កើននូវប្រសិទ្ធភាពផ្នែកគ្រប់គ្រងរដ្ឋបាល និងលុបបំបាត់ការប្រកួតប្រជែង និងជម្លោះក្នុងភារៈកិច្ច ។
- ជំរុញឱ្យមានការចូលរួមពីសំណាក់សហគមន៍មូដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល (NGO) ប្រជាជនមូលដ្ឋាន និងស្ត្រី ក្នុងការសំរេចចិត្តស្តីពីព្រៃឈើក្នុងតំបន់ដែលគេរស់នៅ ។
- បង្កើតនូវជំនាញបច្ចេកទេសដែលចាំបាច់ក្នុងការការពារថែរក្សាព្រៃឈើតាមរយៈកម្មវិធីបណ្តុះបណ្តាល ។
- អប់រំណែនាំសាធារណៈជនអំពីតំលៃនៃព្រៃឈើ និងមធ្យោបាយថៃទាំធនធាន
- ធ្វើការស្រាវជ្រាវលើអេកូឡូស៊ីព្រៃឈើ រុក្ខវប្បកម្ម និងការប្រមូលផល ។

ដោយសារសហគមន៍មូលដ្ឋាន និងប្រជាជនមូលដ្ឋានមានទំនាក់ទំនងពិសេស និងពឹងផ្អែកលើធនធានព្រៃឈើនោះ កម្មវិធី Agenda 21 មានអនុសាសន៍ពិសេសសំរាប់ពួកគេដូចខាងក្រោមៈ

- រដ្ឋាភិបាលត្រូវគាំទ្រដល់អត្តសញ្ញាណ វប្បធម៌ និងសិទ្ធរបស់ប្រជាជនមូលដ្ឋានហើយជំរុញឱ្យពួកគេៈ
    - ចូលរួមក្នុងការប្រើប្រាស់ជាលក្ខណៈសេដ្ឋកិច្ចលើព្រៃឈើ

- ថែរក្សានូវអត្តសញ្ញាណវប្បធម៌ និង សង្គម និង
- សំរេចបាននូវសុខមាលភាព និងជីវភាពរស់នៅដ៏គ្រប់គ្រាន់ ។

- រដ្ឋាភិបាលត្រូវប្រគល់ការកាន់កាប់ដីដល់ប្រជាជនមូលដ្ឋានដើម្បីលើកទឹកចិត្តដល់គេក្នុងកាគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ។

ការបង្កើតនូវយុទ្ធសាស្ត្រកម្មវិធី និងផែនការចាំបាច់សំរាប់អនុវត្តន៍នូវគោលនយោបាយ និង គោលការណ៍កម្មវិធី Agenda 21 ក្នុងអាង MRB គឺជាការទទួលខុសត្រូវរបស់រដ្ឋាភិបាល គណៈកម្មាធិការទន្លេមេគង្គ (MRC) និងអង្គភាពអនុវត្តន៍ក្នុងប្រទេសជាសមាជិកនិមួយៗ ។ ប្រពន្ធ័បញ្ជាក់ពីព្រៃឈើដែលបានត្រូវកំពុងប្រើប្រាស់នៅក្នុងតំបន់ខ្លះនៃពិភពលោកអាចផ្តល់ជាប្រយោជន៍មួយដល់ការប្រើប្រាស់ធនធានព្រៃឈើដោយនិរន្តភាព ។

## ការបញ្ជាក់ពីការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព

ព្រៃឈើមានតួនាទីធំធេងក្នុងផ្នែកសុខភាពនៃប្រពន្ធ័អេកូឡូស៊ីនៃអាងទន្លេមេគង្គ ដែលការអភិវឌ្ឍន៍ដោយនិរន្តរភាពមិនអាចសំរេចទៅបានទេបើគ្មានកម្មវិធីនៃព្រៃឈើដោយនិរន្តរភាពនោះ ។

ដោយសារតែមានការដាស់តឿនលើការបាត់បង់នូវព្រៃទឹកភ្លៀងនៅតំបន់ត្រូពិច និងតំបន់អាកាសធាតុបង្គួរក្នុងពេលជាច្រើនឆ្នាំកន្លងមកមានការកើតឡើងនូវតំរូវការក្នុងតំបន់អឺរ៉ុបខាងលិច និងអាមេរិកខាងជើងក្នុងការធានាថាផលិតផលក្តារបន្ទះ និងឈើដែលលក់ជាសារធារណៈនោះ បានត្រូវបានគេកាប់មកក្នុងលក្ខណៈមួយដែលធានាដល់ប្រពន្ធ័អេកូឡូស៊ី និងដោយនិរន្តរភាព ។ អ្នកចែចាយ និងលក់រាយមួយចំនួន បានតំរូវឱ្យអ្នកផ្គត់ផ្គង់របស់គេផ្តល់នូវការអះអាងថា ផលិតផលឈើរបស់គេនោះបានមកពីការគ្រប់គ្រងព្រៃដោយនិរន្តរភាព ។ ប្រពន្ធ័បញ្ជាក់អន្តរជាតិជាច្រើនត្រូវបានគេបង្កើតឡើងក្នុងគោលបំណងផ្តល់នូវតំរូវការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ថាផលិតផលឈើត្រូវបានគេរកមកដោយរបៀបគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ។ គំរូនៃការបញ្ជាក់បី ដែលត្រូវបានគេប្រើភាគច្រើននោះគឺ :

- អង្គការអន្តរជាតិសំរាប់ធ្វើមាត្រដ្ឋាន (ISO)
- ក្រុមប្រឹក្សាគ្រប់គ្រងព្រៃឈើ (FSC)
- អង្គការអន្តរជាតិផ្នែកឈើនៅតំបន់ត្រូពិក (ITTO)

បន្ថែមពីលើការជួយឱ្យវាអាចលក់បាននៅក្នុងទីផ្សារក្នុងតំបន់អឺរ៉ុប និងអាមេរិកខាងជើង ការបញ្ជាក់ពីការគ្រប់គ្រងព្រៃឈើដោយនិរន្តភាពអាចជាផ្លូវមួយឈានទៅរកការការពារ និង ថែទាំធនធានព្រៃឈើក្នុងអាងទន្លេមេគង្គ MRB ។ MRC កំពុងតែពុះពារដើម្បីទទួលបានការបញ្ជាក់ពីការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងក្លាយជាសមាជិកនៃក្រុមប្រឹក្សាគ្រប់គ្រងព្រៃឈើ ។

**មាត្រដ្ឋាន** ISO 14001:

អង្គការអន្តរជាតិសំរាប់ធ្វើមាត្រដ្ឋាន (ISO) គឺកើតឡើពីអង្គភាពមាត្រដ្ឋានជាតិនៃបណ្តាប្រទេសជាង ១៤០ ហើយបានបង្កើតមាត្រដ្ឋានជាង ១៣០០០ មាត្រដ្ឋាន សំរាប់ការផលិត និងសេវាកម្មរបស់រោងចក្រ និងអង្គការផ្សេងៗ ។ ប្រពន្ធ័មាត្រដ្ឋានគ្រប់គ្រងបរិស្ថាន ISO 14001 (EMS) គឺបង្កើតឡើងដើម្បីអនុវត្តន៍ដោយគ្រប់អង្គភាពទាំអស់ដែលផលិតនូវផលិតផល និងផ្តល់នូវសេវាកម្មផ្សេងៗ ។ ការរៀបរាប់លំអិតមានបង្ហាញនៅក្នុងមេរៀន F ។

ISO 14001 បានបញ្ជាក់នូវតំរូវការសំរាប់ការធ្វើផែនការ ការអនុវត្តន៍ ការត្រួតពិនិត្យ និងពិនិត្យមើលនូវប្រពន្ធ័គ្រប់គ្រងបរិស្ថាន ។ ដោយសារតែ ISO 24001 ជាអង្គភាពមូដ្ឋានដ៏ទូលំទូលាយនោះ ISO 14001 គឺមិនមែនបង្កើតឡើងជាពិសេសសំរាប់តែកិច្ចដំណើរការកាប់ឈើ និងគ្រប់គ្រងព្រៃឈើប៉ុណ្ណោះទេ ។ ទោះជាយ៉ាងណាក៏ដោយ មានមាត្រដ្ឋានបន្ថែមពិសេសមួយ គឺ ISO 14061 ដែលមានគោលការណ៏ណែនាំចំពោះការអនុវត្តន៏នូវ ISO 14001 សំរាប់ព្រៃឈើ ។ ដើម្បីបានទទួលស្គាល់ការបញ្ជាក់នេះអង្គភាពនិមួយៗត្រូវបង្កើតនូវប្រពន្ធ័គ្រប់គ្រងបរិស្ថាន EMS ដែលសមស្របតាមលក្ខណ: ISO 14001 ហើយក៏ដូចជាការបញ្ជាក់ផ្សេងៗទៀតដែរ គឺត្រូវអនុវត្តន៏នូវការវាយតំលៃជាប្រចាំដោយភ្នាក់ងារដែលត្រូវបានទទួលស្គាល់ឯករាជ្យមួយ ។

កិច្ចការទីមួយដែលតំរូវដោយ ISO 14001 គឺការកំណត់នូវរាល់ទិដ្ឋភាពបរិស្ថានសំខាន់ៗទាំងអស់ (ដែលសកម្មភាព និងផលិតផល រឺ សេវាកម្មអាចមានឥទ្ធិពលលើបរិស្ថានហើយបណ្តាលឱ្យមានផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន) ។ ក្នុងកិច្ចដំណើរការព្រៃឈើ និងការកាប់ព្រៃនោះ ទិដ្ឋភាពបរិស្ថានសំខាន់ៗនោះគឺ:

- ការប្រមូលផល: មានការប្រែប្រួលនូវប្រភេទឈើក្នុងព្រៃ និងជំរកសត្វព្រៃ
- ការរៀបចំទីតាំង: មានការប្រែប្រួលស្ថានភាពដី និងការថែទាំដី
- ការសាងសង់ផ្លូវថ្នល់: មានការប្រែប្រួលរំហូតទឹក ជំរកត្រី និងប្រពន្ធ័បង្ហូរចេញ
- ការដាំព្រៃឡើងវិញ: មានការប្រែប្រួលប្រភេទដើមឈើ និងចំនួនប្រភេទ។

ISO 14001 តំរូវឱ្យមានគោលបំណង ទិសដៅ និងផែនការដែលត្រូវអនុវត្តន៏ក្នុងការការពារ ឬកាត់បន្ថយហេតុប៉ះពាល់បរិស្ថានសំខាន់ៗ ។ ទិសដៅគឺការកាពារភាពក្រខ្វក់ និងការបន្តបង្កើននូវមុខងារអនុវត្តន៏ផ្នែកបរិស្ថានដែលឈានទៅរកការអភិវឌ្ឍន៏ដោយនិរន្តរភាព ។

## ក្រុមប្រឹក្សាគ្រប់គ្រងព្រៃឈើ (FSC)

ការគ្រប់គ្រងគឺជាការថែទាំ ការពារ និងបង្កើននូវទ្រព្យធន ឬធនធាន ។ FSC ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៣ ហើយដែលបង្កើតដោយអង្គការជំនួញឈើ អង្គការមិនមែនរដ្ឋាភិបាលផ្នែកបរិស្ថាន អង្គការ

ប្រជាជនមូលដ្ឋាន ក្រុមសហគមន៍ព្រៃឈើ និងអង្គការផ្តល់ការបញ្ជាក់ផ្សេងៗទៀត ។ MRC គឺជាសមាជិកមួយរបស់ FSC ។

FSC បានបង្កើតនូវគោលការណ៍ និងលក្ខខណ្ឌដែលបង្កើតឡើងដើម្បីណែនាំដល់មាត្រដ្ឋានអភិវឌ្ឍន៍របស់ថ្នាក់ជាតិ និងថ្នាក់តំបន់ ។ គោលការណ៍ និងលក្ខខណ្ឌដែលមានសង្ខេបខាងក្រោមនេះគឺប្រើសំរាប់ព្រៃនៅតំបន់ត្រូពិច តំបន់អាកាសធាតុបង្គួរ និងតំបន់ខាងជើងទាំងអស់ ហើយក៏អាចអនុវត្តន៍ឱ្យស្របទៅតាមស្ថានភាពក្នុងមូលដ្ឋាន និងតំបន់ដែរ ។ នោះគឺ :

- សិទ្ធកាន់កាប់ និងប្រើប្រាស់រយៈពេលវែងលើដីព្រៃ និងធនធានផ្សេងៗត្រូវតែកំណត់ កត់ត្រាទុក និងបង្កើតឡើងនៅក្នុងច្បាប់ ។
- សិទ្ធជាលក្ខណៈប្រពៃណី និងច្បាប់ចំពោះប្រជាជនមូលដ្ឋានលើកម្មសិទ្ធការប្រើប្រាស់ និងគ្រប់គ្រងដីព្រៃរបស់ខ្លួន ត្រូវតែបានគោរព និងទទួលស្គាល់ ។
- អង្គការព្រៃឈើ ឬឈើហ៊ុប ត្រូវៈ
    - អនុវត្តន៍នូវការគ្រប់គ្រងព្រៃឈើដោយសមស្របតាមច្បាប់ក្នុងប្រទេស និងសទ្ធិសញ្ញាអន្តជាតិ
    - បង្កើតនូវដំណើរការសំរាប់ការប្រើប្រាស់ផលិតផលច្រើនប្រភេទពីព្រៃដោយមានប្រសិទ្ធិភាព
    - ថែរក្សានូវមុខងាររបស់ប្រពន្ធ័អេកូឡូស៊ី និងបូរណភាពព្រៃឈើដោយរក្សានូវជីវចំរុះ ធនធានទឹក ដី និងប្រពន្ធ័អេកូឡូស៊ី ដែលងាយខូចខាត និងមានតែមួយនោះ
    - អនុវត្តន៍នូវផែនការគ្រប់គ្រងដែលបានកត់ត្រា និងថ្មីៗដើម្បីសំរេចបាននូវគោលដៅរយៈពេលវែងនៃការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព
    - ត្រួតពិនិត្យសុខភាពព្រៃឈើ ទិន្នផល ចង្វាក់គ្រប់គ្រង ផលប៉ះពាល់សង្គម និងបរិស្ថាន
    - ថែរក្សានូវព្រៃឈើអភិវឌ្ឍន៍បន្ទាប់បន្សំ និងព្រៃឈើធម្មជាតិ និងទីតាំងនៃសង្គម វប្បធម៌ និងបរិស្ថានសំខាន់ៗ
    - គ្រប់គ្រងព្រៃដាំដោយយោងទៅតាមគោលការណ៍ពីមុនទាំងអស់ ។

ដើម្បីសំរេចបាននូវគោលដៅទាំងនេះ FSC បានទទួលស្គាល់នូវភាពចាំបាច់ក្នុងការបង្កើននូវការយល់ដឹង និងការអនុវត្តន៍ដោយការចូលរួមរបស់បុគ្គលក្នុងដំណើរការគ្រប់គ្រងព្រៃឈើដោយរដ្ឋាភិបាល និងសាធារណៈក្នុងវិស័យដូចខាងក្រោម :

- បង្កើនការគ្រប់គ្រងព្រៃឈើ
- បញ្ចូលតំលៃពេញលេញនៃការគ្រប់គ្រង និងផលិតទៅក្នុងតំលៃផលិផលព្រៃឈើ (ដូចជាបញ្ចូលនូវតំលៃដែលគេកំពុងធ្វើវាឱ្យមានទៅខាងក្រៅក្នុងពេលនេះ)

- ជំរុញដល់កាប្រើប្រាស់ ធនធានព្រៃឈើឱ្យបានល្អ និងមានប្រយោជន៍ខ្ពស់បំផុត
- កាត់បន្ថយកាកសំណល់ និងការខូចខាត
- ជៀសវាងការប្រើប្រាស់ និងការប្រមូលផលហួសហេតុ ។

ក្រុមហ៊ុនដែលបានទទួលការបញ្ជាក់ពី FSC អាចធ្វើសញ្ញាសំគាល់នូវផលិតផលរបស់ខ្លួនដោយដាក់សញ្ញា SmartWood ដែលវាសំខាន់សំរាប់អ្នកទិញគិតថា ឈើនោះត្រូវបានរកមកក្នុងលក្ខណៈបរិស្ថានល្អ ពីព្រៃដែលគ្រប់គ្រងដោយនិរន្តរភាព ។

## អង្គការអន្តរជាតិផ្នែកឈើនៅតំបន់ត្រូពិក (ITTO)

ដោយមានមូលដ្ឋាននៅប្រទេសជប៉ុនអង្គការ ITTO មានសមាជិកនៅក្នុងប្រទេសចំនួន ៥៦ ប្រទេស ហើយធ្វើការយកចិត្តទុកដាក់ដល់ការអភិវឌ្ឍន៍ដោយនិរន្តរភាព និងការថែរក្សាព្រៃឈើតំបន់ត្រូពិចក្នុងពិភពលោក ។ លក្ខណ្ឌសំរាប់ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពរបស់ ITTOដែលបានជ្រើសរើសមកមួយចំនួននោះគឺៈ

- ថែទាំ និងការពារធនធានព្រៃឈើឱ្យផុតពីការទន្ទ្រាន ។
- ប្រើប្រាស់នូវរបៀបគ្រប់គ្រង និងផែនការប្រើប្រាស់ដីដ៏ល្អបំផុត
- ឱ្យសហគមន៍មូលដ្ឋានដែលពឹងផ្អែកលើព្រៃឈើចូលរួមក្នុងសកម្មភាព និងការសំរេចចិត្តផ្សេងៗ
- ផ្តល់នូវ :
    - ធនធានហិរញ្ញវត្ថុ និងការលើកទឹកចិត្តដល់ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព
    - ក្របខ័ណ្ឌគាំទ្រដល់ស្ថាប័ន
    - ផលប្រយោជន៍ផ្នែកវប្បធម៌ សង្គម និងសេដ្ឋកិច្ច
- ថែរក្សាជីវចំរុះ
- ការពារទឹក និង ដីធ្លី

អង្គការ ITTO ក៏បានចូលរួមផងដែរក្នុងការបង្កើនសមត្ថភាព និងការបណ្តុះបណ្តាលដល់បុគ្គលិកក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការអនុវត្តន៍នូវការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងដំណើរការធ្វើឱ្យមានតំលៃបន្ថែមទៀតលើផលិតផលឈើដំបូងនោះ ។

## របៀបគ្រប់គ្រងព្រៃឈើដោយនិរន្តភាព

ឧទាហរណ៏នៃការអនុវត្តន៍ខ្លះៗ ដែលអាចជួយឱ្យសំរេចបាននូវការគ្រប់គ្រងព្រៃឈើដោយនិរន្តភាពក្នុងអាង MRB និងត្រូវបានបង្ហាញក្នុងផ្នែកខាងក្រោមនេះ ។

វាពុំមានករណីណាមួយដែលងាយស្រួលអនុវត្តន៍នោះទេ ប៉ុន្តែវាចាំបាច់ត្រូវកំណត់វានៅក្នុងពេលនេះ ។ ជំហានដំបូងនោះគឺការបង្កើនការត្រួតពិនិត្យលើសកម្មភាពកាប់ឈើដែលកំពុងធ្វើដោយ ធ្វើការចរចារឡើងវិញទៅលើកិច្ចសន្យាកាប់ឈើទាំងអស់ដោយចំហរ និងមានតម្លាភាព ។ កិច្ចសន្យាថ្មីៗត្រូវឱ្យតំលៃឱ្យត្រឹមត្រូវដល់ធនធានព្រៃឈើ និងកំណត់ឱ្យបានច្បាស់នូវតំរូវការសំរាប់អនុវត្តន៍ការកាប់ឈើ និងប្រុងប្រយត្ន័ការពារធនធានប្រពន្ធ័អេកូឡូស៊ីផ្សេងៗ ។

គឺត្រូវមានការត្រួតពិនិត្យយ៉ាងតឹងតែងទៅលើការនាំឈើចេញពីបណ្តាប្រទេសសជាមាជិកនិមួយៗដើម្បីធានាថា មានតែឈើដែលបានទទួលច្បាប់អនុញ្ញាត្តិទៃដែលបានយកចេញ ហើយចំណូល និងពន្ធដារត្រូវបានប្រមូលត្រឹមត្រូវ និងគ្រប់គ្រាន់ ហើយចំនួនឈើនោះមិនបានគំរាមគំហែងដល់ទិន្នផលដ៏មាននិរន្តរភាពរបស់ព្រៃឈើទេ ។ គំរោងត្រួតពិនិត្យឧក្រិដ្ឋកម្មព្រៃឈើនៅប្រទេស កម្ពុជា ដែលឧបត្ថមដោយអង្គការ UNEP, DANIDA និងភ្នាក់ងារដ៏ទៃទៀត គឺជាឧទាហរណ៏មួយនៃការឆ្លើយតបចំពោះតំរូវការទប់ទល់នឹងការកាប់ឈើខុសច្បាប់ ។ គោលនយោបាយសំរាប់អនុវត្តន៏ការគ្រប់គ្រងដោយសហគមន៏មូលដ្ឋាន និងការកាន់កាប់ព្រៃឈើ អាចបណ្តាលឱ្យមានដំណើរការទិន្នផលប្រកបដោយនិរន្តរភាពជាងការជួលដីទៅឱ្យអ្នកខាងក្រៅធ្វើអាជីវកម្មលើព្រៃឈើនោះ ។

បន្ថែមពីនោះទៀត គឺថាព្រៃឈើត្រូវតែបានការការពារទប់ទល់នឹងការ កាប់ឈើខុសច្បាប់ ការបរបាញ់សត្វ និងការរុករករុក្ខជាតិ និងការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត និងសារជាតិគីមីផ្សេងៗទៀតហួសប្រមាណ ។

## បញ្ហាដែលទាក់ទងនឹងទឹកក្នុងការគ្រប់គ្រងព្រៃដោយនិរន្តរភាព

ខាងក្រោមនេះគឺជារបៀបកាប់ឈើមួយចំនួនដែលអាចជួយដល់ការការពារគុណភាពទឹក ធារាសាស្រ្ត និងប្រពន្ធ័អេកូឡូស៊ីទឹកនៃព្រៃឈើ :

- នៅក្នុងតំបន់មាត់ទឹកត្រូវទុកព្រៃដែលមិនត្រូវកាប់ឈើចំងាយរហូតដល់ ៣០ ម៉ែត្រ ដើម្បីកាត់បន្ថយការហូរនាំនូវសារជាតិ និងកករពីតំបន់ដែលបានកាប់ឈើទៅក្នុងទឹក និងដើម្បីទុកម្លប់ឈើ និងរុក្ខជាតិផ្សេងៗទៀតនៅក្នុងផ្លូវទឹក និងមាត់បឹងដើម្បីជាជំរកដល់សត្វក្នុងទឹក ។
- ដូចគ្នានេះផងដែរគឺដើម្បីកាពារកករដែលហូរធ្លាក់ទៅក្នុងផ្លូវទឹកនោះ ផ្លូវដែលដឹកឈើត្រូវសង់:
    - ឆ្ងាយពីច្រាំង ផ្លូវទឹក និងដីសើម
    - កុំឱ្យមានជំរាលខ្លាំង និងជើងដែលមិនរឹងមាំ
    - សង់យ៉ាងណាដើម្បីកាត់បន្ថយកុំឱ្យមានកាត់កន្លែងផ្លូវទឹកច្រើន
    - ឱ្យមានស្ពានឆ្លងកាត់ទទឹងផ្លូវទឹក
    - កុំឱ្យមានការឆ្លងកាត់ផ្លូវទឹក និងតំបន់ដីសើម
- នៅពេលកាប់ឈើត្រូវមានការប្រយត្ន័ប្រយែងដើម្បីជៀសវាងកុំឱ្យមានការហាប់ដី ខូងដីដែលអាចធ្វើឱ្យថយចុះគុណភាពដី និងបង្កើតឱ្យមានរំហូរទឹកលើដី ។ សារជាតិគីមី ថ្នាំសំលាប់សត្វល្អិត ប្រេង

ត្រូវដឹកឱ្យឆ្ងាយពីរំហូរទឹកលើដី ហើយការពារកុំឱ្យមានជ្រាបចូលទៅក្នុងទឹកក្រោមដី ។ កំទេចកំទីសំណល់ព្រៃឈើ និងឧបករណ៍កាប់ឈើ មិនត្រូវឱ្យមានធ្លាក់ចូលក្នុងផ្លូវទឹក លើកលែងតែក្នុងករណីកំទេចឈើធំៗកំណាត់ណាមួយដែលអាចជាជំរកសត្វក្នុងទឹក ។

- ក្រោយពេលកាប់ឈើហើយ ដីទទេនោះត្រូវដាំរុក្ខជាតិជាបន្ទាន់ដើម្បីកាត់បន្ថយការហូរដាច់ដី ។

## សង្ខេបចំណុចសំខាន់ៗ

- ព្រៃឈើដែលមានសុខភាពល្អអាចការពារធនធានទឹកក្នុងអាង MRB ពីដីល្បប់ និងទឹកជំនន់ ។
- ការបាត់បង់ព្រៃឈើក្នុងបណ្ដាប្រទេសជាសមាជិក បានគំរាមគំហែងដល់ទឹក និងធនធានដែលពឹងផ្អែកផ្សេងៗទៀតក្នុងអាង MRB ។
- ការគ្រប់គ្រងព្រៃឈើដោយមាននិរន្តរភាពត្រូវការឱ្យមានការបង្កើត និងបញ្ចូលគ្នានូវកត្តាច្បាប់ ស្ថាប័ន បច្ចេកទេស សង្គម និងសេដ្ឋកិច្ច ។
- ប្រព័ន្ធបញ្ជាក់អន្តរជាតិជាច្រើនបានទទួលស្គាល់ និងឱ្យតំលៃលើការអនុវត្តន៍ដែលសមស្របតាមលក្ខខណ្ឌនៃការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ។
- ការកាប់ឈើត្រូវធ្វើឡើងតាមរបៀបមួយដែលការពារដល់ភាពក្រខ្វក់ចំពោះធនធានទឹក និង ខូចខាតដល់ជំរកក្នុងទឹក ។

## កម្មវិធីផ្សេងៗរបស់ MRC សំរាប់ការអភិវឌ្ឍន៍ដោយនិរន្តរភាព

~~~~~~~

គណៈកម្មការទន្លេមេគង្គត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៥ ដោយមានការចុះហត្ថលេខាលើកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍ដោយនិរន្តរភាពនៃអាងទន្លេមេគង្គ (MRB) ដោយប្រទេសជាសមាជិកគឺ កម្ពុជា ឡាវ ថៃ និងវៀតណាម ។ កិច្ចព្រមព្រៀងសហប្រតិបត្តិការវាងប្រទេសទាំងនេះមានតាំងពីឆ្នាំ ១៩៥៧ តាំងពីគណៈកម្មាធិការមេគង្គបានបង្កើតឡើងដំបូងម្លេះ ។ បេសកកម្មមុន បានផ្តោតការយកចិត្តទុកដាក់លើ ការធ្វើអាជីវកម្មលើលទ្ធភាពនៃការអភិវឌ្ឍន៍វារីអគ្គីសនី និងនាវាចរនៅក្នុងអាងទន្លេ ។

ទស្សនៈវិស័យនៃ MRC ដែលបានបង្កើតឡើងវិញនេះគឺ "ការរីកចំរើនរុងរឿងផ្នែកសេដ្ឋកិច្ច យុត្តិធម៌សង្គម និងបរិស្ថានល្អក្នុងអាងទន្លេមេគង្គ" ។ ទស្សនៈវិស័យ និងបេសកម្មរបស់ MRC បានដឹកនាំទៅតាមផ្លូវផ្សេងៗនៃសតវត្សទី ២១ គឺការខិតខំប្រឹងប្រែងឈានទៅរកការអភិវឌ្ឍន៍សេដ្ឋកិច្ច រួមជាមួយ និងយុត្តិធម៌សង្គម និងការអភិរក្សបរិស្ថាន ។

## កម្មវិធីផ្សេងៗរបស់ MRC ដើម្បីការអភិវឌ្ឍន៍ដោយនិរន្តរភាព

ដើម្បីអនុវត្តន៍នូវផែនការជាយុទ្ធសាស្ត្ររបស់ខ្លួន MRC បានបោះជំហានពីវិធីសាស្ត្រដែលផ្តោតលើគំរោងទៅជាការផ្តោតទៅលើកម្មវិធីវិញ ហើយពីរចនាសម្ពន្ធ័អង្គភាពដែលមានលក្ខណៈជាវិសយ័និមួយៗដាច់គ្នានោះទៅជា លក្ខណៈទាក់ទងគ្នាវិញ ដើម្បីឱ្យអង្គភាពនេះអាចឆ្លើយតបដោយមានប្រសិទ្ធភាពថែមទៀតទៅនឹងភាពសាំញ៉ាំនៃការគ្រប់គ្រងប្រពន្ធ័អេកូឡូស៊ី និងការអភិវឌ្ឍន៍ដោយនិរន្តរភាពក្នុងអាងទន្លេទាំងមូល ។ ទោះបីជាកម្មវិធីតាមផ្នែកនិមួយៗនៅតែមានតួនាទីសំខាន់ក៏ដោយ MRC បានមានបំណងផ្លាស់ប្តូរឆ្ពោះទៅរកតួនាទីគ្រប់គ្រង និងត្រួតពិនិត្យនៅក្នុងអាង MRB ។
~~~~~~~

**គោលបំណងរបស់** MRC

អាងទន្លេមេគង្គ និងធនធានធម្មជាតិដែលពាក់ព័ន្ធ និងបរិស្ថានគឺជាទ្រព្យធនធម្មជាតិដែលមានតំលៃធំធេងចំពោះប្រទេសជាសមាជិកទាំងអស់ សំរាប់ជាសេដ្ឋកិច្ច សុខមាលភាពសង្គម និងជីវភាពរស់នៅរបស់ប្រជាជនរបស់ខ្លួន ។

**តួនាទីរបស់** MRC

អះអាងបញ្ជាក់ឡើងវិញនូវការកំណត់ក្នុងការបន្តសហប្រតិបត្តិការ និងជុំរុញក្នុងលក្ខណៈកសាង និងគិតពីផលប្រយោជន៍ទៅវិញទៅមកនៃការអភិវឌ្ឍន៍ដោយនិរន្តរភាព ការប្រើប្រាស់ ការគ្រប់គ្រង និងថែរក្សាទឹក និងធនធានពាក់ព័ន្ធសំរាប់គោលបំណងនាវាចរ និងមិនមែននាវាចរ ការលំហែរកាយ និងទេសចរណ៍ និងដើម្បីការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសុខមាលភាពនៃរដ្ឋជាសមាជិកទាំងអស់ ដោយសមស្របតាមតំរូវការ ការពារ ថែទាំ ពង្រីក និងគ្រប់គ្រងបរិស្ថាន និងស្ថានភាពទឹក និងការថែទាំតុល្យភាពអេកូឡូស៊ីជាពិសេសសំរាប់អាងទន្លេនេះ ។

**បេសកម្មរបស់** MRC

ដើម្បីជំរុញ និងទំនាក់ទំនងការអភិវឌ្ឍន៍ និងគ្រប់គ្រងដោយនិរន្តរភាពនូវទឹក និងធនធាន ដែលពាក់ព័ន្ធ ដើម្បីជាប្រយោជន៍របស់ប្រទេសទៅវិញទៅមក និងសុខមាលភាពរបស់ប្រជាជន ដោយអនុវត្តន៍នូវកម្មវិធី និងសកម្មភាពជាយុទ្ធសាស្ត្រ និងផ្តល់នូវព័ត៌មានផ្នែកវិទ្យាសាស្ត្រ និងយោបល់ផ្នែកនយោបាយ ។

ដោយប្រកាន់ខ្ជាប់នូវគោលដៅនេះ MRC បានបង្កើតនូវចំណាត់ថ្នាក់នៃកម្មវិធីដូចខាងក្រោម :

❋ **កម្មវិធីស្នូល**

- ផែនការអភិវឌ្ឍន៍អាងទន្លេ
- កម្មវិធីប្រើប្រាស់ទឹក
- កម្មវិធីបរិស្ថាន

❁ **កម្មវិធីតាមវិស័យ**

- ជលផល
- កសិកម្ម ការស្រោចស្រព និងព្រៃឈើ
- ធនធានទឹក និងធារាសាស្ត្រ
- នាវាចរ
- ទេសចរណ៍
- ការអភិវឌ្ឍន៍ធនធានមនុស្ស

**ផែនការអភិវឌ្ឍន៍អាងទន្លេ** (BDP)

គោលដៅរបស់ DBP គឺដើម្បីៈ

- រៀបចំការធ្វើផែនការដើម្បីគ្រប់គ្រង និងអភិវឌ្ឍន៍ដោយនិរន្តរភាពនូវធនធានក្នុងអាង MRB
- ធ្វើឱ្យមានតុល្យភាពរវាងការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម និងការព្រួយបារម្ភផ្នែកបរិស្ថាន
- បង្កើតនូវក្របខ័ណ្ឌអភិវឌ្ឍន៍ដោយផ្អែកលើចំណេះដឹងបច្ចេកទេស និងការចូលរួមពី"ភាគីពាក់ពន្ធ័"
- ជំរុញដល់កិច្ចសហប្រតិបត្តិការរវាងអ្នកពាក់ពន្ធ័ទាំងអស់ ។

**កម្មវិធីប្រើប្រាស់ទឹក** (WUP)

គោលដៅរបស់ WUPគឺដើម្បីៈ

- គាំទ្រដល់ការគ្រប់គ្រងដោយនិរន្តរភាពនូវធនធានទឹកក្នុងអាង MRB ខាងក្រោម
- ធានាដល់ផលប្រយោជន៍ទៅវិញទៅមកនៃការប្រើប្រាស់ទឹក
- រក្សានូវតុល្យភាពអេកូឡូស៊ី
- បង្កើតនូវចំនេះដឹងរួមជាមូលដ្ឋាន និងគំរូម៉ូដែលធារាសាស្ត្រ
- បង្កើតច្បាប់គ្រប់គ្រងការប្រើប្រាស់ទឹកក្នុងអាង MRB
- បង្កើនសមត្ថភាពស្ថាប័ននៃអង្គភាព MRC និងគណៈកម្មាធិការជាតិទន្លេមេគង្គទាំងអស់ (NMCs) ។

**កម្មវិធីបរិស្ថាន** (EP)

សំរាប់ EP ការយកចិត្តទុកដាក់គឺទៅលើប្រជាជន ដោយមានគោលដៅៈ

- ធ្វើឱ្យមានតុល្យភាពរវាងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការការពារបរិស្ថានដើម្បីជាប្រយោជន៍ដល់ប្រជាជនរស់នៅក្នុងអាង MRB ។

- បង្កើតប្រពន្ធ័ដើម្បីៈ
  - ត្រួតពិនិត្យសុខភាពបរិស្ថាននៃអាង MRB
  - បង្កើនច្បាប់ និងនយោបាយបរិស្ថាន
  - បង្កើនកិច្ចសហប្រតិបត្តិការរវាងបណ្តាប្រទេសជាសមាជិក
  - បង្កើនការយល់ដឹងពីបរិស្ថានរបស់សាធារណៈជន

EP បានបង្កើតនូវគោលបំណងមួយចំនួននៅគ្រប់កំរិតនៃការអភិវឌ្ឍន៍ រួមទាំងគោលបំណងលំអិត និងមធ្យម ។ គោលបំណងលំអិតរបស់ EP គឺៈ

១- បង្កើនសមត្ថភាពសំរាប់ត្រួតពិនិត្យ និងវាយតំលៃស្ថានភាពបរិស្ថានក្នុងអាង MRB ដោយបង្កើតគោលនយោបាយល្អៗ និងរបៀបគ្រប់គ្រងសំរាប់ការអភិវឌ្ឍន៍ដោយនិរន្តរភាព ។

២- បង្កើនចំនេះដឹងជាមូលដ្ឋានលើបញ្ហាបរិស្ថានក្នុងអាង MRB ជួយដល់ការបង្កើតគោលនយោបាយរបស់រដ្ឋាភិបាល ដោយផ្តោតការយកចិត្តទុកដាក់លើទំនាក់ទំនងរវាងប្រជាជន ការអភិវឌ្ឍន៍ និងបរិស្ថាន ។

៣- បង្កើតនូប្រព័ន្ធទំនើបមួយសំរាប់ការផ្លាស់ប្តូរពត៌មានផ្នែកបរិស្ថាន និងការទំនាក់ទំនង ការចែកចាយពត៌មានក្នុងតំបន់ដើម្បីទទួលបានលទ្ធផលល្អប្រសើបំផុត ។

៤- បង្កើនគោលនយោបាយបរិស្ថាន និងច្បាប់ទាក់ទងនឹងការគ្រប់គ្រងទឹក និងធនធានដែលពាក់ពន្ធ័ ការគិតគូដល់យិនឌ័រ ជនជាតិភាគតិច និងទិដ្ឋភាពសេដ្ឋកិច្ច ជួយសំរួលដល់ការបង្កើតគោលនយោបាយ ច្បាប់ និងសេចក្តីណែនាំ ដោយធានានូវភាពស្របគ្នាជាមួយអាទិភាពរបស់ជាតិ បង្កើតនូវដំណើរការអនុវត្តន៍ EIA ក្នុងតំបន់ និង SEA ។

៥- បង្កើនការយល់ដឹង និងសមត្ថភាពក្នុងការដោះស្រាយបញ្ហាបរិស្ថាន បង្កើនការយល់ដឹងរបស់បុគ្គលិកស្តីពីបញ្ហាក្នុងអាងទន្លេទាំងមូល និងសមត្ថភាពក្នុងការអនុវត្តន៍នូវសម្ថភាពចាំបាច់ ។

៦- ក្នុងការបង្កើនទំនាក់ទំនងនៃការអភិវឌ្ឍន៍ក្នុងអាងទន្លេ MRC និងផ្តល់នូវវេទិការ និងមធ្យោបាយរកពត៌មានសំរាប់ការពិភាក្សារវាងភ្នាក់ងារអ្នកផ្តល់ទុន និងអ្នកអនុវត្តន៍ ដើម្បីបង្កើននូវការទំនាក់ទំនងនៃការអភិវឌ្ឍន៍ដែលអាចមានផលប៉ះពាល់លើបរិស្ថាន ។

## កម្មវិធីជលផល

គោលដៅនៃកម្មវិធីជលផលគឺដើម្បី :

- សម្រេចបាននូវលទ្ធភាពផ្តល់សារជាតិអាហារ និងសេដ្ឋកិច្ចនៃជលផលក្នុងអាង MRB
- បង្កើនការគ្រប់គ្រងប្រពន្ធ័អេកូឡូស៊ីរបស់ទឹក
- បង្កើតរបៀបគ្រប់គ្រងដោយនិរន្តរភាពលើការចាប់ត្រី
- បង្កើន និងពង្រីកនូវផលិតផលត្រីតាមរយៈបច្ចេកទេសវារីវប្បកម្ម និងអាងជលផល ។

**កម្មវិធីកសិកម្ម ការស្រោចស្រព និងព្រៃឈើ**

គោលដៅនៃកម្មវិធីនេះគឺដើម្បី :

- បង្កើននូវការគ្រប់គ្រងដោយនិរន្តរភាពលើធនធានទឹក ដី និងព្រៃឈើ
- បង្កើនលទ្ធភាពសេដ្ឋកិច្ចនៃធនធាន
- ធ្វើទំនើបកម្មប្រពន្ធ័ស្រោចស្រព
- បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក
- ធ្វើផែនការសកម្មភាព កសិកម្ម និងព្រៃឈើក្នុងតំបន់ឆ្លងដែន និងតំបន់ផ្ទៃរងទឹកភ្លៀងដែលងាយរងគ្រោះថ្នាក់ ។

**កម្មវិធីធនធានទឹក និងធារសាស្ត្រ**

គោលដៅនៃកម្មវិធីនេះគឺ :

- ការប្រើប្រាស់ធនធានទឹកដោយនិរន្តរភាព
- លើកឡើងពីការគ្រប់គ្រង និងកាត់បន្ថយផលប៉ះពាល់ពីការការពារទឹជំនន់ និងវារីអគ្គិសនី ។

**កម្មវិធីទេសចរណ៍**

គោដៅនៃកម្មវិធីទេសចរណ៍ គឺដើម្បីអភិវឌ្ឍន៍ទេសចរណ៍ដែលស្របគ្នា នឹងការការពារបរិស្ថាន ។

**កម្មវិធីនាវាចរ**

គោលដៅរបស់កម្មវិធីនាវាចរគឺដើម្បី:

- បង្កើតនូវឱកាសការងារ និងការរកចំណូល ដោយអភិវឌ្ឍន៍នូវជំនួញអន្តរជាតិតាមរយៈនាវាចរ
- ជួយដល់ការកាត់បន្ថយភាពក្រីក្រតាមរយៈការបង្កើនការធ្វើដំណើរទៅតំបន់ដាច់ស្រយាល
- បង្កើនសេរីភាពផ្នែកនាវាចរ
- បង្កើតនូវក្របខណ្ឌ័សំរាប់សិរត្ថិភាព ការទំនាក់ទំនង និងប្រសិទ្ធភាពនៃការដឹកជញ្ជូនតាមផ្លូវទឹក
- អនុវត្តន៍ការងារទន្លេដើម្បីលុបបំបាត់នូវឧសគ្គ័នានាដល់ការធ្វើនាវាចរ ។

**កម្មវធីអភិវឌ្ឍន៍ធនធានមនុស្ស** (HRD)

គោលដៅរបស់ HRDគឺ:

- បង្កើតនូវជំនាញ និងសមត្ថភាពសមស្របដើម្បីអនុវត្តន៍នូវផែនការជាយុទ្ធសាស្ត្រ
- ផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រងធនធានទឹកក្នុងអាងទន្លេទាំងមូល

- ពង្រឹងផ្នែករដ្ឋបាល ការដឹកនាំ ក្រុមការងារ និងវប្បធម៌អង្គភាពនៅគ្រប់កំរិតក្នុង MRC, NMC និងភ្នាក់ងាររដ្ឋាភិបាលក្នុងបណ្តាប្រទេសជាមាជិក
- បញ្ចូល និងគិតគូដល់បញ្ហាទាក់ទងនឹងផ្នែក យិនឌ័រ ។

## ការពិនិត្យមើលលើកម្មវិធីផ្សេងៗរបស់ MRC

យើងអាចពិនិត្យឃើញនៅក្នុងគោលបំណងនៃកម្មវិធីផ្សេងៗថា MRC បានកំពុងយកចិត្តទុកដាក់លើគោលការណ៍ និងការអភិវឌ្ឍន៍ដោយនិរន្តរភាពក្នុងកំរិតអាងទន្លេទាំងមូល ក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានទឹក បរិស្ថាន ព្រៃឈើ ជលផល កសិកម្ម នាវាចរ ការធ្វើដំណើរ និងការអភិវឌ្ឍន៍ធនធានមនុស្ស ។ ប្រជាជនគឺជាកត្តាដែលត្រូវបានយកចិត្តទុកដាក់ជាចំបង ហើយសមភាពនៃ យិនឌ័រ និងភាពក្រីក្រគឺត្រូវចាត់ទុកជាបញ្ហាដែលត្រូវយកចិត្តទុដាក់ ។ នៅក្នុងមេរៀនមុនៗ ផ្នែកនិមួយៗនេះ ត្រូវបានលើកយកមកបង្ហាញថាជាកត្តាចាំបាច់សំរាប់ការអភិវឌ្ឍន៍ក្នុងរបៀបប្រកបដោយនិរន្តរភាព ។

MRC បានកំពុងធ្វើខ្លួនជាកត្តាលឹករ និងជាអ្នកដឹកនាំផ្លូវដល់ប្រទេសជាសមាជិកទាំអស់ និងប្រជាជនរបស់គេឈានទៅរកការរីកចំរើនសេដ្ឋកិច្ច យុត្តិធម៌សង្គម និងបរិស្ថានល្អមួយក្នុងអាង MRB ។

## សង្ខេបចំណុចសំខាន់ៗ

- MRC បានកំណត់តួនាទីរបស់ខ្លួនក្នុងការជំរុញដល់ការអភិវឌ្ឍន៍ដោយនិរន្តរភាពក្នុងអាង MRB តាមរយៈការអនុវត្តន៍នូវគោលបំណងនៃកម្មវិធីតាមវិស័យ និងកម្មវិធីស្នូលនានា ។
- កម្មវិធីបានផ្តោតលើការអភិវឌ្ឍន៍ដែលយកចិត្តទុកដាក់ជាពិសេសដល់ប្រជាជន តាមរយៈការធ្វើផែនការរួមនៃសកម្មភាពក្នុងអាងទន្លេ ការយល់ដឹងពីបរិស្ថាន និងការទទួលស្គាល់នូវភាពទាក់ទងគ្នានៃវិស័យទាំងអស់នៅក្នុងអាង MRB ។
- គោលបំណងសំខាន់ៗគឺដើម្បីធ្វើឱ្យមានតុល្យភាពនៃសេដ្ឋកិច្ច-សង្គម និងការព្រួយបារម្ភផ្នែកបរិស្ថាន និងដើម្បីសំរេចបាននូវផលប្រយោជន៍ដោយនិរន្តរភាពទៅវិញទៅមកសំរាប់បណ្តាប្រទេសជាសមាជិកទាំងអស់ ។